សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royal de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងវិស័យសំណង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **លោក លីម លីម៉ះ**

ណែនាំដោយ
លោកគ្រូ **យិត សុខួច**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royal de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងវិស័យសំណង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **លោក លីម លីម័រ**

ណែនាំដោយ
លោកគ្រូ **យិត សុខួច**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# អំណះអំណាង

ខ្ញុំបាទ **លីម លីម៉័រ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២៤ ឆ្នាំសិក្សា២០២០-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការអះអាងចំពោះខ្លឹមសារនៃសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ពិតជាកើតចេញពីគំនិតផ្ទាល់ខ្លួនរបស់ខ្ញុំ និងបានមកពីការជួយជ្រោមពីសំណាក់ **លោកសាស្ត្រាចារ្យ ឃិត សុខួច** ដែលជាសាស្ត្រាចារ្យណែនាំខ្ញុំបាទ បានជួយជ្រោមជ្រែងជាខ្លាំងផ្តល់នូវសៀវភៅឯកសារជំនួយស្មារតី បទដ្ឋានច្បាប់នានាពាក់ព័ន្ធនឹងវិស័យសំណង់នេះ ជាពិសេសនោះគឺអនុសាសន៍ដ៏ខ្ពង់ខ្ពស់ក្នុងការរៀបចំរចនាបថឲ្យមានសោភណភាព។ ជាថ្មីម្តងទៀតខ្ញុំបាទសូមធានាអះអាងថាសារណានេះមិនមានការលួចចម្លងស្នាដៃពីសារណា របាយការណ៍ ឬនិក្ខេបបទរបស់អ្នកផ្សេងឡើយដោយដកស្រង់ចេញតែពីលិខិតបទដ្ឋានច្បាប់ដែលពាក់ព័ន្ធតែប៉ុណ្ណោះ។

ថ្ងៃព្រហស្បតិ៍ ១៥រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៤

**ហត្ថលេខា**

**លីម លីម៉័រ**

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **លីម លីម៉ី** ជានិស្សិត *ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៤ ក្នុងឆ្នាំសិក្សា ២០២៣-២០២៤* សូមថ្លែងនូវកត្តញ្ញូ និងដឹងគុណដ៏ជ្រាលជ្រៅមិនអាចកាត់ថ្លៃបានដល់ **លោកអ្នកមានគុណទាំងពីរ** របស់ខ្ញុំបាទ ដែលបានផ្តល់កំណើត លះបង់កម្លាំងកាយចិត្ត ធ្វើពលិកម្មគ្រប់បែបយ៉ាងក្នុងការចិញ្ចឹមបីបាច់ថែរក្សាដោយផ្តល់នូវភាពកក់ក្តៅ ក្តីស្រឡាញ់ ព្រហ្មវិហារធម៌ និងការអប់រំទូន្មានប្រៀនប្រដៅឲ្យប្រព្រឹត្តអំពើល្អតាមគន្លងធម៌ព្រមទាំងឧបត្ថម្ភជាថវិកាក្នុងការសិក្សារៀនសូត្រដល់រូបខ្ញុំបាទ ជាងនេះទៅទៀតខ្ញុំបាទសូមថ្លែងអំណរគុណដល់លោកគ្រូ អ្នកគ្រូដែលតែងតែបង្ហាត់បង្រៀនផ្តល់ចំណេះដឹងនិងតាមធ្វើជាឪពុកម្តាយទី២របស់សិស្សនិស្សិតគ្រប់ៗគ្នា។ កូនសូមប្រណិប័តន៍ និងសូមសម្តែងនូវកត្តញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅបំផុតដល់ចំពោះអ្នកមានគុណដែលមានចំពោះកូន។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណដល់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្នសម្តេចជាប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលកន្លងមកសម្តេចបានដឹកនាំប្រទេសកម្ពុជាប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយកន្លងមក និងបានរក្សានូវសន្តិភាពគង់វង្ស និងការអភិវឌ្ឍជាដរាបរៀងមក។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណដល់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបន្តការដឹកនាំប្រទេសកម្ពុជាបន្ទាប់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជាថ្នាក់ដឹកនាំថ្មីប្រកបដោយសក្តានុពល និងមានសមត្ថភាពបន្តការរក្សាសន្តិភាព និងការអភិវឌ្ឍជាដរាបរៀងទៅ។

ខ្ញុំបាទសូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តម បណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច លោក-លោកស្រី សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ ព្រមទាំងលោក-លោកស្រី លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ**ទាំងអស់នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់នូវការអប់រំ ព្រមទាំងផ្តល់នូវចំណេះដឹង ក្រមសីលធម៌ដល់ខ្ញុំបាទក្នុងរយៈពេល៤ឆ្នាំនេះ។

ជាពិសេសខ្ញុំបាទ សូមថ្លែងអំណរគុណជូនចំពោះ **លោកសាស្ត្រាចារ្យ ឃិត សូខួច សាកលវិទ្យាធិការរង** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាសាស្ត្រាចារ្យណែនាំក្នុងការស្រាវជ្រាវមួយនេះ ដែលលោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃផ្តល់នូវគំនិតយោបល់ក្នុងការសរសេរ ការកែសម្រួល និងតម្រង់ផ្លូវដល់ខ្ញុំបាទកន្លងមក រហូតបានសម្រេចនូវស្នាដៃសារណាមួយនេះឡើង។

# អារម្ភកថា

ជាបឋមខ្ញុំបាទ **លីម លីម៉េះ** សូមសម្តែងការស្វាគមន៍ និងគោរពជម្រាបសួរដល់ឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តម លោកជំទាវ សាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាទីគោរពដ៏ខ្ពង់ខ្ពស់។

ក្នុងឆ្នាំសិក្សា២០២៣-២០២៤នេះ ខ្ញុំបាទ ជានិស្សិតឆ្នាំទី៤ ពិតជាមានសេចក្តីសោមនស្សរីករាយជាពន់ពេកដោយបានការធ្វើកិច្ចការស្រាវជ្រាវមួយនេះ ដោយសារមានការផ្តល់កម្លាំងចិត្តពីអ្នកមានគុណ និងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យកន្លងមកទើបពួកខ្ញុំកាន់តែមានកម្លាំងចិត្តខ្លាំងក្លាក្នុងការស្រាវជ្រាវចងក្រងជាសារណាមួយនេះឡើង។

សៀវភៅសារណាខ្ញុំបាទស្រាវជ្រាវហើយនេះមានចំណងជើងថា **ការគ្រប់គ្រងវិស័យសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា** ដែលកំពុងមានវត្តមាននៅក្នុងដៃរបស់លោកអ្នក គឺបានកើតឡើងតាមរយៈនៃការខិតខំប្រឹងប្រែង និងស្រាវជ្រាវដោយយកចិត្តទុកដាក់ខ្លាំងបំផុតដើម្បីសម្រិតសម្រាំង និងចម្រាញ់យកខ្លឹមសារដែលមានតម្លៃមានគុណភាព និងមានសារៈប្រយោជន៍បំផុតមកចងក្រងជាសៀវភៅនេះឡើង។ សម្រាប់អ្នកដែលសិក្សាជំនាញច្បាប់ហើយក៏ដូចជាអ្នកដែលចង់បាននូវចំណេះដឹងថ្មីៗផ្នែកការងារសាងសង់សំណង់និងស្ថាបត្យកម្ម។ បើចង់ដឹងថាអត្ថន័យខ្លឹមសារនេះមានអត្ថប្រយោជន៍ខ្លាំងប៉ុណ្ណានោះ សូមលោកអ្នកដាក់ចិត្តដាក់កាយព្យាយាមអានដោយយកចិត្តទុកដាក់ និងកត់ត្រាកន្លែងសំខាន់ទុកនោះលោកអ្នកនឹងបានជ្រាបថាសៀវភៅសារណាមួយនេះមានតម្លៃ ព្រមទាំងមានគុណប្រយោជន៍ប៉ុណ្ណា។

ជាចុងក្រោយខ្ញុំបាទ សង្ឃឹមថាសារណាមួយក្បាលនេះ និងជួយដល់មិត្តៗនិស្សិតដែលមានបំណងចង់ពង្រីកចំណេះដឹងផ្នែកការងារគ្រប់គ្រងវិស័យសំណង់គ្រប់ប្រភេទ។ ខ្ញុំបាទសូមអភ័យទោសជាមុនពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមិត្តអ្នកអានទាំងអស់នូវរាល់ចំណុចខ្វះខាតទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធដែលមិនត្រឹមត្រូវដោយអចេតនាព្រមទាំងទទួលយករាល់មតិរិះគន់ក្នុងន័យស្ថាបនា។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**១.លំនាំបញ្ហានៃការស្រាវជ្រាវ** ........ ១

**២.ចំណោទបញ្ហានៃការស្រាវជ្រាវ** ........ ២

**៣.គោលបំណងនៃការស្រាវជ្រាវ** ........ ២

**៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ** ........ ៣

**៥.សារៈសំខាន់នៃការស្រាវជ្រាវ** ........ ៣

**៦.វិធីសាស្ត្រនៃការស្រាវជ្រាវ** ........ ៣

**៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........ ៣

## ជំពូកទី១
## ទិដ្ឋភាពនៃការគ្រប់គ្រងសំណង់

**១.១. ទិដ្ឋភាពនៃការគ្រប់គ្រងមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន** ........ ៥

១.១.១. លិខិតអនុញ្ញាតសាងសង់ ឬលិខិតអនុញ្ញាតរុះរើ ........ ៥

១.១.២. ការគ្រប់គ្រងការដ្ឋានសាងសង់ ........ ៧

១.១.៣. ការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់ ........ ៨

១.១.៣.១. អ្នកសិក្សាគម្រោងប្លង់ ........ ៩

១.១.៣.២. ការប្រកបអាជីវកម្មក្នុងវិស័យសំណង់ ........ ១០

**១.២. ទិដ្ឋភាពនៃការគ្រប់គ្រងក្រោយច្បាប់ស្តីពីសំណង់ចូលជាធរមាន** ........ ១២

១.២.១. លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬលិខិតអនុញ្ញាតរុះរើ ........ ១២

១.២.២. ការគ្រប់គ្រងគម្រោងប្លង់ ........ ១៣

១.២.៣. ការគ្រប់គ្រងការងារសាងសង់ ឬរុះរើ ........ ១៤

១.២.៤. ការប្រើប្រាស់សំណង់ ........ ១៥

១.២.៤.១. សំណង់ដែលសាងសង់រួចរាល់មុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ........ ១៥
១.២.៤.២. សំណង់ដែលសាងសង់រួចរាល់ក្រោយច្បាប់ស្តីពីសំណង់ចូលជាធរមាន ........ ១៦
១.២.៥. សំណង់ដែលមានសភាពគ្រោះថ្នាក់ ........ ១៧
១.២.៥.១. ចំណាត់ថ្នាក់កម្រិតសភាពគ្រោះថ្នាក់នៃសំណង់ ........ ១៨
១.២.៥.២. ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់នៃសំណង់ ........ ១៩
១.២.៥.៣. នីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ........ ២១
១.២.៦. សំណង់ដែលសាងសង់ ឬរុះរើដោយគ្មាន ឬខុសពីលិខិតអនុញ្ញាត ........ ២២
១.២.៧. អធិការកិច្ចសំណង់ ........ ២២
១.២.៧.១. សមត្ថកិច្ចមន្ត្រីអធិការកិច្ចសំណង់ ........ ២៣
១.២.៧.២. សិទ្ធិ និងភារកិច្ចរបស់មន្ត្រីអធិការកិច្ចសំណង់ ........ ២៣
១.២.៧.៣. នីតិវិធីនៃការធ្វើអធិការកិច្ចសំណង់ ........ ២៤
១.២.៨. វិសមិតភាព ........ ២៧
១.២.៩. ការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់ ........ ២៨
១.២.៩.១. ការគ្រប់គ្រងអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ........ ២៨
១.២.៩.២. ការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ ........ ២៨

## ជំពូកទី២
## ទិដ្ឋភាពនៃការសាងសង់សំណង់

**២.១. នីតិវិធីនៃដំណាក់កាលមុនការសាងសង់** ........ ៣១
២.១.១. ការស្នើសុំលិខិតអនុញ្ញាតសាងសង់ ........ ៣១
២.១.២. ការស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ ........ ៣៣
២.១.៣. សមត្ថកិច្ចក្នុងការផ្តល់លិខិតអនុញ្ញាត និងស្ថាប័នជំនាញក្នុងវិស័យសំណង់ ........ ៣៥
២.១.៣.១. សមត្ថកិច្ចក្នុងការផ្តល់លិខិតអនុញ្ញាត ........ ៣៥
២.១.៣.២. តួនាទីស្ថាប័នជំនាញក្នុងវិស័យសំណង់ ........ ៣៨

**២.២. នីតិវិធីនៃដំណាក់កាលពេលសាងសង់ និងក្រោយពេលសាងសង់** ........ ៥៣
២.២.១. ការត្រួតពិនិត្យដំណើរការសាងសង់ ........ ៥៣

២.២.១.១. ប្រភេទ និងកម្រិតនៃអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ ...... ៥៣

២.២.១.២. នីតិវិធីនៃការផ្តល់អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ ...... ៥៦

២.២.១.៣. លក្ខខណ្ឌនៃការអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់ ...... ៥៨

២.២.២. ការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ...... ៥៩

២.២.៣. ការពិនិត្យសម្រេច និងបែបបទនៃការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ...... ៦០

២.២.៣.១. ការពិនិត្យសម្រេចលើឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ...... ៦០

២.២.៣.២. ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ...... ៦២

**សេចក្តីសន្និដ្ឋាន** ...... ៦៤

**អនុសាសន៍** ...... ៦៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជាយើង ជាប្រទេសមួយក្នុងចំណោមប្រទេសក្នុងពិភពលោក ក៏ដូចជានៅក្នុងតំបន់អាស៊ាន ដែលកំពុងតែលូតលាស់យ៉ាងល្អត្រចះត្រចង់គួរជាទីមោទនៈ។ ប្រទេសកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** រយៈពេល ៦នីតិកាលកន្លងមក កម្ពុជា ជាប្រទេសដែលកំពុងតែអភិវឌ្ឍន៍យ៉ាងលឿនពិតមែន តែមួយរយៈចុងក្រោយនេះ ក្នុងអំឡុងឆ្នាំ២០១៩ ដល់ឆ្នាំ២០២៤ វិស័យសំណង់នៅកម្ពុជាហាក់ដូចជាមានការកើនឡើងគួរឲ្យកត់សម្គាល់ផងដែរ។ ក្នុងនោះផងដែរវិស័យសំណង់កាន់តែរីកលូតលាស់មិនថាសំណង់អគារ ផ្ទះវីឡា ផ្ទះល្វែង បុរី កាន់តែរីកដុះដាល កាន់តែខ្ពស់ៗ កាន់តែទាមទារឲ្យមានការអនុវត្តច្បាប់ឲ្យមានភាពហ្មត់ចត់ ដើម្បីធានាឲ្យបាននូវស្តង់ដារបច្ចេកទេសធានាភាពរឹងមាំចីរភាពសុវត្ថិភាព និងសោភណភាពនៃសំណង់។ ការរៀបចំឲ្យមានលក្ខណៈស្តង់ដារបែបនេះទៅបានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំមន្ត្រីជំនាញដើម្បីត្រួតពិនិត្យគុណភាពនៃសំណង់តាមការចាត់តាំង និងជំនាញរៀងៗខ្លួន ជាពិសេសងាយស្រួលចំពោះវិនិយោគិនដែលមកវិនិយោគវិស័យសំណង់ផងដែរ។ មិនតែប៉ុណ្ណោះដើម្បីឲ្យកាន់តែមានសុវត្ថិភាព និងភាពជឿទុកចិត្តខ្ពស់ពីសំណាក់អ្នកប្រើប្រាស់អគារ និងអ្នកស្ថាបនាសំណង់ និងស្របតាមបដិវត្តឧស្សាហកម្មទី៤ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំច្បាប់ស្តីពីសំណង់មួយដែលត្រូវបានប្រកាសឲ្យប្រើកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលកំណត់នូវបទប្បញ្ញត្តិបច្ចេកទេស វិធាន និងនីតិវិធីក្នុងការគ្រប់គ្រងវិស័យសំណង់នៅកម្ពុជា។

ចំពោះការប្រកបរបរប្រចាំថ្ងៃក្នុងវិស័យសំណង់វិញ យើងសង្កេតឃើញហើយថាមានភាពខ្វះចន្លោះនៅឡើយ នេះក៏ដោយសារតែប្រជាជនយើងភាគរយច្រើនមិនទាន់យល់ច្បាស់ពីបទដ្ឋានគតិយុត្តនានាដែលរាជរដ្ឋាភិបាលក៏ដូចជាក្រសួងសាមីបានកំណត់។ ដោយសារតែភាពខ្វះចន្លោះលើចំណេះដឹងផ្នែកសំណង់បូករួមនឹងការធ្វេសប្រហែសក្នុងបច្ចេកទេសដែលជាហេតុនាំអោយមានការពិបាកក្នុងការរៀបចំវិស័យសំណង់ ក៏ដូចជាការគ្រប់គ្រងការសាងសង់នៅក្នុងប្រទេស។

យោងតាមភាពជាក់ស្តែងក្នុងប្រទេសកម្ពុជាបញ្ហាសំណង់អគារផ្សេងៗដែលបន្សល់មកពីសម័យសង្គមរាស្ត្រនិយម សម័យសាធារណៈរដ្ឋខ្មែរ និងសម័យក្រោយៗមកទៀតដែលរងគ្រោះដោយសារសង្គ្រាមហើយមានសភាពទ្រុឌទ្រោមមកទល់នឹងបច្ចុប្បន្ន។ ដោយសារតែសភាពបែបនេះធ្វើឲ្យការកើតឡើងនូវគ្រោះថ្នាក់មួយចំនួន និងបាត់សោភ័ណភាពនៃទីក្រុងផងដែរនោះ ក្រសួងស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងរៀបចំដែនដី នគរូប-នីយកម្ម និងសំណង់ បានចាត់អង្គភាពជំនាញតាមនាយកដ្ឋាន មន្ទីរជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិចុះ

អន្តរាគមពន្យល់ណែនាំដល់អ្នកដែលរស់នៅឲ្យមានការប្រែនូវសំណង់ឡើងវិញឲ្យស្របទៅតាមបទដ្ឋានគតិយុត្ត ដើម្បីជៀសវាង និងការពារដល់អាយុជីវិតខ្លួនពីការគ្រោះថ្នាក់ដែលបង្កពីសំណង់ដោយប្រធានសក្តិណាមួយ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដូចដែលបានឃើញហើយថា កាលពីច្បាប់ស្តីពីសំណង់ មិនទាន់បានចូលជាធរមាន ការគ្រប់គ្រងលើសំណង់អនាធិបតេយ្យ សំណង់ដែលគ្មានស្តង់ដារតែងតែកើតមានជាបន្ត។ កត្តាអស់ទាំងនេះជាចំណុចខ្សោយនៃវិធានការទប់ស្កាត់ដោយហេតុថាមិនមានលិខិតបទដ្ឋានច្បាប់ណាមួយជាក់លាក់ចំគោលដៅដើម្បីអន្តរាគមន៍លើបញ្ហានោះ។ ទន្ទឹងនឹងនេះ បើយើងដាក់បន្ទុកលើអាជ្ញាធរក្នុងមូលដ្ឋាន ក៏ដូចជាក្នុងតំបន់ក៏មិនត្រឹមត្រូវដែរ ព្រោះថាមិនអាចចោទប្រកាន់គេថាខុសច្បាប់ដោយមិនទាន់មានច្បាប់សំអាងច្បាស់លាស់។ ដើម្បីឲ្យមានភាពល្អឥតខ្ចោះ ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងត្រូវជំនាញត្រូវតែចេញបទប្បញ្ញត្តិមួយសម្រាប់អនុវត្តឲ្យត្រូវទិសដៅផងដែរ។

លើសពីនេះដើម្បីជាការយល់ដឹងឲ្យកាន់តែយល់ច្បាស់អំពីវិស័យសំណង់ យើងត្រូវដឹងថា៖

- ទិដ្ឋភាពនៃការគ្រប់គ្រងវិស័យសំណង់មានរូបភាពបែបណាខ្លះ?
- ទិដ្ឋភាពនៃការសាងសង់សំណង់មានរូបភាពបែបណាខ្លះ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ស្ថិតនៅក្នុងរង្វង់នៃការសិក្សាស្រាវជ្រាវប្រធានបទមួយនេះ គឺត្រូវបានសិក្សាយ៉ាងសំខាន់ទៅលើគោលការណ៍ដែលច្បាប់ស្តីពីសំណង់ឆ្នាំ២០១៩ នៃព្រះរាជាណាចក្រកម្ពុជាបានចែងកំណត់ និងបទដ្ឋានពាក់ព័ន្ធមួយចំនួនទៀតដែលទើបតែចូលជាធរមានថ្មី ព្រោះថាវាជាកាតាលីករសំខាន់ណាស់ក្នុងការជំរុញឲ្យវិស័យសំណង់នៅកម្ពុជាមានគុណភាព ចីរភាព និងសោភ័ណភាព។ នៅក្នុងនោះផងដែរ ការសិក្សាស្រាវជ្រាវនេះបាន ធ្វើការបើកកកាយបទដ្ឋានច្បាប់នានាដែលមានមុនច្បាប់ស្តីពីសំណង់ឆ្នាំ២០១៩ដែលនិយាយពីការរៀបចំទឹកដី រៀបចំដែនដីក្នុងប្រទេស។ លើសពីនេះទៀតគោលគំនិតដ៏សំខាន់បន្ថែមទៀតនោះខ្ញុំនឹងធ្វើការបើកបង្ហាញពីសកម្មភាពនានា និងការចាត់វិធានការអនុវត្តច្បាប់លើសំណង់ដែលគ្មានការអនុញ្ញាត ឬលិខិតអនុញ្ញាតដែលផ្តល់ដោយអាជ្ញាធរពាក់ព័ន្ធ ឬក្រសួងសាមី ដោយមើលឃើញថាពីមុនមកតែងមានសំណង់អគារបាក់រលំបង្កគ្រោះថ្នាក់នាំឲ្យបាត់បង់ជីវិតមនុស្ស ខូចខាតទ្រព្យសម្បត្តិសាធារណៈ ឯកជន ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធផងដែរ។ ដូចដែលបានដឹងទាំងអស់គ្នាហើយថាកាលពីឆ្នាំ២០១៩ កន្លងទៅមានការបាក់អគារមួយនៅក្រុងព្រះសីហនុដែលបានសម្លាប់ជីវិតមនុស្ស១៧នាក់ និង២៤បានរងរបួស ដែលបញ្ហានេះកើតចេញពីកំហុសបច្ចេកទេសសាងសង់។

សរុបមកវិញគោលបំណងដែលបានយកមកសិក្សាស្រាវជ្រាវនេះ គឺដើម្បីបានស្វែងយល់បន្ថែមអំពីសារសំខាន់នៃច្បាប់សំណង់ពីក្រសួងដែលពាក់ព័ន្ធនឹងវិស័យសំណង់ហើយមិនតែប៉ុណ្ណោះនោះទេ ការស្រាវជ្រាវ

មួយនេះជាវណ្ណៈកម្មមួយសម្រាប់ជាជំនួយដល់និស្សិត ដែលមានបំណងសិក្សាស្វែងយល់អំពីស្ថានភាពនៃការសាងសង់ និងនីតិវិធីក្នុងការគ្រប់គ្រងការងារបច្ចេកទេសនៃសំណង់។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវមួយនេះ មានដែនកំណត់មួយគឺ ផ្តោតទៅលើការសិក្សាទាក់ទងនឹងវិស័យសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់ស្តីពីសំណង់ឆ្នាំ២០១៩ និងបទប្បញ្ញត្តិមួយចំនួនដែលពាក់ពាក់ព័ន្ធដូចជាលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតរុះរើសំណង់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលមានជាធរមានមុនច្បាប់សំណង់ចូលជាធរមានជាដើម។ ការសិក្សាស្រាវជ្រាវនេះមិនបានសិក្សាទាំងមូលទៅលើប្រភពច្បាប់នៃការសាងសង់ពីសម័យព្រះរាជាណាចក្រកម្ពុជាទី១ ឬសម័យសង្គមរាស្ត្រនិយមនោះទេផ្តោតសំខាន់ក្នុងពេលបច្ចុប្បន្ននេះតែម្តង។ ហើយដែនកំណត់នៃការស្រាវជ្រាវវិញនោះ ខ្ញុំចាប់ផ្តើមធ្វើការស្រាវជ្រាវចាប់ពីថ្ងៃទី០៨ មេសា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវមួយនេះមានអត្ថប្រយោជន៍ជាឯកសារជំនួយស្មារតី ជាពុទ្ធិ និងពង្រីកវិសាលភាពចំណេះដឹង ក៏ដូចជាជំនួយដល់ធនធានក្នុងការបំពេញភារកិច្ចក្នុងការចាប់យកវិជ្ជាជីវៈជាអ្នកម៉ៅការសាងសង់ ឬជាមន្ត្រីក្នុងការត្រួតពិនិត្យសំណង់។ ពិសេសមិត្តអ្នកសិក្សាអាចស្វែងយល់បានអំពីវិធី ឬនីតិវិធីតាមដំណាក់កាលនៃសំណង់ដោយយល់ពីរបៀបមុនសាងសង់ ពេលសាងសង់ និងក្រោយពេលសាងសង់។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងនាមជានិស្សិតដែលជាអ្នកសិក្សាស្រាវជ្រាវមួយរូបនូវឯកសារយកមកធ្វើជាគោល និងសម្រាប់យកមកធ្វើការបកស្រាយនៅក្នុងការសារណាបញ្ចប់ការសិក្សានេះ ខ្ញុំបានធ្វើការសិក្សា និងដកស្រង់នូវអត្ថន័យខ្លឹមសារដែលជាប់ពាក់ព័ន្ធចេញពីប្រភពឯកសារផ្សេងៗដោយមានមូលដ្ឋានច្បាស់លាស់រួមមានច្បាប់រដ្ឋ អនុក្រឹត្យរបស់រាជរដ្ឋាភិបាល ប្រកាសសាមីក្រសួង ព្រមទាំងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលជាប់ពាក់ព័ន្ធទៅនឹងវិស័យសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បន្ថែមលើសពីនេះផងដែរនោះ សារណាមួយនេះបានស្តែងចេញពីការយកចិត្តទុកដាក់ណែនាំដ៏ខ្ពង់ខ្ពស់ពីសំណាក់សាស្ត្រាចារ្យណែនាំ ក៏ដូចជាខ្លួនឯងខិតខំព្យាយាមធ្វើយ៉ាងណាសរសេរ និងស្រាវជ្រាវប្រកបដោយការយកចិត្តទុកដាក់ជាមួយនឹងប្រធានបទសារណានេះ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ទំហំនៃការស្រាវជ្រាវ និងចងក្រងសរសេរសារណានេះ ដើម្បីឲ្យមានភាពងាយស្រួល និងច្បាស់លាស់អំពីការគ្រប់គ្រងវិស័យសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ខ្ញុំនឹងធ្វើការបែងចែករចនាសម្ព័ន្ធស្រាវជ្រាវជាពីរជំពូកគឺៈ

ជំពូកទី១៖ ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងសំណង់ ដែលធ្វើការនិយាយរៀបរាប់ពន្យល់អំពីនៃនីតិវិធីនៃការគ្រប់គ្រង់សំណង់ទាំងមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន និងនីតិវិធីក្រោយពេលច្បាប់ស្តីពីសំណង់ឆ្នាំ២០១៩ចូលជាធរមាន។

ជំពូកទី២៖ ទិដ្ឋភាពនៃការសាងសង់សំណង់ ដែលនឹងត្រូវការបកស្រាយអំពីនីតិវិធីនៃការមុនការសាងសង់សំណង់ នីតិវិធីពេលដែលកំពុងសាងសង់ និងនីតិវិធីក្រោយពេលសាងសង់សំណង់រួចរាល់រហូតដល់ប្រើប្រាស់សំណង់ ឬសំណង់ត្រូវបានដាក់សម្ពោធជាផ្លូវការ។

# ជំពូកទី១
# និន្នាការនៃការគ្រប់គ្រងសំណល់

# ជំពូកទី១
# ទិដ្ឋភាពនៃការគ្រប់គ្រងសំណង់

## ១.១. ទិដ្ឋភាពនៃការគ្រប់គ្រងមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន

នៅក្នុងប្រទេសកម្ពុជាយើងមានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានធ្វើការបែងចែកការគ្រប់គ្រងវិស័យសំណង់ជាពីរថ្នាក់រួមមានការគ្រប់គ្រងថ្នាក់ជាតិ ឬក្រសួងស្ថាប័ន និងថ្នាក់ក្រោមជាតិ ឬជាមន្ទីរ។ ការធ្វើការបែងចែកបែបនេះមានភាពងាយស្រួលសម្រាប់មន្ត្រីជំនាញ ក៏ដូចជាសម្រាប់អ្នកវិនិយោគ និងសម្រាប់អ្នកសាងសង់សំណង់ ហើយជាពិសេសនោះសម្រាប់មន្ត្រីជំនាញបច្ចេកទេសសំណង់ក្នុងការក្តោបក្តាប់ទិន្នន័យការងារសាងសង់សំណង់ក្នុងតំបន់ និងលើសពីនេះទៀតនោះដើម្បីបានចូលទៅក្បែរជាមួយប្រជាពលរដ្ឋដើម្បីពន្យល់អំពីសិទ្ធិរបស់ពួកគាត់ក្នុងការសាងសង់សំណង់ឲ្យបានត្រឹមត្រូវទៅតាមបទដ្ឋានច្បាប់ជាធរមាន។

ដើម្បីសិក្សាស្វែងយល់ចំណុចខាងឲ្យកាន់តែច្បាស់ថា ទិដ្ឋភាពការគ្រប់គ្រងមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន តើមានការគ្រប់គ្រងលើកិច្ចការងារអ្វីខ្លះពាក់ព័ន្ធនឹងសំណង់? បន្តិចទៀតយើងនឹងសិក្សាលើចំណុចទាំងអស់នោះ។

### ១.១.១. លិខិតអនុញ្ញាតសាងសង់ ឬលិខិតអនុញ្ញាតរុះរើ

លិខិតអនុញ្ញាតសាងសង់ គឺជាលិខិតមួយដែលមានអត្ថប្រយោជន៍យ៉ាងខ្លាំងសម្រាប់ការងារសាងសង់ ហើយក៏ជាលិខិតដ្ឋានគតិយុត្តមួយដែលបង្ហាញពីគ្រឹះស្របច្បាប់សម្រាប់ការងារសាងសង់សំណង់ បានសេចក្តីថាប្រជាពលរដ្ឋគ្រប់រូបរួមទាំងរូបវន្តបុគ្គល ឬបុគ្គលសាធារណៈ និងឯកជនមានសិទ្ធិពេញលេញក្នុងការសាងសង់សំណង់គ្រប់ប្រភេទនៅលើដីធ្លីដែលជាកម្មសិទ្ធិស្របច្បាប់របស់ខ្លួនដែលមានការការពារ និងទទួលស្គាល់ដោយអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់នេះ។[1] រាល់ការសាងសង់ក្នុងទីក្រុង និងទីប្រជុំជនត្រូវមានលិខិតអនុញ្ញាតសាងសង់។[2] នេះបង្ហាញឲ្យឃើញពីតម្លាភាពនៃ និងគុណភាពនៃការអនុវត្តច្បាប់ត្រង់ថា សាងសង់ក៏ត្រូវមានច្បាប់អនុញ្ញាត រីឯរុះរើក៏ត្រូវមានច្បាប់អនុញ្ញាតឲ្យរុះរើដូចគ្នា ប៉ុន្តែក្នុងករណីខ្លះដែលលើកលែងផងដែរដោយពុំចាំបាច់មានលិខិតអនុញ្ញាតនោះទេដូចជាការសាងសង់នូវសំណង់តូចៗ ជួសជុល ឬរុះរើនូវសំណង់ដែលតូចៗជាដើម ដើម្បីជៀសវាងការខាតបង់ពេលវេលារបស់ប្រជាពលរដ្ឋ។

មិនមែនរាល់ការងារសាងសង់សុទ្ធតែតម្រូវឲ្យមាន ឬទាមទារឲ្យមានលិខិតអនុញ្ញាតសាងសង់នោះទេ ប៉ុន្តែដើម្បីធានាដល់សុវត្ថិភាពសាធារណៈ និងការការពារដីធ្លីសាធារណៈសម្រាប់រៀបចំទីក្រុង ឬមួយទីប្រជុំជនឲ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

---

[1] ដកស្រង់ចេញពីឯកសារស្តីពីលិខិតអនុញ្ញាតសាងសង់ ទំព័រ១៣១

[2] មាត្រា២ នៃអនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី១៩ ធ្នូ ១៩៩៧

ជាក់ស្តែងសំណង់ដែលពុំចំណុះក្រោមលិខិតអនុញ្ញាតសាងសង់រួមមានដូចខាងក្រោម៖[3]

- សំណង់ដែលជាលំនៅឋានរបស់ប្រជាពលរដ្ឋដែលស្ថិតនៅទីជនបទ ឬតំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និងឆ្ងាយពីតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌជាតិ តំបន់រក្សាទុកការពារ ដោយពុំគិតពីទំហំ ឬសម្ភារៈសំណង់ប្រើប្រាស់ឡើយ។
- ការជួសជុល និងថែទាំរក្សាទាំងឡាយណាដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬទិដ្ឋភាពសំណង់ លើកលែងតែការជួសជុលនោះអាចបណ្តាលឲ្យប៉ះពាល់ដល់អ្នកជិតខាង។
- បណ្តាសំណង់ដូចជា ទីសក្ការៈបូជា សាលាសំណាក់សាធារណៈ បណ្តាការិយាល័យរបស់រដ្ឋសម្រាប់សេវាសាធារណៈដែលរដ្ឋជាម្ចាស់កិច្ចការ គឺគ្រាន់តែជូនដំណឹងអំពីគម្រោងសាងសង់ទៅអាជ្ញាធរមូលដ្ឋាន។

រីឯការជួសជុល ឬការរុះរើវិញ សំដៅដល់ការសាងសង់សារជាថ្មី ការពង្រីក និងការសាងសង់បន្ថែមពីលើសំណង់ចាស់ ឬសំណង់ដែលមានស្រាប់។

ការរុះរើ ឬការសាងសង់បន្ថែមទៅលើសំណង់ដែលមានស្រាប់តម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់ផងដែរ ប្រសិនបើការងារទាំងអស់នោះកែប្រែ ជួសជុល កែប្រែទៅលើ៖[4]

- ការប្រើប្រាស់ផ្ទៃករបស់អគារ
- ទិដ្ឋភាពនៃអគារ
- ការធ្វើបង្គន់អនាម័យ និងការបន្តភ្ជាប់ទៅបំពង់លូ
- ការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់ តភ្ជាប់ទៅបំពង់លូ
- បង្កើនផ្ទៃក្រឡាកម្រាលសំណង់
- កន្លែងទទួលសាធារណៈជន
- ទំរង់ដី(ចាក់ដីបំពេញ ជីកយកដីចេញ ប្តូរប្រភេទដីស្រែចំការជាដីសាងសង់) ឬប៉ះពាល់ខ្លាំងដល់ទិដ្ឋភាពទីដ្ឋានណាមួយដូចជាលុបបំបាត់បឹង ឬប្រឡាយបង្ហូរទឹក ឬផ្នែកណាមួយនៃប្រព័ន្ធបង្ហូរទឹកចេញ ការកាប់ដើមឈើដែលមានស្រាប់។ល។

[3] មាត្រា៣ នៃអនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី១៩ ធ្នូ ១៩៩៧

[4] មាត្រា២ នៃអនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី១៩ ធ្នូ ១៩៩៧

### ១.១.២. ការគ្រប់គ្រងការដ្ឋានសាងសង់

ដើម្បីចូលរួមក្នុងការអភិវឌ្ឍវិស័យសំណង់ប្រកបដោយសុវត្ថិភាព និងចីរភាពទាមទារឲ្យក្រុមហ៊ុនសាង-សង់ក៏ដូចជាម្ចាស់ការដ្ឋានសំណង់គិតគូរអំពីសណ្តាប់ធ្នាប់សាធារណៈ និងដើម្បីសុវត្ថិភាពក្នុងការដ្ឋានសំណង់តាមរយៈការគ្រប់គ្រងការដ្ឋានសាងសង់ដោយអនុលោមទៅតាមស្តង់ដារបច្ចេកទេស និងតាមច្បាប់ជាធរមាន។

ផ្អែកតាមប្រកាសលេខ៣២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់។

ដូចនេះរាល់ការដ្ឋាននីមួយៗ អាចដំណើរការទៅបានលុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន ដែលលិខិតអនុញ្ញាតបើកការដ្ឋាននេះត្រូវស្នើសុំទៅអគ្គនាយកដ្ឋានសំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ស្របតាមសមត្ថកិច្ចចេញលិខិតអនុញ្ញាតសាងសង់ ដោយភ្ជាប់ជាមួយសំណុំឯកសារដើម្បីស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន មានពាក្យស្នើសុំរបស់ម្ចាស់សំណង់ លិខិតអនុញ្ញាតសាងសង់ រួមទាំងប្លង់ស្ថាបត្យកម្មដែលបានអនុញ្ញាត និងប្លង់គ្រឿងផ្គុំសំណង់។[5]

ករណីដែលបើកការដ្ឋានដោយពុំមានលិខិតអនុញ្ញាតសាងសង់ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្អាកការងារការដ្ឋាននោះជាបណ្តោះអាសន្ន ហើយបើសិនជាម្ចាស់សំណង់នៅតែបន្តការងារសាងសង់ទៀត អាជ្ញាធរមានសមត្ថកិច្ចនឹងធ្វើការដកហូតសម្ភារៈសាងសង់នោះហើយប្តឹងទៅតុលាការ។[6] ចំពោះការដ្ឋានដែលត្រូវបានផ្អាកជាបណ្តោះអាសន្ននោះអាចដំណើរការថ្មីវិញបានករណីដែលម្ចាស់សំណង់ស្នើសុំបំពេញបែបបទឡើងវិញដោយធ្វើការដាក់ពាក្យស្នើសុំលិខិតបើកការដ្ឋានសាងសង់ ដោយបំពេញលក្ខខណ្ឌគ្រប់គ្រាន់ទៅតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច។[7]

ម្យ៉ាងវិញទៀតការដ្ឋានសំណង់នីមួយៗត្រូវ៖[8]

- តម្កល់ជាប្រចាំនូវលិខិតបើកការដ្ឋាន គំនូរប្លង់តាមមុខជំនាញការងារសំណង់ ផែនការអនុវត្តការងារក្នុងដំណាក់កាលនីមួយៗនៃការសាងសង់ និងឯកសារពាក់ព័ន្ធទុកសម្រាប់ឲ្យភ្នាក់ងារសំណង់តាមដានពិនិត្យ

[5] ប្រការ៣ថ្មី នៃប្រកាសលេខ៩៣ ប្រក.ដនស/អសណ ស្តីពី ការកែសម្រួលប្រការ២ និងប្រការ៣ នៃប្រកាសលេខ៣២ប្រក/សណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ ចុះថ្ងៃទី២៦ មីនា ២០០៩

[6] ប្រការ១៤ នៃប្រកាសលេខ៣២ ប្រក/សណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ ចុះថ្ងៃទី២០ មីនា ២០០១

[7] ប្រការ១៥ នៃប្រកាសលេខ៣២ ប្រក/សណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ ចុះថ្ងៃទី២០ មីនា ២០០១

[8] ប្រការ៤ នៃប្រកាសលេខ៣២ ប្រក/សណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ ចុះថ្ងៃទី២០ មីនា ២០០១

- មានអ្នកបច្ចេកទេសសំណង់សម្រាប់ទទួលខុសត្រូវក្នុងការសាងសង់ ហើយមានកាតព្វកិច្ចដើម្បីឆ្លើយបំភ្លឺផ្តល់ព័ត៌មានជូនដល់ភ្នាក់ងារមានសមត្ថកិច្ចត្រួតពិនិត្យ
- ដាក់ផ្ទាំងគំនូរសំណង់ដែលមានឈ្មោះសំណង់នៃអគារត្រូវបានសាងសង់ ក្រុមហ៊ុនសំណង់ ម្ចាស់សំណង់ ស្ថាបត្យករ វិស្វករ ផ្ទៃក្រឡាសំណង់ លេខទូរស័ព្ទទាក់ទង និងកន្លែងការដ្ឋានតាំងនៅ
- មានភ្លើងដើម្បីបំភ្លឺ និងប្រដាប់សម្រាប់ពន្លត់អគ្គីភ័យជាប្រចាំ
- បន្ថយការរំខានដោយស្នូរសំឡេង ផ្សែង ធូលី និងផលប៉ះពាល់ដទៃទៀតឲ្យស្ថិតនៅក្នុងកម្រិត និងពេលវេលាមួយដែលអ្នករស់នៅជុំវិញការដ្ឋានអាចទទួលបាន។

នៅក្នុងដំណើរការការដ្ឋានត្រូវមានការហ៊ុំព័ទ្ធដោយរបងដែលមានកម្ពស់២ម៉ែត្រយ៉ាងទាបបំផុត ហើយមិនអនុញ្ញាតឲ្យធ្វើលើចិញ្ចើមថ្នល់។ ក្នុងករណីទីតាំងការដ្ឋានចង្អៀត ការធ្វើរបងបិទបាំងបណ្តោះអាសន្នលើចិញ្ចើមផ្លូវសាធារណៈត្រូវរក្សាឲ្យមានចន្លោះផ្លូវដើរលើចិញ្ចើមថ្នល់ និងធ្វើរបាំងការពារតាមទំហំដែលអនុញ្ញាត ឬកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។ ចំពោះសំណង់ដែលមានកម្ពស់ចាប់ពី៥ម៉ែត្រឡើងទៅ ត្រូវហ៊ុមព័ទ្ធដោយក្រណាត់កៅស៊ូ ឬសំណាញ់សុវត្ថិភាព។[9] ចំពោះសំណង់ដែលត្រូវប្រើប្រាស់គ្រឿងចក្របរិក្ខារលើកស្ទូចហើយអាចធ្វើឲ្យប៉ះពាល់ដល់ដំណើរការលើផ្លូវសាធារណៈ ម្ចាស់សំណង់ត្រូវសុំការអនុញ្ញាតពីអាជ្ញាធរដែនដីដើម្បីបិទផ្លូវសម្រាប់ការដំឡើងគ្រឿងផ្គុំសំណង់ ហើយធ្វើផ្លូវវាងជាបណ្តោះអាសន្ន និងបំពាក់ភ្លើងសញ្ញាសម្គាល់លើផ្លូវដែលបិទដើម្បីសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈនៅពេលយប់។[10]

លើសពីនេះការដ្ឋានត្រូវមានសណ្តាប់ធ្នាប់ និងអនាម័យជាប្រចាំតាំងពីពេលចាប់ផ្តើមដំណើរការរហូតដល់បញ្ចប់ការដ្ឋាន។ ម្ចាស់សំណង់ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំសណ្តាប់ធ្នាប់ និងអនាម័យដែលបណ្តាលមកពីការទុកដាក់សម្ភារៈ ឬកាកសំណល់ឲ្យប៉ះពាល់ផ្លូវសាធារណៈ ឬហូរធ្លាក់ចូលក្នុងអាងត្រួតពិនិត្យនៃបណ្តាលូ និងប្រឡាយទឹក។[11]

### ១.១.៣. ការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់

ការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញនូវប្រកាសមួយចំនួនដែលបែងចែកដាច់ដោយឡែកពីគ្នាដែលរួមមាន អ្នកវិជ្ជាជីវៈសិក្សាគម្រោងប្លង់ និងអ្នកប្រកបអាជីវកម្មក្នុងវិស័យសំណង់។ ហើយការអនុវត្តប្រកាសមានសេចក្តីលម្អិតបែបណានោះយើងនឹងសិក្សាដូចតទៅ។

[9] ប្រការ៥ នៃប្រកាសលេខ៣២ ប្រក/សណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ ចុះថ្ងៃទី២០ មីនា ២០០១

[10] ប្រការ៨ នៃប្រកាសលេខ៣២ ប្រក/សណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ ចុះថ្ងៃទី២០ មីនា ២០០១

[11] ប្រការ៦ នៃប្រកាសលេខ៣២ ប្រក/សណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ ចុះថ្ងៃទី២០ មីនា ២០០១

#### ១.១.៣.១. អ្នកសិក្សាគម្រោងប្លង់

អ្នកសិក្សាគម្រោងប្លង់ សំដៅដល់អ្នកវិជ្ជាជីវៈ ឬក្រុមហ៊ុន ឬអង្គភាពរដ្ឋ ដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្លង់ ឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីអនុវត្តការងារសិក្សាគម្រោងប្លង់។[12]

អ្នកសិក្សាគម្រោងប្លង់ សំដៅដល់រូបវន្តបុគ្គលដែលសិក្សាគម្រោងប្លង់ពាក់ព័ន្ធនឹងការសាងសង់ហើយមានសញ្ជាតិខ្មែរ ឬបរទេស។[13] រីការសិក្សាគម្រោងប្លង់ សំដៅដល់ការសិក្សាគម្រោងប្លង់ដែលពាក់ព័ន្ធនឹងការសាងសង់។[14] អ្នកសិក្សាគម្រោងប្លង់នេះអាចជាស្ថាបត្យករ ឬវិស្វករដែលធ្វើការសិក្សាគម្រោងប្លង់តាមមុខជំនាញរបស់ខ្លួន។ ជាមួយគ្នានេះផងដែរដើម្បីអាចក្លាយខ្លួនទៅជារូបវន្តបុគ្គលសិក្សាគម្រោងប្លង់ពួកគេដាច់ខាតត្រូវបំពេញបែបបទស្នើសុំចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (នៅនាយកដ្ឋានសិក្សាគម្រោងប្លង់នៃអគ្គនាយកដ្ឋានសំណង់) ដើម្បីមានសិទ្ធិក្នុងការសិក្សាគម្រោងប្លង់សំណង់ផ្សេងៗ និងមានការទទួលស្គាល់ពីក្រសួងនូវបទពិសោធន៍នៃវិជ្ជាជីវៈដែលខ្លួនមាន។ ហើយក្រសួងមិនទទួលស្គាល់រាល់ការចុះហត្ថលេខាបញ្ជាក់លើរាល់ឯកសារគម្រោងប្លង់របស់ស្ថាបត្យករ ឬវិស្វករណាដែលមិនបានមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ទេ។[15]

រាល់រូបវន្តបុគ្គលដែលមានបំណង ឬកំពុងធ្វើការសិក្សាគម្រោងប្លង់នៅព្រះរាជាណាចក្រកម្ពុជា ទោះបីអនុញ្ញាតពីស្ថាប័នណាផ្សេងក៏ដោយ ក៏ត្រូវមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[16]

ចំពោះការចុះបញ្ជីរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ស្ថាបត្យករ ឬវិស្វករត្រូវមានលក្ខណៈសម្បត្តិដូចជា៖[17]

- មានសញ្ញាបត្រស្ថាបត្យករ ឬសញ្ញាបត្រវិស្វករ
- មានបទពិសោធន៍ការងារក្នុងមុខជំនាញ ដែលធ្លាប់បានអនុវត្តការងារសិក្សាគម្រោងប្លង់កន្លងមកនៅតាមបណ្តាអង្គភាព ស្ថាប័ន ក្រុមហ៊ុនឯកជន អង្គការនានា។ល។

---

[12] ប្រការ៣វាក្យខណ្ឌទី៧នៃប្រកាសលេខ១០៩ ដនស/ប្រ.ក/នី.ក ស្តីពីបែបបទនៃការងារត្រួតពិនិត្យ និងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម និងគម្រោងប្លង់គ្រឿងផ្គុំសំណង់ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១

[13] ប្រការ២ វាក្យខណ្ឌទី១ នៃប្រកាសលេខ១៩២ ប្រក.ដនស/អសណ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧

[14] ប្រការ២ វាក្យខណ្ឌទី២ នៃប្រកាសលេខ១៩២ ប្រក.ដនស/អសណ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧

[15] ប្រការ៣ នៃប្រកាសលេខ១៩២ ប្រក.ដនស/អសណ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧

[16] ប្រការ៤ នៃប្រកាសលេខ១៩២ ប្រក.ដនស/អសណ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧

[17] ប្រការ៥ នៃប្រកាសលេខ១៩២ ប្រក.ដនស/អសណ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧

- មានលិខិតបញ្ជាក់ការសិក្សា ឬវិញ្ញាបនបត្រផ្សេងៗនៃវគ្គបំពាក់បំប៉ន ឬបណ្ដុះបណ្ដាលបន្ថែមផ្នែកមុខជំនាញផ្ទាល់ខ្លួនប្រសិនបើមាន។

មួយទៀតចំពោះវិញ្ញាបនបត្រសិក្សាគម្រោងប្លង់របស់រូបវន្តបុគ្គលនេះទៀតសោតមានសុពលភាព ៣ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ។ ក្នុងរយៈពេល ៣០ថ្ងៃមុនផុតកំណត់សុពលភាព រូបវន្តបុគ្គលត្រូវដាក់ពាក្យសុំបន្តសុពលភាពសិក្សាគម្រោងប្លង់ សាជាថ្មីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[18] លើសពីនេះផងដែរនោះរូបវន្តបុគ្គលដែលទទួលបានវិញ្ញាបនបត្រសិក្សាគម្រោងប្លង់ នឹងអាចចូលរួមក្នុងសិក្ខាសាលា ឬមួយវគ្គបណ្ដុះបណ្ដាលនានាតាមការអញ្ជើញរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីលើកកម្ពស់សមត្ថភាព និងគុណភាពនៃវិជ្ជាជីវៈលើការងារជំនាញរបស់ខ្លួន។[19]

ម្យ៉ាងវិញចំពោះកម្រិតរបស់ស្ថាបត្យកម្មជារូបវន្តបុគ្គលសិក្សាគម្រោងប្លង់ស្ថាបត្យកម្ម និងវិស្វករដែលជារូបវន្តបុគ្គលសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់ ឬប្លង់វិស្វកម្មត្រូវបានកំណត់ទៅតាមបទពិសោធន៍ការងារក្នុងមុខជំនាញនីមួយៗក្នុងរយៈពេលដូចខាងក្រោម៖[20]

- កម្រិតទី១ មានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១០ឆ្នាំ
- កម្រិតទី២ មានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ឆ្នាំ
- កម្រិតទី៣ មានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៣ឆ្នាំ។

រាល់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់អាចសុំតម្លើងឋានៈកម្រិតរបស់ខ្លួន នៅពេលណាដែលរូបវន្តបុគ្គលនោះ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយការវាយតម្លៃក្នុងការតម្លើងឋានៈនេះ ត្រូវពិនិត្យសម្រេចដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[21] ហើយរូបវន្តបុគ្គលដែលប្រកបអាជីវកម្មសិក្សាគម្រោងប្លង់នេះទៀត-សោត ត្រូវបង់ពន្ធអាករតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[22]

### **១.១.៣.២. ការប្រកបអាជីវកម្មក្នុងវិស័យសំណង់**

ការប្រកបអាជីវកម្មក្នុងវិស័យសំណង់នេះ ក្នុងន័យទូលាយ ឬទិដ្ឋភាពទូទៅដែលបានឃើញសព្វថ្ងៃនេះ សំដៅដល់ក្រុមជាង ឬសហគ្រាសក្រុមហ៊ុន ឬរូបវន្តបុគ្គលដែលមានជំនាញបច្ចេកទេស ដែលធ្វើ ឬប្រកបវិជ្ជាជីវៈ ឬអាជីវកម្មក្នុងវិស័យសំណង់ក្នុងគោលបំណងស្វែងរកកម្រៃ។

---

[18] ប្រការ១៥ នៃប្រកាសលេខ១៩២ ប្រក.ដនស/អសណ ស្ដីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧

[19] ប្រការ១២ នៃប្រកាសលេខ១៩២ ប្រក.ដនស/អសណ ស្ដីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧

[20] ប្រការ៦ថ្មី នៃប្រកាសលេខ០៣៥ ស្ដីពីការកែសម្រួលប្រការ៦ នៃប្រកាសលេខ១៩២ ប្រក.ដនស/អសណ ស្ដីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០

[21] ប្រការ១៣ នៃប្រកាសលេខ១៩២ ប្រក.ដនស/អសណ ស្ដីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧

[22] ប្រការ១៤ នៃប្រកាសលេខ១៩២ ប្រក.ដនស/អសណ ស្ដីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧

ចំពោះសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ទាំងអស់ដែលធ្វើសកម្មភាពនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[23] ហើយសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ទាំងអស់ ដែលមានបំណងធ្វើអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ ត្រូវដាក់ពាក្យសុំប្រកបអាជីវកម្ម នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រីឯរូបវន្តបុគ្គល និងក្រុមជាងសំណង់វិញ ត្រូវដាក់ពាក្យសុំប្រកបអាជីវកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-រាជធានី។[24] មួយវិញទៀតចំពោះសហគ្រាស និងក្រុមហ៊ុនដែលមានលិខិតអនុញ្ញាតពីស្ថាប័នផ្សេងៗកន្លងមក ត្រូវដាក់ពាក្យសុំប្តូរយកលិខិតអនុញ្ញាតថ្មីពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ លើសពីនេះរូបវន្តបុគ្គល និងក្រុមជាងសំណង់ក៏ដូចគ្នា ត្រូវដាក់ពាក្យសុំប្តូរយកលិខិតថ្មីពីមន្ទីររៀបចំ-ដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-រាជធានី។[25]

ដោយឡែកច្បាប់អនុញ្ញាតដល់រាល់សហគ្រាស និងក្រុមហ៊ុនបរទេសដែលមានបំណងប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ឬផ្តល់យោបល់ ពិគ្រោះបច្ចេកទេស និងសាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផងដែរ ឯសហគ្រាស ឬក្រុមហ៊ុនបរទេសដែលកំពុងប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ផ្តល់យោបល់ពិគ្រោះបច្ចេកទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីមានលិខិតអនុញ្ញាតពីស្ថាប័នណាផ្សេងរួចហើយក៏ដោយ ក៏ត្រូវមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដូចគ្នា។[26] ហើយរាល់ការចុះបញ្ជី ការចេញលិខិតអនុញ្ញាត សហគ្រាស និងជាក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ រូបវន្តបុគ្គល និងក្រុមជាងសំណង់ ត្រូវបង់ពន្ធអាករផ្សេងៗ ស្របតាមការកំណត់នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[27]

ម្យ៉ាងវិញចំពោះលិខិតអនុញ្ញាតប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់មានសុពលភាព ៣ឆ្នាំ (បីឆ្នាំ) គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត។ ក្នុងរយៈពេល ៣០ថ្ងៃ(សាមសិបថ្ងៃ) មុនផុតកំណត់សុពលភាព

[23] ប្រការ១ នៃប្រកាសលេខ៧៥ ប្រក.ដ.ន.ស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩

[24] ប្រការ៥ នៃប្រកាសលេខ៧៥ ប្រក.ដ.ន.ស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩

[25] ប្រការ៦ នៃប្រកាសលេខ៧៥ ប្រក.ដ.ន.ស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩

[26] ប្រការ៨ នៃប្រកាសលេខ៧៥ ប្រក.ដ.ន.ស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩

[27] ប្រការ៩ នៃប្រកាសលេខ៧៥ ប្រក.ដ.ន.ស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩

សហគ្រាស និងក្រុមហ៊ុនប្រកបអាជីវកម្ម ឬធ្វើអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតសាជាថ្មីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ករណីដែលសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតនៃអាជីវកម្ម សហគ្រាស និងក្រុមហ៊ុនត្រូវធ្វើពាក្យសុំទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដោយគ្រាន់តែភ្ជាប់ជាមួយនូវលិខិតអនុញ្ញាតចាស់ និងបង្កាន់ដៃបង់ពន្ធអាករ ឬប័ណ្ណប៉ាតង់ប្រចាំឆ្នាំចុងក្រោយ។[28]

## ១.២. ទិដ្ឋភាពនៃការគ្រប់គ្រងក្រោយច្បាប់ស្តីពីសំណង់ចូលជាធរមាន

### ១.២.១. លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬលិខិតអនុញ្ញាតរុះរើ

បន្ទាប់ពីច្បាប់ស្តីពីសំណង់បានចូលជាធរមានកាលពីឆ្នាំ២០១៩មក បទប្បញ្ញត្តិបានចែងអំពីការសាង-សង់ ឬរុះរើសំណង់ដែលពុំចាំបាច់ត្រូវមានលិខិតអនុញ្ញាតសាងសង់ជាមុន ហើយក៏បែងចែកប្រភេទសំណង់មួយចំនួនទៀតដែលពុំតម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់ឡើយ។ ដោយឡែកច្បាប់ស្តីពីសំណង់បានចែងថា រាល់ការងារសាងសង់ ឬរុះរើត្រូវមានការអនុញ្ញាតជាមុនសិនដោយអាជ្ញាធរមានសមត្ថកិច្ច។[29] ក៏ប៉ុន្តែចំពោះការងារសាងសង់ ឬរុះរើសំណង់ផ្សេងៗក្នុងស្ថានភាពអាសន្ន ឬស្ថានភាពគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះ ឬការពារអាយុជីវិត ឬបង្ការមិនឲ្យមានការប៉ះពាល់ ឬខូចខាតធ្ងន់ធ្ងរដល់សុខភាព ឬទ្រព្យសម្បត្តិក្នុងស្ថានភាពអាសន្ន មិនតម្រូវឲ្យមានលិខិតអនុញ្ញាតជាមុនឡើយ។ ក្នុងរយៈពេល ៣០ថ្ងៃ(សាមសិប)ថ្ងៃយ៉ាងយូរក្រោយស្ថានភាពអាសន្នត្រូវបានបញ្ចប់ម្ចាស់សំណង់ដែលសាងសង់ ក្នុងភាពអាសន្នត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌ និងនីតិវិធី។ ចំពោះម្ចាស់សំណង់ដែលបានរុះរើក្នុងភាពអាសន្នវិញត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ច ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់។[30]

មួយវិញទៀតចំពោះការងារសាងសង់ ឬរុះរើដែលមានទំហំតូចដែលមិនប៉ះពាល់ដល់សន្តិសុខ មិនប៉ះ-ពាល់ដល់សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ លំនៅឋានដែលធ្វើអំពីឈើ ផ្ទះថ្មឈើពីលើ ផ្ទះតៀមធ្វើអំពីឈើ ឬថ្មនៅទីជនបទ ឬស្រែចំការ ដែលមិនប៉ះពាល់ដល់តំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ និងសំណង់ដែលបម្រើដល់សន្តិសុខជាតិ និងការពារជាតិ មិនតម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់ឡើយ។[31] ដោយឡែករាល់ការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់មិនតម្រូវឲ្យមាន

---

[28] ប្រការ១០ នៃប្រកាសលេខ១៦៦ ប្រក.ដនស/អសណ ស្តីពីការកែសម្រួលប្រការ៧ និងប្រការ១០ នៃប្រកាសលេខ៧៥ ប្រក/ដនស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧

[29] មាត្រា២៦ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[30] មាត្រា២៧ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[31] មាត្រា២៨ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

លិខិតអនុញ្ញាតសាងសង់ឡើយ ករណីដែលការងារនោះមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទម្ងន់ សោភណភាពខាងក្រៅ ឬមុខងារប្រើប្រាស់ទាំងមូល ឬផ្នែកណាមួយនៃសំណង់ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក៏ប៉ុន្តែក្នុងករណីនេះម្ចាស់សំណង់ត្រូវជូនដំណឹងជាមុនទៅកាន់អាជ្ញាធរដែលមានសមត្ថកិច្ច។[32]

### ១.២.២. ការគ្រប់គ្រងគម្រោងប្លង់

ស្របតាមច្បាប់ស្តីពីសំណង់ដែលទើបចូលជាធរមានកាលពីឆ្នាំ២០១៩រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ ឬរុះរើត្រូវចុះហត្ថលេខាទទួលខុសត្រូវដោយអ្នកសិក្សាគម្រោងប្លង់ដែលទទួលបាន និងមានអាជ្ញាបណ្ណ ឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីជាការបញ្ជាក់ពីភាពត្រឹមត្រូវស្របតាមស្តង់ដារបច្ចេកទេស។[33] ចំណែកឯរាល់គម្រោងប្លង់ដែលប្រើប្រាស់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ ឬរុះរើត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិរៀបចំដែនដី និងនគរូបនីយកម្ម។ ហើយគម្រោងប្លង់ដែលប្រើប្រាស់សម្រាប់សាងសង់ ឬរុះរើសំណង់គ្រប់ប្រភេទត្រូវរៀបចំឲ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាសម្រាប់ជនពិការភាពជាអាទិ៍ ផ្លូវ និងជម្រាលសម្រាប់ផ្លាស់ទី និងរួមទាំងឧបករណ៍ធ្នាក់ដៃ ជណ្តើរយន្ត បន្ទប់អនាម័យ ចំណតយានយន្ត ពិសេសសម្រាប់ជនពិការ និងស្លាកសញ្ញាសម្គាល់នានា ដោយលើកលែងតែសំណង់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។[34]

រាល់ការងារសាងសង់ ឬរុះរើដែលតម្រូវឲ្យមានលិខិតអនុញ្ញាតម្ចាស់សំណង់ត្រូវធានាអនុវត្តឲ្យបានត្រឹមត្រូវតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។ មុនការអនុវត្តការងារសាងសង់ ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឲ្យកែសម្រួលគម្រោងប្លង់ដែលបានទទួលការយល់ព្រមរួចហើយ ហើយការកែសម្រួលគម្រោងប្លង់នេះត្រូវធ្វើឡើងតាមរយៈលិខិតអនុញ្ញាតកែសម្រួលគម្រោងប្លង់តាមលក្ខខណ្ឌ និងនីតិវិធីត្រូវកំណត់ដោយអនុក្រឹត្យ។[35] ជាពិសេសផងដែរនោះរាល់ស្នាដៃរបស់អ្នកសិក្សាគម្រោងប្លង់ដែលមានលក្ខណៈដើមទាំងមូល ឬមួយដោយផ្នែកដែលបានទទួលការយល់ព្រមពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច តាមរយៈលិខិតអនុញ្ញាតសាងសង់ត្រូវបានការពារពីការលួចចម្លងស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។[36]

[32] មាត្រា២៩ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[33] មាត្រា៣២ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[34] មាត្រា៣៣ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[35] មាត្រា៣៤ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[36] មាត្រា៣៥ វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

មួយវិញទៀតគម្រោងប្លង់មួយមិនអាចយកទៅអនុវត្តនៅទីតាំងផ្សេងទៀតដោយគ្មានការអនុញ្ញាតពីអ្នកសិក្សាដែលបានចុះហត្ថលេខាលើគម្រោងប្លង់នោះ និងម្ចាស់សំណង់បានឡើយ។ យ៉ាងណាមិញចំពោះរាល់គម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មនៅទីតាំងផ្សេងទៀតត្រូវបានហាមឃាត់។[37]

### ១.២.៣. ការគ្រប់គ្រងការងារសាងសង់ ឬរុះរើ

ការគ្រប់គ្រងការងារសងសង់ ឬរុះរើសំណង់វិញច្បាប់ស្តីពីសំណង់ឆ្នាំ២០១៩បានកំណត់ថា រាល់ការងារសាងសង់ ឬរុះរើត្រូវអនុវត្តដោយដោយអ្នកសាងសង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបានរាជធានី-ខេត្ត។ ចំណែកឯអ្នកសាងសង់វិញត្រូវតែមានអាជ្ញាបណ្ណជាគោលការណ៍សំខាន់ ប៉ុន្តែមានករណីដែលមិនចាំបាច់មានអាជ្ញាបណ្ណក៏បាន តែត្រូវបំពេញលក្ខខណ្ឌដូចជា ជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ការសាងសង់ ឬរុះរើសំណង់ដែលជាលំនៅឋានផ្ទាល់ខ្លួន និងការសាងសង់ ឬរុះរើសំណង់តាមជំនាញវិជ្ជាជីវៈរបស់ខ្លួន។[38]

ម្យ៉ាងវិញទៀតចំពោះអ្នកសាងសង់យើងកំណត់ថា អ្នកដែលសាងសង់ ឬរុះរើបាន គឺត្រូវមានអាជ្ញាបណ្ណដែលជាគោលការណ៍ទី១ ឬគោលការណ៍អាទិភាព។[39] អ្នកដែលសាងសង់ ឬអ្នកអនុវត្តការងារសំណង់ដែលមិនមែនជាម្ចាស់សំណង់ ត្រូវតែមានអាជ្ញាបណ្ណ។ ដូចនេះអ្នកដែលសាងសង់បានមាន៤(បួន)ប្រភេទ គឺទី១អ្នកវិជ្ជាជីវៈទី២គឺក្រុមហ៊ុន បន្ទាប់មកទី៣គឺជាងជំនាញ និងទី៤ចុងក្រោយគឺក្រុមជាង។ អ្នកទាំងអស់នេះទោះបីមិនមានអាជ្ញាបណ្ណ ក៏ត្រូវមានលិខិតអនុញ្ញាតដូចក្រុមជាងដែរ។ ដោយឡែកម្ចាស់សំណង់វិញ តម្រូវឲ្យមានលិខិតអនុញ្ញាតត្រូវផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ ឬរុះរើជូនអាជ្ញាធរមានសមត្ថកិច្ច។ ហើយរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសងសង់ ឬរុះរើត្រូវរៀបចំដោយអ្នកសាងសង់ និងមានការឯកភាពពីម្ចាស់សំណង់ផងដែរ។[40]

មួយវិញទៀតគួរបញ្ជាក់ផងដែរថា រាល់ការងារសាងសង់ ឬរុះរើត្រូវអនុវត្តតាមគម្រោងប្លង់ បទប្បញ្ញត្តិបច្ចេកទេសសំណង់ បទប្បញ្ញត្តិជាធរមានដទៃទៀតដែលពាក់ព័ន្ធនឹងវិស័យសំណង់ មិនតែប៉ុណ្ណោះត្រូវអនុវត្តតាមគម្រោងប្លង់ពិតមែន តែគម្រោងប្លង់នោះត្រូវតែជាគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។[41] នៅពេលដែលដំណើរការការដ្ឋាន រាល់ការងារសាងសង់ ឬរុះរើដែលតម្រូវឲ្យមានលិខិតអនុញ្ញាតត្រូវមានការត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យ និងបញ្ជាក់ដែលមានអាជ្ញាបណ្ណ ឬការ

---

[37] មាត្រា៣៥ វាក្យខណ្ឌទី២ និងទី៣ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[38] មាត្រា៣៦ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[39] មាត្រា៣៦ ដដែល នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[40] មាត្រា៤០ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[41] មាត្រា៣៧ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

អនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ហើយអ្នកត្រួតពិនិត្យ និងបញ្ជាក់ការងារសាងសង់ ឬរុះរើត្រូវធ្វើរបាយការណ៍ និងចេញលិខិតបញ្ជាក់ពីអនុលោមភាពនៃការងារតាមគម្រោងប្លង់ដែលបានយល់ព្រមដោយអាជ្ញាធរមានសមត្ថកិច្ច និងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។[42]

ប៉ុន្តែក្នុងករណីចាំបាច់ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធរដែលមានសមត្ថកិច្ចអាចចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីត្រួតពិនិត្យការងារសាងសង់ ឬរុះរើ ហើយម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ បុគ្គលដែលពាក់ព័ន្ធការងារសាងសង់ ដោយរាប់បញ្ចូលទាំងអ្នកអភិវឌ្ឍន៍អចលនវត្ថុ អ្នកសាងសង់ និង អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ ត្រូវផ្តល់កិច្ចសហការដល់មន្ត្រីត្រួតពិនិត្យសំណង់។ មួយវិញទៀតប្រសិនបើករណីរកឃើញថាការងារសាងសង់ ឬរុះរើមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានទេនោះ អាជ្ញាធរមានសមត្ថកិច្ចអាចសម្រេចផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឲ្យរុះរើ ឬចាត់វិធានការចាំបាច់ផ្សេងៗទៀតតាមច្បាប់កំណត់។[43]

### ១.២.៤. ការប្រើប្រាស់សំណង់

#### ១.២.៤.១. សំណង់ដែលសាងសង់រួចរាល់មុនច្បាប់ស្តីពីសំណង់ចូលជាធរមាន

ព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងការរីកចម្រើនជាពិសេសវិស័យសំណង់ តម្រូវការនៃភាពស្របច្បាប់ពិតជាសំខាន់ដើម្បីធានានូវសុវត្ថិភាព និងសោភ័ណភាពនៃសំណង់។

រាល់ការប្រើប្រាស់សំណង់ដែលតម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់ ត្រូវអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចតាមរយៈវិញ្ញាបនបត្រប្រើប្រាស់សំណង់។ វិញ្ញាបនបត្រប្រើប្រាស់សំណង់ គឺជាឯកសារគតិយុត្តដ៏សំខាន់មួយក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិទៅតាមច្បាប់។ វាជាឯកសារដែលចេញដោយអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចេញប្រកាសលេខ១៧៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ទាក់ទងនឹងបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើ-ប្រាស់សំណង់ សម្រាប់សំណង់ណាដែលបានសាងសង់រួចមុនច្បាប់សំណង់ចូលជាធរមាន គោលបំណងនៃប្រកាសនេះ គឺដើម្បីធានាបាននូវគុណភាពរួមមានសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សោភណភាព និងបរិយាកាសល្អ ដោយផ្អែកតាមទស្សនៈទានរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់ និងសាធារណៈជន។

ប្រកាសនេះផងដែរមានគោលបំណង បង្ការការសាងសង់សំណង់ដែលមិនគោរពតាមបទដ្ឋានគុណភាព និងសុវត្ថិភាពដែលបានកំណត់ផងដែរ។ បន្ថែមពីលើនេះ ប្រកាសលេខ១៧៧ នេះបានចែងអំពីបែបបទ និង

[42] មាត្រា៤១ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[43] មាត្រា៤២ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

នីតិវិធីនៃការចេញ ការផ្អាក និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ណាដែលបានសាងសង់រួចហើយមុនពេលដែលច្បាប់ស្តីពីសំណង់បានចូលជាធរមានដែលបានអនុម័តកាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩។

សំណង់ដែលត្រូវបានអនុម័តតាមសេចក្តីប្រកាសរួមមាន សំណង់ដែលគ្មានការអនុញ្ញាត សំណង់មិនស្របតាមការអនុញ្ញាត និងសំណង់ដែលសាងសង់មិនមានលិខិតអនុញ្ញាតសាងសង់។

ជាក់ស្តែងដើម្បីប្រើប្រាស់សំណង់ ជាទូទៅតាមបទប្បញ្ញត្តិច្បាប់ត្រូវតែមានវិញ្ញាបនបត្រអនុញ្ញាតឲ្យប្រើប្រាស់សំណង់ដែលក្នុងនោះរួមមានសមត្ថកិច្ចក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលរាជធានីខេត្ត និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

សំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅច្រកចេញចូលតែមួយ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី-ខេត្ត។ ឯសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។[44]

### ១.២.៤.២. សំណង់ដែលសាងសង់រួចរាល់ក្រោយច្បាប់ស្តីពីសំណង់ចូលជាធរមាន

យោងតាមច្បាប់ស្តីពីសំណង់ដែលបានចូលជាធរមាននៅឆ្នាំ២០១៩ បានចែងច្បាស់លាស់ថា ការប្រើប្រាស់សំណង់ដែលតម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់ ត្រូវអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចតាមរយៈវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដោយម្ចាស់សំណង់ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ មុននឹងប្រើប្រាស់ ឬដាក់ឲ្យប្រើប្រាស់សំណង់នោះ។[45] ប៉ុន្តែក្នុងករណីដែលសំណង់ទាំងមូល ឬផ្នែកណាមួយនៃគម្រោងសាងសង់នោះអាចប្រើប្រាស់បានដោយសុវត្ថិភាព អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឲ្យចូលប្រើប្រាស់សំណង់ក្នុងរយៈពេលណាមួយបណ្តោះអាសន្នបាន។[46]

មួយវិញទៀតដើម្បីធានានូវគុណភាព និងសោភណភាពនៃសំណង់ សំណង់ដែលប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋានតម្រូវឲ្យមានការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ ៥ឆ្នាំម្តង ដោយគិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់ ហើយការត្រួតពិនិត្យនេះត្រូវបន្តអនុវត្តជាទៀតទាត់រៀងរាល់ ៥ឆ្នាំ

[44] ប្រការ១២ នៃប្រកាសលេខ១៧៧ ដនស/ប្រក. ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

[45] មាត្រា៨៤ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[46] មាត្រា៨៥ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

ម្តងយ៉ាងយូរ។ ចំពោះសំណង់ដែលប្រើប្រាស់ក្នុងគោលដៅលំនៅឋានតម្រូវឲ្យមានការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពក្នុងរយៈពេល ១០ឆ្នាំ គិតចាប់ពីថ្ងៃដែលចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់ ហើយត្រូវបន្តអនុវត្តត្រួត-ពិនិត្យបែបនេះជាទៀតទាត់ក្នុងរយៈពេល១០ឆ្នាំម្តងជាទៀតទាត់។ ចំណែកការត្រួតពិនិត្យ និងការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃការប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យនៃសំណង់ត្រូវធ្វើឡើងសម្រាប់រយៈពេល ២ឆ្នាំម្តង។ រីឯបរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់តម្រូវឲ្យមានការត្រួតពិនិត្យរៀងរាល់១ឆ្នាំម្តង។ ដោយឡែកប្រភេទបរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ លើសពីនេះម្ចាស់សំណង់ ឬអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចប្រគល់លទ្ធផលនៃការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ជូនអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេល១ខែក្រោយផុតកំណត់រយៈពេលដែលតម្រូវឲ្យអនុវត្តការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់។[47]

យ៉ាងណាមិញករណីដែលមានហានិភ័យចំពោះជីវិតមនុស្ស ទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សន្តិសុខ ឬសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធរដែលមានសមត្ថកិច្ចអាចតម្រូវឲ្យមានការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ភ្លាមៗ។[48] ហើយអាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឲ្យមានការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ ត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យសំណង់ ឬអ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ចំណែករាល់ការចំណាយសម្រាប់ត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់នេះ ជាបន្ទុករបស់ម្ចាស់សំណង់។[49]

មួយវិញទៀតបែបបទ និងនីតិវិធីនៃការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[50]

### ១.២.៥. សំណង់ដែលមានសភាពគ្រោះថ្នាក់

ជាធម្មតាទៅហើយចំពោះសំណង់ដែលសាងសង់យូរឆ្នាំ សំណង់ហាលថ្ងៃ ហាលភ្លៀង ហាលខ្យល់រាល់ថ្ងៃវាតែងតែប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ខូចទ្រង់ទ្រាយដើមពីមួយថ្ងៃទៅមួយថ្ងៃឈានទៅរកការខូចខាតធ្ងន់ធ្ងរ និងអាចមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់សំណង់នោះ។

[47] មាត្រា៤៧ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[48] មាត្រា៤៨ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[49] មាត្រា៤៩ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[50] មាត្រា៥០ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

ដោយយល់ឃើញអំពីបញ្ហាបែបនេះហើយទើបក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចត្រួតពិនិត្យតាមដានរាល់សំណង់ទាំងឡាយណាដែលមាន សភាពគ្រោះថ្នាក់ដើម្បីចាត់វិធានការចាំបាច់នានាក្នុងការធានាសុវត្ថិភាព សន្តិសុខ និងព្រមទាំងសណ្តាប់ធ្នាប់ សាធារណៈផងៗ[51]

ចំពោះសំណង់ដែលមានសភាពគ្រោះថ្នាក់ ម្ចាស់សំណង់ និងអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចរាយ ការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច និងអនុវត្តតាមវិធានការបញ្ចៀសគ្រោះថ្នាក់ទាំងឡាយដែលកំណត់ដោយ អាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីចាំបាច់ដើម្បីបញ្ចៀសគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការ បន្ទាន់ជាអាទិ៍ ហ៊ុំព័ទ្ធហាមចូល ហាមប្រើប្រាស់ និងតម្រូវឲ្យរុះរើសំណង់ ហើយរាល់ការចំណាយក្នុងការបញ្ចៀស គ្រោះថ្នាក់ជាបន្ទុករបស់ម្ចាស់សំណង់ៗ[52] ឯកម្រិតសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និង នីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ៗ[53]

#### ១.២.៥.១. ចំណាត់ថ្នាក់កម្រិតសភាពគ្រោះថ្នាក់នៃសំណង់

សភាពគ្រោះថ្នាក់របស់សំណង់មាន២(ពីរ) ប្រភេទរួមមាន ប្រភេទគ្រោះថ្នាក់ដែលកើតឡើងភ្លាមៗ និង ប្រភេទសំណង់មិនអាចកើតឡើងភ្លាមៗៗ[54] នៅក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចទទួលបានពាក្យបណ្តឹង ឬព័ត៌មានអំពីសំណង់ដែលមានសភាពគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ច ត្រូវសម្រេចធ្វើការត្រួតពិនិត្យគុណ- ភាព និងសុវត្ថិភាពសំណង់នោះៗ ខណៈពេលនោះដែរ អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យ គុណភាព និងសុវត្ថិភាពសំណង់ ដើម្បីចុះត្រួតពិនិត្យវាយតម្លៃ និងធ្វើការសន្និដ្ឋានអំពីការចាត់ថ្នាក់កម្រិតសភាព គ្រោះថ្នាក់របស់សំណង់ជាបន្ទាន់ៗ ប្រសិនបើពិនិត្យឃើញថាគ្រោះថ្នាក់អាចកើតឡើងភ្លាមៗ មន្ត្រីត្រួតពិនិត្យ គុណភាព និងសុវត្ថិភាពនៃសំណង់ត្រូវរាយការណ៍ជូនដល់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធជាបន្ទាន់ តាមគ្រប់ មធ្យោបាយដែលអាចធ្វើទៅបានៗ[55]

---

[51] មាត្រា៥១ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[52] មាត្រា៥២ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[53] មាត្រា៥៣ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[54] ប្រការ៤ នៃប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃ ការគ្រប់គ្រងសំណង់ដែលមានគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

[55] ប្រការ៥ នៃប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃ ការគ្រប់គ្រងសំណង់ដែលមានគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

ចំណែកឯរបាយការណ៍ស្ដីពីការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ ត្រូវដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចតាមរយៈប្រធានអង្គភាពមានសមត្ថកិច្ចក្នុងរយៈពេលគិតចាប់ពីថ្ងៃសម្រេចធ្វើការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ទៅតាមសមត្ថកិច្ចដែលផ្ដល់លិខិតអនុញ្ញាតសាងសង់៖[56]

- យ៉ាងយូរ១០(ដប់)ថ្ងៃ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យ៉ាងយូរ៥(ប្រាំ)ថ្ងៃ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្ដល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។
- យ៉ាងយូរ៣(បី)ថ្ងៃ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្ដល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

### ១.២.៥.២. ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់នៃសំណង់

ក្នុងករណីគ្រោះថ្នាក់អាចកើតឡើងភ្លាមៗចំពោះសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មានសមត្ថកិច្ចចេញវិធានការបញ្ចៀសគ្រោះថ្នាក់ផ្អែកតាមរបាយការណ៍ស្ដីអំពីការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់របស់អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ។ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់នេះ ត្រូវធ្វើឡើងទៅតាមប្រភេទ និងកម្រិតនៃសភាពគ្រោះថ្នាក់នៃសំណង់ និងផ្អែកតាមរបាយការណ៍ស្ដីពីការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់។ ហើយមិនតែប៉ុណ្ណោះ អង្គភាពដែលមានសមត្ថកិច្ចត្រូវយកលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ទៅបិទផ្សាយជាសាធារណៈនៅទីតាំងសំណង់ដែលមានសភាពគ្រោះថ្នាក់នោះ។[57]

លើសពីនេះក្នុងករណីគ្រោះថ្នាក់អាចកើតឡើងភ្លាមៗ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវជូនដំណឹងទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ អ្នកជួលសំណង់ ឬអ្នកដែលកំពុងស្ថិតនៅក្នុងទីតាំងសំណង់ជាបន្ទាន់ តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបានអំពីវិធានការបញ្ចៀសគ្រោះថ្នាក់។[58]

ហើយវិធានការបញ្ចៀសគ្រោះថ្នាក់ដែលអាចកើតឡើងភ្លាមៗមានជាអាទិ៍៖[59]

---

[56] ប្រការ៦ នៃប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ស្ដីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

[57] ប្រការ១០ នៃប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ស្ដីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

[58] ប្រការ១១ នៃប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ស្ដីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

[59] ប្រការ១១ ដដែលនៃប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ស្ដីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

- ជម្លៀសមនុស្សចេញពីសំណង់ដែលមានសភាពគ្រោះថ្នាក់
- កំណត់អត្តសញ្ញាណសំណង់ជិតខាងដែលអាចរងផលប៉ះពាល់ និងជម្លៀសមនុស្សចេញពីសំណង់ទាំងនោះ
- ហ៊ុមព័ទ្ធ ហាមចូល ហាមប្រើប្រាស់ និងហាមអ្នកគ្មានភារកិច្ចចេញចូល
- រុះរើសំណង់ ឬផ្នែកណាមួយនៃសំណង់ដែលអាចបង្កគ្រោះថ្នាក់
- កំណត់បរិវេណសុវត្ថិភាព
- បិទផ្សាយជាសាធារណៈនូវលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់នៅទីតាំងសំណង់។

ដោយឡែកចំពោះករណីគ្រោះថ្នាក់មិនអាចកើតឡើងភ្លាមៗ អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និង/ឬអ្នកជួលសំណង់អំពីវិធានការនៃការបញ្ចៀសគ្រោះថ្នាក់។[60]

ហើយវិធានការបញ្ចៀសគ្រោះថ្នាក់ដែលមិនអាចកើតឡើងភ្លាមៗ មានជាអាទិ៍៖[61]

- តម្រូវឲ្យម្ចាស់សំណង់ជួសជុល កែប្រែ ឬរុះរើសំណង់ ឬផ្នែកណាមួយនៃសំណង់
- តម្រូវឲ្យម្ចាស់សំណង់រកអ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ ដើម្បីសិក្សារកវិធីសាស្រ្តបញ្ចៀសគ្រោះថ្នាក់
- តម្រូវឲ្យម្ចាស់សំណង់ចាត់ចែងអនុវត្តតាមការផ្តល់យោបល់បច្ចេកទេសរបស់អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់
- តម្រូវឲ្យម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ ចាត់វិធានការចាំបាច់នានាដើម្បីធានាសុវត្ថិភាព សុខភាព និងទ្រព្យសម្បត្តិរបស់អតិថិជន អ្នកប្រើប្រាស់សំណង់ និងអ្នកជិតខាង
- បិទផ្សាយលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់នៅទីតាំងសំណង់។

មួយវិញទៀតលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ ត្រូវកំណត់រយៈពេលសម្រាប់អនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់ដោយម្ចាស់សំណង់ និងរយៈពេលសម្រាប់អនុវត្តសិទ្ធិតវ៉ារបស់ម្ចាស់សំណង់។ រីឯ

[60] ប្រការ១២ នៃប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

[61] ប្រការ១២ ដដែលនៃប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់រយៈពេលសម្រាប់អនុវត្តសិទ្ធិតវ៉ារបស់ម្ចាស់សំណង់ទៅតាមប្រភេទ និងកម្រិតនៃសភាពគ្រោះថ្នាក់របស់សំណង់ ប៉ុន្តែរយៈពេលនេះមិនត្រូវយូរជាង៖[62]

- ៩០(កៅសិប)ថ្ងៃគិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងអំពីវិធានការបញ្ជៀសគ្រោះថ្នាក់ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងអំពីវិធានការបញ្ជៀសគ្រោះថ្នាក់ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងអំពីវិធានការបញ្ជៀសគ្រោះថ្នាក់ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

### ១.២.៥.៣. នីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់ចំពោះសំណង់ ដែលស្ថិតក្រោមសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់របស់ខ្លួន។ ហើយបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់ មានបង្ហាញជាអាទិ៍ ទីតាំងនៃសំណង់ ប្រភេទនៃសំណង់ មុខងារប្រើប្រាស់សំណង់ អត្តសញ្ញាណរបស់ម្ចាស់សំណង់ និងអ្នកគ្រប់គ្រងសំណង់ កម្រិតនៃសភាពគ្រោះថ្នាក់ និងវិធានការបញ្ជៀសគ្រោះថ្នាក់សម្រាប់ត្រួតពិនិត្យតាមដានចាត់វិធានការពង្រឹងការអនុវត្តច្បាប់។ ជាងនេះទៅទៀតអង្គភាពមានសមត្ថកិច្ចមានភារកិច្ចគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពកម្មបញ្ជីសំណង់ដែលមានគ្រោះថ្នាក់ជាឯកសាររឹង និងជាឯកសារទម្រង់អេឡិចត្រូនិក។[63] លើសពីនេះអង្គភាពមានសមត្ថកិច្ចដែលមានភារកិច្ចត្រួតពិនិត្យ និងតាមដានរាល់សំណង់ដែលត្រូវបានចុះក្នុងបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់ និងលើកសំណើជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចេញវិធានការបញ្ជៀសគ្រោះថ្នាក់ ឬដកចេញពីបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់តែម្តង។[64]

ដោយឡែកម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ដែលមានក្នុងបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់ដដែលនោះ ត្រូវផ្តល់កិច្ចសហការជាមួយមន្ត្រីនៃអង្គភាពដែលមានមានសមត្ថកិច្ចនៅក្នុង

---

[62] ប្រការ១៣ នៃប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ជៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

[63] ប្រការ១៨ នៃប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ជៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

[64] ប្រការ១៩ នៃប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ជៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

ការត្រួតពិនិត្យ តាមដាន និងចាត់វិធានការបញ្ចៀសគ្រោះថ្នាក់ និងត្រូវរាយការណ៍អំពីស្ថានភាពនៃការប្រែប្រួលរបស់សំណង់ជូនអាជ្ញាធរមានសមត្ថកិច្ច។[65]

### ១.២.៦. សំណង់ដែលសាងសង់ ឬរុះរើដោយគ្មាន ឬខុសពីលិខិតអនុញ្ញាត

យោងតាមបទប្បញ្ញត្តិនៃច្បាប់ និងបទដ្ឋានដែលពាក់ព័ន្ធនឹងវិស័យសំណង់ ជាពិសេសនោះគឺច្បាប់ស្តីពីសំណង់ឆ្នាំ២០១៩ បានចែងជាពិសេសសម្រាប់វិស័យសំណង់។ ដោយហេតុនោះថា កាលណាសំណង់ដែលសាងសង់ដោយបំពាន សាងសង់ដោយមិនបានបំពេញលក្ខខណ្ឌដែលច្បាប់តម្រូវ ត្រូវចាត់ទុកថាជាសំណង់ដែលខុសច្បាប់។

ក្នុងករណីនេះអាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ការងារសាងសង់ ឬរុះរើដែលគ្មានលិខិតអនុញ្ញាត ប្រសិនបើការសាងសង់ ឬរុះរើនោះតម្រូវឲ្យមានលិខិតអនុញ្ញាត។[66] លើសពីនេះអាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការផ្អាកការងារសាងសង់ ឬរុះរើផងដែរចំពោះសំណង់ណាដែលបានធ្វើឡើងខុសពីលិខិតអនុញ្ញាត និងតម្រូវឲ្យម្ចាស់សំណង់កែតម្រូវឲ្យស្របតាមលិខិតអនុញ្ញាតនោះ។[67] មួយវិញទៀតអាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការកែសម្រួល ឬរុះរើរាល់សំណង់ដែលសាងសង់ដោយគ្មាន ឬសាងសង់ខុសពីលិខិតអនុញ្ញាតនោះ ហើយថែមទាំងចាត់វិធានការហាមឃាត់រាល់ការប្រើប្រាស់ ការប្រកបអាជីវកម្ម ការចាត់ចែង និងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់នោះផងដែរ។[68]

### ១.២.៧. អធិការកិច្ចសំណង់

ការត្រួតពិនិត្យលើសំណង់ ជាពិសេសលើបច្ចេកទេសសាងសង់ត្រឹមត្រូវតាមក្បួនខ្នាត និងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តែងតាំងមន្ត្រីអធិការកិច្ចសំណង់ ដើម្បីចុះអង្កេត ស្រាវជ្រាវ ត្រួតពិនិត្យ ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់។[69]

ការធ្វើអធិការកិច្ចសំណង់ សំដៅដល់ការតាមដាន ស្រាវជ្រាវ និងត្រួតពិនិត្យការអភិវឌ្ឍអចលនវត្ថុ ដើម្បីចាត់វិធានការ ឬដាក់ទណ្ឌកម្មលើបុគ្គលប្រព្រឹត្តអំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីនគរូបនីយកម្ម និងសំណង់។[70]

---

[65] ប្រការ២០ នៃប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

[66] មាត្រា៥៤ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[67] មាត្រា៥៥ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[68] មាត្រា៥៦ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[69] មាត្រា៥៧ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[70] ប្រការ៣ វាក្យខណ្ឌទី១ នៃប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស-កយ ស្តីពីនីតិវិធីបែបបទនៃការធ្វើអធិការកិច្ចសំណង់ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

ហើយមន្ត្រីអធិការកិច្ចសំណង់ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឲ្យពិនិត្យបទល្មើសដូចដែលមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។[71]

### ១.២.៧.១. សមត្ថកិច្ចមន្ត្រីអធិការកិច្ចសំណង់

យោងតាមប្រកាសអន្តរក្រសួងលេខ១១៨ដដែលនេះបានកំណត់អំពីមន្ត្រីអធិការកិច្ចសំណង់ ដែលក្នុងនោះមានដូចខាងក្រោម៖[72]

- ថ្នាក់ដឹកនាំជាវិស្វករ ឬស្ថាបត្យករនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- មន្ត្រីជំនាញជាវិស្វករ ឬស្ថាបត្យករនៃអគ្គនាយកដ្ឋានសំណង់ និងអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- មន្ត្រីជំនាញជាវិស្វករ ឬស្ថាបត្យករនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីខេត្ត។
- មន្ត្រីជំនាញជាវិស្វករ ឬស្ថាបត្យករនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។

### ១.២.៧.២. សិទ្ធិ និងភារកិច្ចរបស់មន្ត្រីអធិការកិច្ចសំណង់

យោងតាមបទដ្ឋានច្បាប់ស្តីពីសំណង់ឆ្នាំ២០១៩ បានចែងកំណត់យ៉ាងច្បាស់អំពីសិទ្ធិ និងភារកិច្ចរបស់មន្ត្រីអធិការកិច្ចសំណង់ ដែលមានដូចខាងក្រោមនេះ៖[73]

- ត្រួតពិនិត្យ បញ្ឈប់ ចាត់វិធានការបណ្តោះអាសន្ន និងពិន័យអន្តរការណ៍ចំពោះបទល្មើសសំណង់ដែលមានចែងក្នុងច្បាប់ស្តីពីសំណង់នេះ
- ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាក់ព័ន្ធក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនោះប្រព្រឹត្តល្មើសនឹងច្បាប់
- មានសិទ្ធិចាប់យកវត្ថុតាង និងកសាងសំណុំរឿងនៃបទល្មើសសំណង់
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់។

លើសពីនេះ មន្ត្រីអធិការកិច្ចសំណង់អាចចូលទៅក្នុងការដ្ឋានសំណង់គ្រប់ពេលវេលាក្នុងពេលការដ្ឋានកំពុងដំណើរការ ឬក្នុងអគារនៅក្នុងម៉ោងធ្វើការដើម្បីបំពេញភារកិច្ចរបស់ខ្លួន។[74]

---

[71] មាត្រា៥៧ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[72] ប្រការ៤ នៃប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស-កយ ស្តីពីនីតិវិធីបែបបទនៃការធ្វើអធិការកិច្ចសំណង់ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

[73] មាត្រា៥៩ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[74] មាត្រា៦០ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

### ១.២.៧.៣. នីតិវិធីនៃការធ្វើអធិការកិច្ចសំណង់

អាជ្ញាធរមានសមត្ថកិច្ច ជាអ្នកសម្រេចធ្វើអធិការកិច្ចសំណង់។ ហើយអាជ្ញាធរមានសមត្ថកិច្ចនោះ មានដូចខាងក្រោម៖[75]

- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះការអភិវឌ្ឍអចលនវត្ថុគ្រប់ប្រភេទ និងទំហំ។
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ចំពោះការអភិវឌ្ឍអចលនវត្ថុដែលស្ថិតនៅក្រោមរបស់រដ្ឋបាលរាជធានី ខេត្ត។
- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ចំពោះការអភិវឌ្ឍអចលនវត្ថុដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ការលើកសំណើធ្វើអធិការកិច្ចសំណង់ទៅអាជ្ញាធរមានសមត្ថកិច្ចគឺមានតែប្រធានអង្គភាពតែប៉ុណ្ណោះ។[76]

ជាការពិតណាស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអ្នកចេញលិខិតបញ្ជាបេសកកម្មចុះធ្វើអធិការកិច្ចសំណង់ ជូនមន្ត្រីអធិការកិច្ចសំណង់ថ្នាក់ជាតិ រីឯអភិបាលនៃគណៈអភិបាលរាជធានី ខេត្តវិញ ជាអ្នកចេញលិខិតបេសកកម្មជូនមន្ត្រីអធិការកិច្ចសំណង់ថ្នាក់រាជធានី ខេត្ត តាមសំណើរបស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌវិញ ក៏ជាអ្នកចេញលិខិតបញ្ជាបេសកកម្មចុះអធិការកិច្ចសំណង់ជូនមន្ត្រីអធិការកិច្ចសំណង់ថ្នាក់ក្រុង ស្រុក ខណ្ឌ តាមសំណើរបស់ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ផងដែរ។[77] នេះជាការបែងចែកការត្រួតពិនិត្យ និងធ្វើអធិការកិច្ចទៅតាមដែនសមត្ថកិច្ច និងប្រភេទ និងទំហំនៃសំណង់ផងដែរ។ យ៉ាងណាមិញចំពោះការធ្វើអធិការកិច្ចសំណង់ មន្ត្រីអធិការកិច្ចសំណង់មានចំនួនច្រើន ឬតិចទៅតាមការសម្រេចរបស់ប្រធានអង្គភាព ជាពិសេសទៅតាមដែនសមត្ថកិច្ចរៀងៗខ្លួនដែលក្នុងនោះមានមន្ត្រីអធិការកិច្ចសំណង់ចំនួន ៥(ប្រាំ)នាក់យ៉ាងតិច ការសម្រេចដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ត្រីអធិការកិច្ចសំណង់ចំនួន ៣(បី)នាក់យ៉ាងតិចដែលសម្រាប់ការសម្រេចដោយអភិបាលនៃ

[75] ប្រការ៥ នៃប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស-កយ ស្តីពីនីតិវិធីបែបបទនៃការធ្វើអធិការកិច្ចសំណង់ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

[76] ប្រការ៥ វាក្យខណ្ឌទី៣ នៃប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស-កយ ស្តីពីនីតិវិធីបែបបទនៃការធ្វើអធិការកិច្ចសំណង់ ចុះថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១៩

[77] ប្រការ៦ នៃប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស-កយ ស្តីពីនីតិវិធីបែបបទនៃការធ្វើអធិការកិច្ចសំណង់ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

គណៈអភិបាលរាជធានី ខេត្ត ហើយ១(មួយ)នាក់យ៉ាងតិច សម្រាប់ការធ្វើអធិការកិច្ចសំណង់សម្រេចដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។[78]

ជាទូទៅមន្ត្រីអធិការកិច្ចអាចចូលបំពេញការងារនៅក្នុងការដ្ឋានសំណង់បាន លុះត្រាណាតែការដ្ឋានសំណង់កំពុងដំណើរការ ហើយអាចចូលបំពេញការងារបានតែនៅក្នុងម៉ោងធ្វើការតែប៉ុណ្ណោះ គឺនៅក្រោយម៉ោង៦(ប្រាំមួយ)ព្រឹក និងមុនម៉ោង១៨(ដប់ប្រាំបី)ល្ងាច។ ក្នុងករណីចាំបាច់ដែលតម្រូវឲ្យការធ្វើអធិការកិច្ចសំណង់នៅក្រៅពេលដូចដែលកំណត់ មន្ត្រីអធិការកិច្ចសំណង់ត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា។[79] មួយវិញទៀតជាការកំណត់ហើយក៏ជាលក្ខខណ្ឌពិសេសផងដែរនោះពេលដែលបំពេញបេសកកម្ម មន្ត្រីអធិការកិច្ចសំណង់ត្រូវមានលិខិតបេសកកម្មដែលចេញដោយប្រធានអង្គភាពរៀងខ្លួន ស្លៀកពាក់ឯកសណ្ឋាន និងមានសញ្ញាសម្គាល់ជាចាំបាច់។[80]

បន្ថែមពីលើនេះទៀតក្នុងពេលបំពេញបេសកកម្ម មន្ត្រីអធិការកិច្ចសំណង់ ត្រូវអនុវត្តដូចខាងក្រោម៖[81]

- ត្រួតពិនិត្យ និងអង្កេតអំពីអនុលោមភាពនៃការអភិវឌ្ឍដី និង/ឬការងារសាងសង់ ឬរុះរើសំណង់តាមលិខិតអនុញ្ញាត បទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាន
- ត្រួតពិនិត្យការប្រកបអាជីវកម្មរបស់រូបវន្តបុគ្គល ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ ក្រុមហ៊ុនសាងសង់ និងក្រុមជាងសំណង់
- ត្រួតពិនិត្យសុវត្ថិភាពការងារនៅខាងក្នុង និងជុំវិញបរិវេណការដ្ឋានសំណង់
- ត្រួតពិនិត្យឯកសារពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍ដី និង/ឬគម្រោងសាងសង់ ឬរុះរើសំណង់
- ស្នើសុំឲ្យម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍន៍អចលនវត្ថុផ្តល់ព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុនសិក្សាគម្រោងប្លង់ ក្រុមហ៊ុនសាងសង់ ជាងជំនាញ និង/ឬក្រុមជាងសំណង់ ដែលពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍ដី និង/ឬគម្រោងសាងសង់ ឬរុះរើ
- ណែនាំឲ្យម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍន៍អចលនវត្ថុធ្វើការកែតម្រូវតាមលិខិតអនុញ្ញាតអភិវឌ្ឍន៍អចលនវត្ថុ

[78] ប្រការ៧ នៃប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស-កយ ស្តីពីនីតិវិធីបែបបទនៃការធ្វើអធិការកិច្ចសំណង់ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

[79] ប្រការ៨ នៃប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស-កយ ស្តីពីនីតិវិធីបែបបទនៃការធ្វើអធិការកិច្ចសំណង់ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

[80] ប្រការ៩ នៃប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស-កយ ស្តីពីនីតិវិធីបែបបទនៃការធ្វើអធិការកិច្ចសំណង់ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

[81] ប្រការ១០ នៃប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស-កយ ស្តីពីនីតិវិធីបែបបទនៃការធ្វើអធិការកិច្ចសំណង់ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

- ពន្យល់ណែនាំអ្នកគ្រប់គ្រងការដ្ឋានឲ្យចាត់វិធានការបន្ទាន់ ដើម្បីបញ្ចៀសគ្រោះថ្នាក់ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដោយថាហេតុ នៅខាងក្នុង និងជុំវិញបរិវេណការដ្ឋានសំណង់
- ណែនាំរូបវន្តបុគ្គល ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងក្រុមហ៊ុនសាងសង់ និងក្រុមជាងសំណង់អំពីបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុ
- ធ្វើកំណត់ហេតុនៃការចុះអធិការកិច្ចសំណង់ របាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់
- ប្រតិបត្តិការងារផ្សេងទៀត ដែលអាជ្ញាធរមានសមត្ថកិច្ចប្រគល់ជូន។

រីឯកំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់ និងរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់នោះត្រូវដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចតាមរយៈប្រធានអង្គភាពមានសមត្ថកិច្ចដើម្បីពិនិត្យ និងសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចុះធ្វើអធិការកិច្ច។ ចំពោះកំណត់ហេតុ និងរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់របស់មន្ត្រីអធិការកិច្ចសំណង់ថ្នាក់ក្រោមជាតិដែលដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចត្រូវចម្លងជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[82] ហើយចំពោះខ្លឹមសារសំខាន់ៗនៃកំណត់ហេតុ និងរបាយការណ៍នៃការចុះធ្វើអធិការកិច្ចសំណង់ត្រូវមានអត្តសញ្ញាណម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍន៍អចលនវត្ថុ និងរូបវន្តបុគ្គល ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ ក្រុមហ៊ុនសាងសង់ ក្រុមជាងសាងសង់ ព័ត៌មានអំពីគម្រោងអភិវឌ្ឍន៍ដី ឬគម្រោងសាងសង់ ឬរុះរើ និងរួមទាំងលទ្ធផលនៃការផ្ទៀងផ្ទាត់អំពីអនុលោមចំពោះលិខិតអនុញ្ញាតអភិវឌ្ឍន៍អចលនវត្ថុ និងហត្ថលេខារបស់មន្ត្រីអធិការកិច្ចសំណង់ អ្នកគ្រប់គ្រងការដ្ឋាន ម្ចាស់សំណង់ និងអ្នកពាក់ព័ន្ធដទៃទៀត។[83]

ដោយឡែកមន្ត្រីអធិការកិច្ចសំណង់ មិនត្រូវធ្វើសកម្មភាពដែលបង្កឲ្យមានការប៉ះពាល់ ឬរាំងស្ទះដល់ដំណើរការអភិវឌ្ឍ ឬសាងសង់ ឬរុះរើដែលអនុលោមតាមលិខិតអនុញ្ញាត បទប្បញ្ញត្តិបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាននៅក្នុងពេលបំពេញសកម្មភាពអធិការកិច្ចរបស់ខ្លួន ហើយក៏មិនត្រូវផ្សព្វផ្សាយជាសាធារណៈអំពីព័ត៌មានដែលពាក់ព័ន្ធនឹងបច្ចេកទេសសាងសង់ និងកិច្ចសន្យាម៉ៅការសាងសង់។[84]

[82] ប្រការ១១ នៃប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស-កយ ស្តីពីនីតិវិធីបែបបទនៃការធ្វើអធិការកិច្ចសំណង់ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

[83] ប្រការ១២ នៃប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស-កយ ស្តីពីនីតិវិធីបែបបទនៃការធ្វើអធិការកិច្ចសំណង់ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

[84] ប្រការ១៦ នៃប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស-កយ ស្តីពីនីតិវិធីបែបបទនៃការធ្វើអធិការកិច្ចសំណង់ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

### **១.២.៨. វិសមិតភាព**

ក្នុងវិស័យសំណង់ដើម្បីធានាឲ្យមានប្រក្រតីភាព និងតម្លាភាព យុត្តិធម៌ត្រឹមត្រូវ ច្បាប់ស្តីពីសំណង់បានកំណត់អំពីគោលការណ៍វិសមិតភាពនៃការអនុវត្តការងារសំណង់រវាងអ្នកដែលទទួលសមត្ថកិច្ច ឬទទួលបាននូវសម្បទាឲ្យអនុវត្តការងារសំណង់ផ្សេងៗ។ ចំណុចនេះប្រសិនបើបុគ្គលណាម្នាក់ទៅអនុវត្តការងារសំណង់ច្រើនប្រភេទហើយធ្វើឲ្យប្រសិទ្ធភាព ឬភាពត្រឹមត្រូវនៃការងារនោះវាក្លាយទៅជាខុសវិញនោះនាំឲ្យមានការហាមឃាត់ករណីបែបនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នឹងមិនផ្តល់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈទៅមន្ត្រីរាជការដែលកំពុងប្រតិបត្តិការងារនៅក្នុងការងារសំណង់នោះទេ។ ជាក់ស្តែងមន្ត្រីរាជការដែលមានសមត្ថកិច្ចត្រួតពិនិត្យ និងសម្រេចលើគម្រោងប្លង់មិនអាចជាអ្នកសិក្សាគម្រោងប្លង់ ឬអ្នកត្រួតពិនិត្យ និងបញ្ជាក់លើគម្រោងប្លង់ដែលខ្លួនបានសិក្សា ឬត្រួតពិនិត្យ និងបញ្ជាក់បានឡើយ។[85]

មួយវិញទៀតចំពោះមន្ត្រីអធិការកិច្ចសំណង់ មន្ត្រីត្រួតពិនិត្យសំណង់ និងរួមទាំងអ្នកត្រួតពិនិត្យបញ្ជាក់សំណង់ មិនអាចជាម្ចាស់សំណង់ ឬជាសហព័ទ្ធ ឬជាញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣ថ្នាក់ ឬញាតិពន្ធក្នុង៣ថ្នាក់របស់ម្ចាស់សំណង់ ឬមួយជាអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់បានឡើយ។[86] ច្បាប់បានចែងកំណត់បែបនេះដើម្បីជៀសវាងការអនុវត្តច្បាប់មិនមានតម្លាភាព។

មិនតែប៉ុណ្ណោះចំពោះការបំពេញមុខងារជាអ្នកសិក្សាគម្រោងប្លង់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអ្នកត្រួតពិនិត្យ និងគម្រោងប្លង់របស់ខ្លួន។[87]

ចំពោះការបំពេញមុខងារជាអ្នកសាងសង់វិញក៏ដូចគ្នា គឺមានវិសមិតភាពជាមួយនឹងមុខងារជាអ្នកត្រួតពិនិត្យ និងបញ្ជាក់លើការងារសាងសង់របស់ខ្លួន។[88] លើសពីនេះទៀតអ្នកត្រួតពិនិត្យ និងបញ្ជាក់លើគម្រោងប្លង់ ឬការងារសាងសង់មិនអាចជាសហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣ថ្នាក់របស់ម្ចាស់សំណង់បានឡើយ ចំណែកឯសមាជិកភាគហ៊ុននៃក្រុមហ៊ុនដែលជាម្ចាស់សំណង់ បុគ្គលិកក្រុមហ៊ុនដែលជាម្ចាស់សំណង់ ឬអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់ ក៏មិនអាច និងមិនត្រូវបានអនុញ្ញាតឲ្យបំពេញមុខងារជាអ្នកត្រួតពិនិត្យ និងបញ្ជាក់លើគម្រោងប្លង់ ឬការងារសាងសង់សំណង់នេះបានឡើយ។[89]

---

[85] មាត្រា៦២ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[86] មាត្រា៦៣ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[87] មាត្រា៦៤ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[88] មាត្រា៦៥ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[89] មាត្រា៦៦ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

### ១.២.៩. ការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់

ច្បាប់ស្ដីពីសំណង់ឆ្នាំ២០១៩ បានចែងកំណត់ និងបែងចែកការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់ នេះជាពីរប្រភេទ គឺការគ្រប់គ្រងការប្រកបវិជ្ជាជីវៈ និងការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង។ ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ និងធ្វើការបែងចែកថាបុគ្គលទាំងពីរប្រភេទនេះខុសគ្នាដូចម្ដេចខ្លះយ៉ាងណានោះ យើងនឹងលម្អិតដូចតទៅ។

#### ១.២.៩.១. ការគ្រប់គ្រងអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់

អ្នកវិជ្ជាជីវៈ សំដៅដល់បុគ្គលដែលមានជំនាញទាំងអស់ ដែលបានសិក្សារៀនសូត្រ មានបទពិសោធន៍ រហូតមានជំនាញ មានសញ្ញាបត្របញ្ជាក់បញ្ចប់ការសិក្សានៃជំនាញរបស់ខ្លួនបានជោគជ័យ ហើយត្រូវមកចុះបញ្ជីនៅគណៈវិជ្ជាជីវៈតាមជំនាញរបស់ខ្លួនរៀងៗខ្លួនដូចជា វិស្វករត្រូវចុះបញ្ជីនៅគណៈវិស្វករ និងស្ថាបត្យករចុះបញ្ជីនៅគណៈស្ថាបត្យករទើបទទួលបានឈ្មោះជាអ្នកវិជ្ជាជីវៈ។ ដូចដែលច្បាប់បានកំណត់ថា រូបវន្តបុគ្គលដែលអាចបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ត្រូវចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធនីមួយៗនៃវិស័យសំណង់។[90] ហើយអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។[91]

#### ១.២.៩.២. ការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់

ការប្រកបវិជ្ជាជីវៈ និងការប្រកបអាជីវកម្មក្នុងវិស័យសំណង់មានលក្ខណៈខុសគ្នា។ ការប្រកបវិជ្ជាជីវៈ សំដៅដល់អ្នកដែលប្រកបវិជ្ជាជីវៈតែម្នាក់ឯងដោយឯករាជ្យ និងយកកម្រៃក្នុងវិស័យឯកជន។ ចំណែកការប្រកបអាជីវកម្ម សំដៅដល់ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណក្នុងការប្រកបអាជីវកម្ម ឬក្រុមអ្នកប្រកបវិជ្ជាជីវៈ ឬក្រុមជាងជំនាញដែលធ្វើការជាក្រុម ឬនៅក្នុងក្រុមហ៊ុន ក្នុងគោលបំណងរកប្រាក់កម្រៃដូចគ្នា។

អ្នកដែលប្រកបវិជ្ជាជីវៈដោយឯករាជ្យក្នុងវិស័យសំណង់ គឺខ្លួនឯងមានសិទ្ធិអំណាចសម្រេចនៅក្នុងទិដ្ឋភាពបច្ចេកទេសដែលបម្រើឲ្យការងារសំណង់ទៅតាមកម្រិត ជំនាញរបស់ខ្លួន និងត្រូវមានអាជ្ញាបណ្ណដែលផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[92] ដោយឡែកចំពោះអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដែលបំពេញមុខងារជានាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ មិនតម្រូវឲ្យមានអាជ្ញាបណ្ណឡើយ។[93] នៅពេលដែលការងារសំណង់អនុវត្តដោយក្រុមហ៊ុន អ្នកទទួលខុសត្រូវទីមួយនោះខាងបច្ចេកទេស គឺនាយកបច្ចេកទេស។ នាយកបច្ចេកទេសនេះត្រូវមានចំណេះជំនាញទៅតាមប្រភេទការងារ

[90] មាត្រា១២ នៃច្បាប់ស្ដីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[91] មាត្រា១៣ នៃច្បាប់ស្ដីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[92] មាត្រា១៥ វាក្យខណ្ឌទី១ នៃច្បាប់ស្ដីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[93] មាត្រា១៥ វាក្យខណ្ឌទី២ នៃច្បាប់ស្ដីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

របស់ពួកគាត់ នាយកបច្ចេកទេសនេះហើយដែលជាអ្នកចុះហត្ថលេខានៅលើឯកសារសាងសង់ដើម្បីបញ្ជាក់អំពីទិដ្ឋភាពបច្ចេកទេសរបស់ក្រុមហ៊ុន និងតម្រូវឲ្យបោះត្រាក្រុមហ៊ុននៅលើឯកសារដែលបានចុះហត្ថលេខានោះ។

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវបានបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈ ក្នុងករណីណាមួយដូចខាងក្រោម៖[94]

- លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ
- បានប្រព្រឹត្តកំហុសវិជ្ជាជីវៈដែលនាំទៅដល់ការផ្អាក ឬដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ
- មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ដោយមានការបញ្ជាក់ពីគ្រូពេទ្យជំនាញ ឬបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ឬការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភដោយតុលាការ
- បានទទួលការប្រកាសក្ស័យធនដោយតុលាការ
- ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ។

ការផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់មិនត្រូវលើសពី៦ខែ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។ ហើយនីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់អាចត្រូវបានផ្តល់ឡើងវិញ ក្រោយរយៈពេល ៥ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។ ក្នុងករណីបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈដោយមូលហេតុត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈនេះ អាចត្រូវបានផ្តល់ឡើងវិញ បន្ទាប់ពីសាមីខ្លួនបាននីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។[95]

ដោយឡែកចំពោះក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់វិញ ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងករណីដូចខាងក្រោម៖[96]

- លែងបំពេញលក្ខខណ្ឌតម្រូវណាមួយដែលអនុញ្ញាតឲ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្ម
- ត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម
- ត្រូវបានតុលាការប្រកាសរំលាយ ឬប្រកាសមោឃភាព
- ត្រូវបានតុលាការប្រកាសក្ស័យធន ឬការជម្រះបញ្ជីតាមផ្លូវតុលាការ

[94] មាត្រា១៦ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩
[95] មាត្រា១៦ ដដែលនៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩
[96] មាត្រា១៨ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

- មានអភិបាល ឬនាយកបច្ចេកទេសដែលបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ឬការប្រកាសចាប់ផ្តើមហិតូបត្ថម្ភដោយតុលាការ លើកលែងតែអភិបាល ឬនាយកបច្ចេកទេសនោះត្រូវបានប្តូរក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាល ឬនាយកបច្ចេកទេសដែលត្រូវបានតុលាការប្រកាសក្ស័យធន ឬជម្រះបញ្ជីតាមផ្លូវតុលាការ លើកលែងតែអភិបាល ឬនាយកបច្ចេកទេសនោះត្រូវបានផ្លាស់ប្តូរក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាល ឬនាយកបច្ចេកទេសដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្តូរក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលមានសាលក្រម ឬសាលដីកាស្ថាពរ។

ការផ្អាកអាជ្ញាបណ្ណប្រកបអាជីវកម្មក្នុងវិស័យសំណង់មិនត្រូវមានរយៈពេលលើសពី១(មួយ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។ នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចត្រូវបានផ្តល់ឡើងវិញក្រោយរយៈពេល៥ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។ ដោយឡែកចំពោះបុគ្គល ឬអ្នកវិជ្ជាជីវៈដែលត្រូវតុលាការប្រកាសក្ស័យធន ឬការជម្រះបញ្ជីតាមផ្លូវតុលាការ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាល ឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់វិញ ក្រោយរយៈពេល ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃប្រកាសក្ស័យធន ឬការជម្រះបញ្ជីតាមផ្លូវតុលាការ។ រីបុគ្គល ឬអ្នកវិជ្ជាជីវៈដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាល ឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ គឺបន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។[97]

[97] មាត្រា១៨ ដដែលនៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

# ជំពូកទី២
# ទិដ្ឋភាពនៃការសោចសង់
# សំណង់

# ជំពូកទី២
# ទិដ្ឋភាពនៃការសាងសង់សំណង់

## ២.១. នីតិវិធីនៃដំណាក់កាលមុនការសាងសង់

ជាទូទៅនីតិវិធី និងដំណាក់កាលមុននឹងការចាប់ផ្តើមសាងសង់សាងសង់នូវសំណង់គ្រប់ប្រភេទ គឺមានដំណាក់កាលនីមួយៗយោងតាមទិដ្ឋភាពច្បាប់ និងតាមទំហំ និងប្រភេទនៃសំណង់ ជាពិសេសដំណាក់កាលនៃការស្នើសុំលិខិតអនុញ្ញាតសាងសង់ដែលមានសំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតូចជាង ឬស្មើ៥០០ម៉ែត្រក្រឡា សំណង់មានក្រឡាកម្រាលសំណង់សរុបធំជាង៥០០ម៉ែត្រក្រឡា ដល់៣០០០ម៉ែត្រក្រឡា និងសំណង់ដែលមានក្រឡាកម្រាលសំណង់សរុបធំជាង៣០០០ម៉ែត្រក្រឡា និងរួមទាំងរាល់សំណង់ស្ថានីយប្រេងឥន្ធនៈទាំងអស់។

ដើម្បីសិក្សាឲ្យកាន់តែមានភាពច្បាស់លាស់ និងស៊ីជម្រៅជាងនេះទៅទៀត ខ្ញុំនឹងធ្វើការបកស្រាយលើបីចំណុចសំខាន់ដែលនិយាយអំពីការស្នើសុំលិខិតអនុញ្ញាតសាងសង់ ការស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន និងនិយាយទៅលើស្ថាប័នជំនាញដែលមានសមត្ថកិច្ចនឹងវិស័យសំណង់ ដែលមានតួនាទីពិសេសក្នុងការអន្តរាគមបានទាន់ពេលវេលាប្រសិនបើមានបញ្ហាកើតឡើងដោយចៃដន្យ។

### ២.១.១. ការស្នើសុំលិខិតអនុញ្ញាតសាងសង់

យោងតាមច្បាប់ស្តីពីសំណង់ឆ្នាំ២០១៩ បានចែងកំណត់យ៉ាងច្បាស់ថារាល់ការងារសាងសង់ ឬរុះរើត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច។[98] រាល់ការសាងសង់សំណង់ថ្មី ការកសាងឡើងវិញការពង្រីក និងសាងសង់បន្ថែម ត្រូវមានលិខិតអនុញ្ញាតសាងសង់។

រាល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលចង់ធ្វើការសាងសង់សំណង់នានាដោយតម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់ នោះរូបវន្តបុគ្គល ឬនីតិបុគ្គលនោះត្រូវធ្វើការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់សំណង់របស់ខ្លួនជាមុនសិន។ ហើយមានតែកម្មសិទ្ធិករនៃដី និងអ្នកដែលបានកាន់កាប់ដីស្របច្បាប់ ទើបអាចស្នើសុំលិខិតអនុញ្ញាតសាងសង់សំណង់នៅលើដីនោះបាន។ ការងារសាងសង់នេះផងដែរ មិនអាចអនុញ្ញាតនៅលើដីដែលកំពុងមានវិវាទអំពីសិទ្ធិកាន់កាប់បានឡើយ។[99]

---

[98] មាត្រា២៦ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[99] មាត្រា១៣ នៃអនុក្រឹត្យលេខ២២៤អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

**ក.សំណុំឯកសារសម្រាប់ស្នើសុំលិខិតអនុញ្ញាតសាងសង់**

ចំពោះសំណុំឯកសារសម្រាប់ស្នើសុំលិខិតអនុញ្ញាតសាងសង់ត្រូវធ្វើជាភាសាខ្មែរ និងភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម៖[100]

- ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ចំនួន១ច្បាប់
- ឯកសារបញ្ជាក់អត្តសញ្ញាណម្ចាស់សំណង់(ថតចម្លង) ចំនួន២ច្បាប់
- ឯកសារបញ្ជាក់ការកាន់កាប់ដីស្របច្បាប់(ថតចម្លង) ចំនួន២ច្បាប់
- សលាកបត្រក្បាលដី ចំនួន២ច្បាប់
- លិខិតបញ្ជាក់ព័ត៌មានសុរិយោដី ចំនួន២ច្បាប់
- ប្លង់ស្ថាបត្យកម្ម ចំនួន៥ច្បាប់
- របាយការណ៍ស្តីពីការត្រួតពិនិត្យ និងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម ចំនួន៥ច្បាប់
- លិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់ស្ថាបត្យកម្ម ចំនួន៥ច្បាប់។

**ខ.រយៈពេលសម្រេចរបស់អាជ្ញាធរលើពាក្យសុំលិខិតអនុញ្ញាតសាងសង់**

រូបវន្តបុគ្គលបន្ទាប់ពីបានដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់រួចមកហើយ ត្រូវរង់ចាំការសម្រេចពីអាជ្ញាធរមានសមត្ថកិច្ចដែលបានដាក់ពាក្យសុំនោះ ដែលមានដូចខាងក្រោម៖[101]

- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ក្នុងរយៈពេលយ៉ាងយូរ៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ២៥(ម្ភៃប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។
- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។

[100] ប្រការ៤ នៃប្រកាសលេខ០១៣ ដនស/ប្រ.ក/នី.ក ស្តីពីបែបបទ និងបរិបទនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២២

[101] មាត្រា១៩ នៃអនុក្រឹត្យលេខ២២៤អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

### គ.សុពលភាពនៃលិខិតអនុញ្ញាតសាងសង់

មួយវិញទៀតលិខិតអនុញ្ញាតសាងសង់នេះទៀតសោត នឹងអស់សុពលភាពនៅក្នុងករណីដែលការដ្ឋានសំណង់មិនបានចាប់ផ្ដើមដំណើរការក្នុងរយៈពេល១ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតសាងសង់នោះ។ ក្នុងករណីម្ចាស់សំណង់បានទទួលលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ រយៈពេលនៃសុពលភាពលិខិតអនុញ្ញាតសាងសង់ត្រូវចាប់ផ្ដើមរាប់ឡើងវិញគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតសាងសង់បើកការដ្ឋាននោះ។[102]ប្រសិនបើចង់បន្តសុពលភាព លក្ខខណ្ឌនៃការបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់មានដូចខាងក្រោម៖[103]

- ការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ត្រូវបានផ្ញើមកអាជ្ញាធរមានសមត្ថកិច្ចតាមរយៈយន្តការច្រកចេញចូលតែមួយ ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃមុនថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតសាងសង់
- គ្មានការកែប្រែគម្រោងប្លង់ស្ថាបត្យកម្មដើមនៃលិខិតអនុញ្ញាតសាងសង់
- មិនទាន់មានការចាប់ផ្ដើមសាងសង់នៅការដ្ឋានសំណង់។

### ២.១.២. ការស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់

មុននឹងចាប់ផ្ដើមដំណើរការការដ្ឋានសាងសង់ ម្ចាស់សំណង់ដែលដែលតម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់នោះត្រូវតែមានលិខិតអនុញ្ញាតបើកការដ្ឋានផងដែរ ហើយលិខិតនេះត្រូវតែមានជាមុនសិនទើបអាចបើកការដ្ឋានដើម្បីសាងសង់សំណង់បាន។ ដោយឡែកចំពោះការដ្ឋានសំណង់ដែលបានចាប់ផ្ដើមដំណើរការប៉ុន្តែបានផ្អាកទៅវិញលើសពី១(មួយ)ឆ្នាំត្រូវមានលិខិតបន្តសុពលភាពលិខិតបើកការដ្ឋានសំណង់ មុននឹងបន្តដំណើរសាងសង់ ឬរុះរើ។[104]

### ក.សំណុំឯកសារសម្រាប់ស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់

ចំពោះសំណុំឯកសារសម្រាប់ស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ត្រូវភ្ជាប់មកជាមួយឯកសារដូចជា៖[105]

- ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន ចំនួន១ច្បាប់
- ប្លង់ស្ថាបត្យកម្ម ចំនួន២ច្បាប់
- លិខិតអនុញ្ញាតសាងសង់ ចំនួន១ច្បាប់

[102] មាត្រា២០ នៃអនុក្រឹត្យលេខ២២៤អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០
[103] មាត្រា២០ ដដែលនៃអនុក្រឹត្យលេខ២២៤អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០
[104] មាត្រា៣៧ នៃអនុក្រឹត្យលេខ២២៤អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០
[105] មាត្រា៣៩ នៃអនុក្រឹត្យលេខ២២៤អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

- ប្លង់គ្រឿងបង្គុំ ចំនួន៤ច្បាប់
  - ស្នាមមេដៃ ឬហត្ថលេខា និងឈ្មោះរបស់ម្ចាស់សំណើនៅលើគ្រប់សន្លឹកប្លង់
  - ហត្ថលេខា និងឈ្មោះរបស់វិស្វករគណនា ឬហត្ថលេខា និងត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់នៅលើគ្រប់សន្លឹកប្លង់
  - បញ្ជីសន្លឹកប្លង់
  - ប្លង់គ្រឹះ, លម្អិតគ្រឹះ
  - ធ្នឹមគ្រឹះ, លម្អិតធ្នឹមគ្រឹះ
  - ប្លង់សសរ, លម្អិតសសរ
  - ប្លង់ធ្នឹម, លម្អិតធ្នឹម
  - ប្លង់កម្រាល, លម្អិតកម្រាល
  - ប្លង់ជណ្តើរ, លម្អិតគ្រឿងផ្គុំជណ្តើរ
  - ប្លង់ដំបូល, ធ្នឹមដំបូល
  - លម្អិតគ្រឿងបង្គុំផ្សេងៗ
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ម្ចាស់សំណើ ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណរបស់វិស្វករគណនាគ្រឿងផ្គុំសំណង់ ចំនួន១ច្បាប់
- វិញ្ញាបនបត្រប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ចំនួន១ច្បាប់
- របាយការណ៍សិក្សាពិសោធន៍ដី(ចំពោះគម្រោងធំ ឬអគារខ្ពស់) ចំនួន១ច្បាប់
- និងឯកសារចាំបាច់ដទៃទៀត(បើមាន)។

**ខ.រយៈពេលសម្រេចរបស់អាជ្ញាធរលើពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន**

បន្ទាប់ពីបានដាក់ពាក្យស្នើសុំរួចរាល់ហើយ រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវកំណត់ដូចខាងក្រោម៖[106]

- យ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ផ្តល់ដោយអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

[106] មាត្រា៤០ នៃអនុក្រឹត្យលេខ២២៨អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

- យ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយអង្គភាពច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។
- យ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយការិយាល័យច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**គ.សុពលភាពនៃលិខិតអនុញ្ញាតបើកការដ្ឋាន**

ចំពោះលិខិតអនុញ្ញាតបើកការដ្ឋាននេះផងដែរ នឹងអស់សុពលភាពដែលមានកំណត់ក្នុងអនុក្រឹត្យដែលបានចែងកំណត់ក្នុងករណីណាមួយដូចខាងក្រោម៖[107]

- ការដ្ឋានសំណង់មិនបានចាប់ផ្តើមដំណើរការក្នុងរយៈពេល១ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់នោះ
- មួយវិញទៀតនោះការដ្ឋានសំណង់បានផ្អាកដំណើរការរយៈពេលលើសពី១ឆ្នាំ
- និងលិខិតអនុញ្ញាតសាងសង់ ឬរុះរើអស់សុពលភាព ត្រូវបាននិរាករ ឬប្រកាសមោឃភាពដោយអាជ្ញាធរមានសមត្ថកិច្ច ឬដោយតុលាការ។ ហើយលិខិតអនុញ្ញាតបើកការដ្ឋានសំណង់អាចបន្តសុពលភាពបានតែម្តងគត់។ ដោយឡែកលក្ខខណ្ឌនៃការបន្តសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់រួមមានដូចជា៖
    - ការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ត្រូវធ្វើតាមយន្តការច្រកចេញចូលតែមួយក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ មុនថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់
    - និងគ្មានការកែប្រែគម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់គ្រឿងផ្គុំសំណង់ ឬគម្រោងប្លង់រុះរើនៃលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតរុះរើ ឬលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។

## ២.១.៣. សមត្ថកិច្ចក្នុងការផ្តល់លិខិតអនុញ្ញាត និងស្ថាប័នជំនាញក្នុងវិស័យសំណង់

### ២.១.៣.១. សមត្ថកិច្ចក្នុងការផ្តល់លិខិតអនុញ្ញាត

ការផ្តល់លិខិតអនុញ្ញាតសាងសង់ទៅកាន់រូបវន្តបុគ្គល ដែលជាម្ចាស់សំណង់ដែលសាងសង់នៅលើដីដែលជាកម្មសិទ្ធិរបស់ខ្លួនត្រូវគោរពតាមសមត្ថកិច្ចដែលបទដ្ឋានច្បាប់បានកំណត់ទៅតាមទំហំ និងតាមប្រភេទ

[107] មាត្រា៤១ នៃអនុក្រឹត្យលេខ២២៤អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

នៃសំណង់ដែលក្នុងនោះរួមមានរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងរាជរដ្ឋាភិបាល ឬស្ថាប័នដែលបានទទួលសិទ្ធិប្រទាន។

**ក.រាជរដ្ឋាភិបាល ឬស្ថាប័នតំណាងដែលបានទទួលសិទ្ធិប្រទាន**

រាជរដ្ឋាភិបាល ឬស្ថាប័នតំណាងដែលបានទទួលសិទ្ធិប្រទាន មានសមត្ថកិច្ចផ្តល់ការអនុញ្ញាតឲ្យសាងសង់ ឬរុះរើ ចំពោះសំណង់ដូចខាងក្រោម៖[108]

- សំណង់ដែលជាការសម្ងាត់របស់ជាតិ មានជាអាទិ៍សំណង់សម្រាប់បោះពុម្ពរូបិយបណ្ណ តម្កល់ និងរក្សាទុករូបិយវត្ថុ
- សំណង់សម្រាប់បម្រើដល់សន្តិសុខជាតិ និងការពារជាតិ មានជាអាទិ៍សំណង់លេណដ្ឋាន ឃ្លាំងស្តុកអាវុធ និងគ្រឿងយុទ្ធភណ្ឌ និងសំណង់បម្រើដល់ការប្រយុទ្ធ។

**ខ.រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងសំណង់គ្រប់ប្រភេទ។ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតរុះរើសំណង់ដូចខាងក្រោម៖[109]

- សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបលើសពី ៣០០០(បីពាន់)ម៉ែត្រក្រឡា
- អគារដែលមានកម្ពស់ខ្ពស់ជាង ១១(ដប់មួយ)ជាន់ឡើងទៅរួមទាំងជាន់ផ្ទាល់ដី
- សំណង់ដែលមានជាន់ក្រោមដីក្នុងជម្រៅជ្រៅជាង ៥(ប្រាំ)ម៉ែត្រ
- ការងារសាងសង់ឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់ដែលមានស្រាប់ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មីសរុបលើសពី ៣០០០(បីពាន់)ម៉ែត្រក្រឡា
- ជញ្ជាំងទប់ដីដែលមានកម្ពស់ខ្ពស់ជាង៥(ប្រាំ)ម៉ែត្រ
- ឋបនីយភណ្ឌដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គិភ័យដូចជាស្ថានីយ ឬដេប៉ូស្តុក លក់ ឬចែកចាយប្រេងឥន្ធនៈ ឧស្ម័ន ឬផលិតផលគេលសិលាដទៃទៀត ពោង ឬស៊ីទែនស្តុកប្រេងឥន្ធនៈ ឬឧស្ម័នសារធាតុងាយឆេះ ឬផលិតផលគេលសិលាដទៃទៀត និងរោងជាងដែលមានផលិតផលងាយឆេះ

[108] មាត្រា៧ នៃអនុក្រឹត្យលេខ២២៤អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[109] មាត្រា៤ នៃអនុក្រឹត្យលេខ២២៤អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

- អាងតម្កល់ឬស្តុកទឹកដែលមានកម្ពស់ខ្ពស់ជាង១៥(ដប់ប្រាំ)ម៉ែត្រ ឬមានចំណុះលើសពី ៥០ (ហាសិប)ម៉ែត្រគុប
- សំណង់សម្រាប់បម្រើវិស័យកីឡា ទេសចរណ៍ និងវប្បធម៌ មានជាអាទិ៍ពហុកីឡដ្ឋាន ទីលានវាយកូនហ្គោល ទីលានកីឡាប្រណាំង សួនកម្សាន្ត អាងហែលទឹក សារមន្ទីរ សាលមហោស្រព សាលសន្និសីទ រោងភាពយន្ត
- សំណង់នៅក្នុងតំបន់ការពារបរិស្ថានធម្មជាតិ បេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ ឬតំបន់ការពារផ្សេងទៀត
- អគារ ប៉ម ឬសំណង់នៅក្នុងស្ថានីយអ្នកដំណើរតាមរថយន្ត ស្ថានីយអយស្ម័យាន កំពង់ផែអាកាសយានដ្ឋាន និងស្ថានីយវារីអគ្គិសនី ដែលអ្នកមិនមែនជាផ្នែកនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ឬផ្នែកនៃសំណង់ការងារទឹក
- សំណង់អគារ ប៉ម ឬខ្លោងទ្វារនៅតាមច្រកទ្វារអន្តរជាតិ
- បង្គោលអង់តែនទូរស័ព្ទ និងបង្គោលអង់តែនស្ថានីយវិទ្យុ ឬទូរទស្សន៍
- សំណង់មិនមែនអគារដទៃទៀតដែលមានកម្ពស់ខ្ពស់ជាង ៣០(សាមសិប)ម៉ែត្រ។

**គ.អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

ចំពោះសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត វិញដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ជាសេនាធិការនោះ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតអនុញ្ញាតរុះរើ ចំពោះការងារសំណង់ដូចខាងក្រោម៖[110]

- សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាង ឬស្មើ៣០០០(បីពាន់)ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាង ឬស្មើ១១(ដប់មួយ)ជាន់រួមទាំងជាន់ផ្ទាល់ដី ដោយគ្មាន ឬមានជាន់ក្រោមដីក្នុងជម្រៅរាក់ជាង ឬស្មើ៥(ប្រាំ)ម៉ែត្រ ដោយលើកលែងសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ
- ការងារសាងសង់ឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់ដែលមានស្រាប់ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់ បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មីសរុបលើសពី ៥០០(ប្រាំរយ)ម៉ែត្រក្រឡា និងតិចជាង ឬស្មើ ៣០០០(បីពាន់)ម៉ែត្រក្រឡា

[110] មាត្រា៥ នៃអនុក្រឹត្យលេខ២២៤អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

- ជញ្ជាំងទប់ដីដែលមានកម្ពស់ទាបជាង ឬស្មើ៥(ប្រាំ)ម៉ែត្រ
- របងថ្ម ឬបេតុងដែលមានកម្ពស់ខ្ពស់ជាង៣(បី)ម៉ែត្រ
- សំណង់មិនមែនអគារដទៃទៀតដែលមានកម្ពស់ទាបជាង ឬស្មើ ៣០(សាមសិប)ម៉ែត្រ។

**ឃ.អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**

បន្ថែមលើនេះទៀតនោះចំពោះសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមាន ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាសេនាធិការ មាន សមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និង លិខិតអនុញ្ញាតរុះរើ ចំពោះសំណង់ ឬការងារដូចខាងក្រោម៖[111]

- សំណង់លំនៅឋានដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាង ឬស្មើ៥០០(ប្រាំរយ)ម៉ែត្រ ក្រឡា និងកម្ពស់ទាបជាង ឬស្មើ៤(បួន)ជាន់រួមទាំងជាន់ផ្ទាល់ដី និងគ្មានជាន់ក្រោមដី
- ការងារសាងសង់សំណង់លំនៅឋានឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់ លំនៅឋានដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់បូកផ្ទៃក្រឡាកម្រាលសំណង់ ថ្មីសរុបលើសពីទំហំផ្ទៃក្រឡាកម្រាលសំណង់ដែលមិនតម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់ និង តិចជាង ឬស្មើ៥០០(ប្រាំរយ)ម៉ែត្រក្រឡា
- របងថ្ម ឬបេតុងដែលមានកម្ពស់ទាបជាង ឬស្មើ៣(បី)ម៉ែត្រ។

### ២.១.៣.២. តួនាទីស្ថាប័នជំនាញក្នុងវិស័យសំណង់

ក្នុងវិស័យសំណង់ក៏ដូចគ្នាទៅនឹងវិស័យផ្សេងទៀតដែរ ដែលមានអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធដែល មាននូវសមត្ថកិច្ចគ្រប់គ្រង និងត្រួតពិនិត្យលើវិស័យសំណង់នេះតាមជំនាញរៀងៗខ្លួន។ ទោះបីមានបែបនេះក៏ ពិតមែនតែសមត្ថកិច្ចផ្ទាល់ និងគ្រប់គ្រងលើការងារសំណង់ទាំងមូល និងគ្រប់ផ្នែក គ្រប់ជំនាញគឺ ក្រសួងរៀបចំ-ដែនដី នគរូបនីយកម្ម និងសំណង់ ចំណែកឯស្ថាប័នដទៃទៀតដូចជាក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេស សំណង់ និងក្រសួងមហាផ្ទៃ ដែលស្ថាប័នទាំងពីរនេះមានតួនាទីដោយផ្នែកក្នុងវិស័យសំណង់បន្ថែមលើតួនាទី គោលរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គួរបញ្ជាក់ផងដែរថាមិនមែនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អង្គភាពជំនាញចំណុះក្រសួងនោះទេ តែបញ្ហាខ្លះត្រូវតែធ្វើការជាអន្តរក្រសួងទើប ការងារទាន់សភាពការណ៍ ជាពិសេសក្រសួងមហាផ្ទៃ មិនមែនរំលោភសមត្ថកិច្ចគ្រប់គ្រងនៅតាមផ្នែកនោះទេតែ ជាផ្នែកមួយក្នុងការដោះស្រាយបញ្ហាភ្លាមៗជំនួសឲ្យក្រសួងសាមីទៅតាមបទដ្ឋានច្បាប់ដែលបានកំណត់ ជាក់ស្តែង ឧទាហរណ៍ថាមានករណីភ្លើងឆេះអគារ ដូចនេះក្រសួងមហាផ្ទៃមានសមត្ថកិច្ចក្នុងការអន្តរាគមភ្លាមៗ។

[111] មាត្រា៦ នៃអនុក្រឹត្យលេខ២២៤អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

**ក.ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានឡើងដោយច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំ-ដែនដី នគរូបនីយកម្ម និងសំណង់នៅឆ្នាំ១៩៩៩ ដែលចំណុះឲ្យរាជរដ្ឋាភិបាល និងមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យសំណង់ រៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៃព្រះរាជាណាចក្រកម្ពុជា។[112] លើសពីនេះទៀតដើម្បីប្រសិទ្ធភាពការងារខ្ពស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់ ឬធ្វើប្រតិភូកម្មសមត្ថកិច្ចគ្រប់វិស័យសំណង់ដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[113] ហើយក្រសួងរៀបចំ-ដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចពីរ សមត្ថកិច្ចថ្នាក់កណ្តាល និងសមត្ថកិច្ចថ្នាក់មូលដ្ឋាន។

**ក.១.សមត្ថកិច្ចថ្នាក់កណ្តាល**

ក្នុងន័យនេះជាសមត្ថកិច្ចក្រសួងរៀបចំដែន នគរូបនីយកម្ម និងសំណង់ផ្ទាល់ ដែលមានអគ្គនាយកដ្ឋានសំណង់ដែលជាសេនាធិការមានសមត្ថកិច្ចគ្រប់គ្រងទាំងមូលក្នុងវិស័យសំណង់ ក្នុងនោះមាននាយកដ្ឋានចំនួន៣ដែលចំណុះរួមមាន នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ នាយកដ្ឋានសិក្សាគម្រោងប្លង់ និងនាយកដ្ឋានសំណង់ ដែលទទួលខុសត្រូវលើការងារផ្សេងៗគ្នា។

**ក.១.១.អគ្គនាយកដ្ឋានសំណង់**

តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានសំណង់មានដូចជា៖[114]

- លើកស្ទួយខឿនស្ថាបត្យកម្មក្នុងវិស័យសំណង់ឲ្យមានលក្ខណៈជាតិ និងទំនើបទាន់សម័យ
- ស្រាវជ្រាវរៀបចំបទប្បញ្ញត្តិ ទម្រង់បែបបទ ក្បួនខ្នាត លក្ខណៈវិនិច្ឆ័យបច្ចេកទេសបច្ចេកវិទ្យា បទដ្ឋានបច្ចេកទេសផ្នែកសំណង់ និងស្ថាបត្យកម្ម រួមទាំងស្តង់ដារសម្ភារៈបរិក្ខារសំណង់ឲ្យមានឯកភាព
- តម្រង់ទិស ណែនាំ តាមដាន ត្រួតពិនិត្យការសាងសង់ ការជួសជុល ការថែទាំ ការរុះរើរាល់បណ្តាគម្រោងសំណង់អគាររបស់រដ្ឋ ឯកជន អង្គការនានា រួមទាំងសំណង់បេតិកភណ្ឌ និងសំណង់ផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងដោយប្រកាសអន្តរក្រសួង
- គ្រប់គ្រង ពិនិត្យ កំណត់សមត្ថភាពបច្ចេកវិជ្ជាជីវៈ និងចេញលិខិតអនុញ្ញាតអាជីវកម្មដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលធ្វើអាជីវកម្មទាក់ទងនឹងការសាងសង់ និងការសិក្សាគម្រោងប្លង់

[112] មាត្រា១ និងមាត្រា២ នៃច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩

[113] មាត្រា៥ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[114] មាត្រា១៧ នៃអនុក្រឹត្យលេខ៦២ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩

- ត្រួតពិនិត្យ និងដាក់ឲ្យធ្វើការពិសោធន៍សម្ភារៈសំណង់
- កំណត់ស្តង់ដារគុណភាពសម្ភារៈបរិក្ខារសំណង់ ដែលបាននាំចូលមកពីបរទេស និងផលិតក្នុងប្រទេស
- លើកផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់បុគ្គលិកក្រសួង និងបណ្តាមន្ទីររាជធានីខេត្ត ធ្វើទំនាក់ទំនងណែនាំបច្ចេកទេសដល់បណ្តាគ្រឹះស្ថានបណ្តុះបណ្តាលមុខវិជ្ជាសំណង់ និងស្ថាបត្យកម្ម
- សម្របសម្រួលជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីត្រួតពិនិត្យបណ្តាគម្រោងវិនិយោគសំណង់។

### ក.១.២.នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់

ដូចដែលបានមកស្រាយខាងលើរួចមកហើយអគ្គនាយកដ្ឋានសំណង់មាននាយកដ្ឋានចំណុះចំនួន ៣ (បី) ហើយមានតួនាទី និងភារកិច្ចផ្សេងៗគ្នា។ ទី១ នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ ដែលនឹងលើកមកបកស្រាយបន្តពីអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

តួនាទី និងភារកិច្ចរបស់នាយកដ្ឋានស្រាវជ្រាវបច្ចេកទេស និងសំណង់មានដូចជា៖[115]

- ស្រាវជ្រាវ កសាងបទប្បញ្ញត្តិ ទម្រង់បែបបទ ក្បួនខ្នាត លក្ខណៈវិនិច្ឆ័យបច្ចេកទេស បច្ចេកវិទ្យាបទដ្ឋានបច្ចេកទេសផ្នែកសំណង់ និងស្ថាបត្យកម្ម រួមទាំងសម្ភារៈ បរិក្ខារសំណង់
- កំណត់ស្តង់ដារ ប្រភេទ សំភារៈ បរិក្ខារសំណង់ និងលក្ខណៈវិនិច្ឆ័យបច្ចេកទេស គុណភាពការងារសំណង់ និងចូលរួមផ្តល់យោបល់អំពីគុណភាពសំណង់ តម្រូវការគុណភាពសម្ភារៈបរិក្ខារគ្រឿងចក្រសំណង់ ដែលនាំចូលពីបរទេសតាមការផ្លាស់ប្តូរពាណិជ្ជកម្ម និងផលិតផលក្នុងស្រុក
- ចងក្រងបណ្តាបញ្ជីតម្លៃសម្ភារៈសំណង់ គ្រឿងសំណង់ និងពលកម្ម ដែលប្រែប្រួលតាមខេត្តក្រុង និងតាមដានជាប្រចាំនូវការប្រែប្រួលថ្លៃនៅតាមទីផ្សារទាំងនោះ
- ត្រួតពិនិត្យ និងដាក់អោយធ្វើការពិសោធន៍សម្ភារៈគ្រឿងផ្គុំសំណង់ ដី ព្រមទាំងស្រាវជ្រាវបង្កើតមុខសម្ភារៈសំណង់ថ្មី ដោយប្រើប្រាស់វត្ថុធាតុដើមក្នុងប្រទេសបម្រើអោយលំនៅឋានរបស់ប្រជាពលរដ្ឋ។ ស្រាវជ្រាវជាប្រចាំ សម្ភារៈផលិតចេញថ្មីៗ គ្រឿងចក្របរិក្ខារបម្រើឲ្យការងារសាងសង់ទំនើបៗលើទីផ្សារជាតិ និងអន្តរជាតិ

---

[115] មាត្រា១៨ នៃអនុក្រឹត្យលេខ៦២ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩

- សហការជាមួយនាយកដ្ឋានបុគ្គលិក និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការបណ្តុះ-បណ្តាលជំនាញបច្ចេកទេសដល់បុគ្គលិកក្រសួង និងបណ្តាមន្ទីរខេត្ត ក្រុង។ ចាត់ចែងអប់រំ ផ្សព្វផ្សាយ ឯកសារបច្ចេកទេសសំណង់ដល់គ្រប់មជ្ឈដ្ឋានដើម្បីលើកស្ទួយប្រសិទ្ធភាពសេដ្ឋកិច្ច សុវត្ថិភាព និងសុខមាលភាពសាធារណៈ ព្រមទាំងណែនាំបច្ចេកទេសដល់គ្រឹះស្ថានបណ្តុះ-បណ្តាលមុខវិជ្ជាសំណង់ និងស្ថាបត្យកម្ម។

**ក.១.៣.នាយកដ្ឋានសិក្សាគម្រោងប្លង់**

ដោយឡែកទី២គឺនាយកដ្ឋានសិក្សាគម្រោងប្លង់ ដែលនឹងលើកយកមកបកស្រាយបន្ទាប់ពីនាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់។

តួនាទី និងភារកិច្ចរបស់នាយកដ្ឋានសិក្សាគម្រោងប្លង់ មានដូចជា៖[116]

- សិក្សាគម្រោងប្លង់សាងសង់ថ្មី ជួសជុល កែលំអពង្រីកបើកទូលាយអគាររបស់បណ្តាក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីខេត្ត ក្រុង ដែលប្រើប្រាស់ថវិការបស់ឯកជនអង្គការនានា រួមទាំងអ្នកវិនិយោគទុនក្នុងប្រទេស ឬក្រៅប្រទេស និងអង្គការអន្តរជាតិ។ សិក្សាស្រាវជ្រាវធ្វើគម្រោងប្លង់ដែលចែកចេញជាផ្នែកឯកសារបច្ចេកទេស ស្ថាបត្យកម្ម និងផ្នែកគំនូរប្លង់។
- សិក្សាស្រាវជ្រាវគម្រោងប្លង់ និងធ្វើបញ្ជីប៉ាន់ស្មានសម្ភារៈនៃសំណង់សាធារណៈ
- ត្រួតពិនិត្យគម្រោងប្លង់ស្ថាបត្យកម្ម និងបច្ចេកទេសសំណង់អគារ
- ត្រួតពិនិត្យសៀវភៅបន្ទុកនៃការដ្ឋានសាងសង់
- ត្រួតពិនិត្យបណ្តាគម្រោងប្លង់ អ្នកវិនិយោគនានា អំពីតម្រូវការពិតនៃសម្ភារៈសំណង់នាំចូលជារូបិយបណ្ណ
- គ្រប់គ្រង ត្រួតពិនិត្យ និងកំណត់សមត្ថភាពបច្ចេកទេស និងចេញលិខិតអនុញ្ញាតបើកអាជីវកម្មដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលធ្វើអាជីវកម្មទាក់ទងនឹងការសិក្សាធ្វើគម្រោងប្លង់ និងការសាងសង់។

**ក.១.៤.នាយកដ្ឋានសំណង់**

មួយវិញទៀតទី៣នោះ គឺនាយកដ្ឋានសំណង់ ដែលនឹងលើកមកធ្វើការបកស្រាយបន្ទាប់ពីនាយកដ្ឋានសិក្សាគម្រោងប្លង់។

[116] មាត្រា១៩ នៃអនុក្រឹត្យលេខ៦២ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩

តួនាទី និងភារកិច្ចរបស់នាយកដ្ឋានសំណង់ មានដូចជា៖[117]

- ណែនាំ តាមដាន ត្រួតពិនិត្យរាល់ការងារបច្ចេកទេសក្នុងការសាងសង់ រុះរើតាមដំណាក់កាលនីមួយៗ ដើម្បីធានាសុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈ និងគុណភាពសំណង់
- ចេញលិខិតអនុញ្ញាតបើក និងបិទការដ្ឋានរបស់បណ្តាសហគ្រាស ក្រុមហ៊ុន អង្គភាពសាងសង់នានា
- ចូលរួមធ្វើកោសល្យវិច័យនានា ផ្តល់សំណុំឯកសារបច្ចេកទេសដល់ស្ថាប័នមានសមត្ថកិច្ចក្នុងករណីវិវាទបញ្ហាសាងសង់ រុះរើបាក់ស្រុត និងករណីបទល្មើសផ្សេងទៀត ដែលផ្ទុយនឹងបទដ្ឋានបច្ចេកទេស
- សិក្សាលើបច្ចេកទេសសាងសង់ទំនើប រឹងមាំ មានប្រសិទ្ធភាព ជាសកល និងឆាប់រហ័សដែលកំពុងត្រូវប្រើប្រាស់ នៅប្រទេសនានាពិសេសបណ្តាប្រទេសអាស៊ាន
- រៀបចំបទប្បញ្ញត្តិ សេចក្តីណែនាំក្នុងការជួសជុលថែទាំ ប្រើប្រាស់សំណង់អគារ សាធារណៈ និងបេតិកភណ្ឌ
- គាក់តែងកម្មវិធី និងកសាងគម្រោងថវិកាជួសជុល ថែទាំធំៗ ព្រមទាំងធានាអំពីលក្ខណៈបច្ចេកទេសសំណង់តាមកិច្ចសន្យា
- ស្រង់ស្ថិតិ វិភាគទិន្នន័យសេដ្ឋកិច្ច តម្លៃវប្បធម៌ ក្នុងការប្រើប្រាស់អគារសាធារណៈ និងបេតិកភណ្ឌ
- ណែនាំត្រួតពិនិត្យរាល់ការងារបច្ចេកទេសក្នុងការជួសជុលកែសម្រួល ដើម្បីធានាសុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈ ប្រសិទ្ធភាព សេដ្ឋកិច្ច សោភ័ណភាព គុណភាពសំណង់នៃគ្រប់បណ្តាសំណង់សាធារណៈ និងគ្រប់បណ្តាសំណង់បេតិកភណ្ឌ។

### ក.២ សមត្ថកិច្ចថ្នាក់មូលដ្ឋាន

ជាក់ស្តែងក្នុងវិស័យសំណង់នេះដែរ សមត្ថកិច្ចថ្នាក់មូលដ្ឋាន ត្រូវបានគ្រប់គ្រងដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដែលមានការិយាល័យចំណុះចំនួន៣។ ដោយឡែកនៅថ្នាក់ក្រុង ស្រុកខណ្ឌវិញ មានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។[118]

[117] មាត្រា២០ នៃអនុក្រឹត្យលេខ៦២ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩

[118] ប្រការ២ នៃប្រកាសលេខ៧៦ ប្រក/ដ.ន.ស ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង និងតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩

### ក.២.១.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត មានតួនាទី និងភារកិច្ចដូចខាងក្រោម៖[119]

- អនុវត្តគោលនយោបាយ និងទិសដៅការងាររបស់ក្រសួងដែលក្នុងនោះរួមមាន ការងាររៀបចំដែនដី ការងារនគរូបនីយកម្ម ការងារសំណង់ ការងារសុរិយោដី និងការងារភូមិសាស្ត្រ ដើម្បីធានានូវតុល្យភាព និងស្ថិរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ការពារផលប្រយោជន៍ និងសណ្តាប់ធ្នាប់ជាសាធារណៈ លើកកម្ពស់សោភណភាពសង្គម ការពារសម្បត្តិធម្មជាតិ និងវប្បធម៌ជាតិ
- ចងក្រងឯកសារទិន្នន័យទាក់ទងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រដោយសហការជាមួយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ
- អនុវត្តបទប្បញ្ញត្តិលិខិតបទដ្ឋានបច្ចេកទេសនានារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផ្តល់មតិយោបល់ ពិនិត្យលើការស្នើសុំទីតាំងសាងសង់ ដោយផ្អែកលើលិខិតអនុញ្ញាតរបស់ក្រសួង
- សហការជាមួយអាជ្ញាធរដែនដី អង្គការជាតិ និងអន្តរជាតិ
- ចូលរួមផ្តល់យោបល់អំពីគុណភាពសំណង់ បរិក្ខារ គ្រឿងចក្រ ព្រមទាំងដាក់អោយពិសោធន៍សម្ភារៈ គ្រឿងផ្គុំសំណង់ និងភូគព្ភសាស្ត្រ
- គ្រប់គ្រង តាមដាន ត្រួតពិនិត្យការសិក្សាស្រាវជ្រាវគម្រោងប្លង់ និងសំណង់ បណ្តាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុងសមត្ថកិច្ចរបស់ខ្លួន និងតាមការប្រគល់ភារកិច្ចពីក្រសួង
- ចេញលិខិតអនុញ្ញាតបើក ផ្អាក និងបិទអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ដល់រូបវន្តបុគ្គល និងក្រុមជាងសំណង់ និងពិនិត្យតាមដានសមត្ថភាពបច្ចេកទេសអាជីវកម្ម
- លើកផែនការបណ្តុះបណ្តាលមន្ត្រីជំនាញ
- ណែនាំការងាររៀបចំការដ្ឋានសំណង់ បើក និងបិទការដ្ឋាន
- ចេញលិខិតអនុញ្ញាតសាងសង់

[119] ប្រការ១ នៃប្រកាសលេខ៧៦ ប្រក/ដ.ន.ស ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង និងតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩

- តាមដានអនុវត្តបទប្បញ្ញត្តិសេចក្តីណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការជួសជុល ថែទាំ ប្រើប្រាស់សំណង់អគារ សំណង់ការ្យ និងបេតិកភណ្ឌក្នុងខេត្ត ក្រុង
- គ្រប់គ្រងដីធ្លីគ្រប់ប្រភេទ
- វាស់វែង និងគណនាឋានលេខាស្ថានភាពដី និងក្បាលដីក្នុងក្របខណ្ឌសមត្ថកិច្ច និងក្នុងភូមិ-សាស្ត្ររដ្ឋបាលដែលខ្លួនទទួលខុសត្រូវ
- កសាងប្លង់ដីគ្រប់ប្រភេទ ប្លង់ស្ថានភាពដីទូទៅ ប្លង់សុរិយោដី ប្លង់ក្បាលដី ប្លង់ដីក្នុងទីប្រជុំជន
- ចូលរួមសិក្សា និងកសាងឯកសារពន្ធអាករដី និងលើកគម្រោងចំណូលពន្ធអាករដីប្រចាំឆ្នាំក្នុងទូទាំងខេត្ត ក្រុង ក្នុងសមត្ថកិច្ចរបស់ខ្លួន។

### ក.២.២.ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

បន្ថែមពីលើនេះទៀតមានការិយាល័យមួយដែលចំណុះឲ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ដែលមានសមត្ថកិច្ចលើវិស័យសំណង់ដោយផ្ទាល់នោះ គឺការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានតួនាទី និងភារកិច្ចដូចខាងក្រោម៖[120]

- ប្រមូលទិន្នន័យតាមខេត្ត រាជធានី ដើម្បីចងក្រងបទប្បញ្ញត្តិពលកម្មសំណង់ សម្ភារៈ បរិក្ខារ និងគ្រឿងចក្រសំណង់ និងប្រព័ន្ធវិស្វកម្ម
- ពិនិត្យ និងដាក់ឲ្យពិសោធសម្ភារៈគ្រឿងផ្គុំសំណង់ និងភូគព្ភសាស្ត្រ
- ចូលរួមផ្តល់យោបល់អំពីគុណភាពសំណង់ បរិក្ខារ និងគ្រឿងចក្រសំណង់
- ប្រមូលចងក្រងទិន្នន័យតាមខេត្ត ក្រុង រាជធានី នូវការងារឧត្តុនិយម ភូគព្ភសាស្ត្រ និងជលសាស្ត្រលើកិច្ចការសំណង់
- ចងក្រងបញ្ជីតម្លៃពលកម្ម សម្ភារៈ បរិក្ខារ និងគ្រឿងចក្រសំណង់ដែលប្រែប្រួលតាមខេត្ត ក្រុង
- វាយតម្លៃហេតុផលប៉ះពាល់បរិស្ថានតាមខេត្ត ក្រុង ដើម្បីធ្វើគម្រោងសំណង់
- សិក្សាស្រាវជ្រាវគម្រោងប្លង់ និងធ្វើបញ្ជីប៉ាន់ស្មានសម្ភារៈ និងតម្លៃតាមសមត្ថកិច្ចរបស់ខ្លួន
- ចេញលិខិតអនុញ្ញាតបើកអាជីវកម្ម សិក្សាគម្រោងប្លង់ និងសាងសង់ដល់រូបវន្តបុគ្គល និងក្រុមជាងសំណង់
- ពិនិត្យតាមដានសមត្ថភាពបច្ចេកទេសរបស់រូបវន្តបុគ្គល និងក្រុមជាងសំណង់ដែលប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់

[120] ប្រការ៣ នៃប្រកាសលេខ៧៦ ប្រក/ដ.ន.ស ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង និងតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩

- ធ្វើកោសល្យវិច័យ និងដោះស្រាយវិវាទពាក់ព័ន្ធនឹងសំណង់
- ចូលរួមលើកផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសសំណង់
- ណែនាំការងាររៀបចំការដ្ឋាន ការការពារសុវត្ថិភាពពលកម្ម និងសណ្តាប់ធ្នាប់សាធារណៈ
- ពិនិត្យសៀវភៅបន្ទុកនៃការដ្ឋានសាងសង់
- តាមដានអនុវត្តបទប្បញ្ញត្តិលិខិតបទដ្ឋាន សេចក្តីណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការជួសជុល ថែទាំ ប្រើប្រាស់សំណង់អគារ សំណង់ការ្យ និងបេតិកភណ្ឌ ក្នុងខេត្ត ក្រុង
- តាក់តែងកម្មវិធី និងកសាងគម្រោងថវិកាជួសជុល ថែទាំអគារសាធារណៈរបស់ខេត្ត ក្រុង
- ស្រង់ស្ថិតិ វិភាគទិន្នន័យ សេដ្ឋកិច្ច តម្លៃវប្បធម៌ ក្នុងការប្រើប្រាស់អគារសាធារណៈ និងបេតិកភណ្ឌ
- ណែនាំ និងត្រួតពិនិត្យសុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈ សោភណភាព គុណភាពសំណង់ និងហេតុផលប៉ះពាល់ផ្សេងៗក្នុងការជួសជុល កែសម្រួលបណ្តាសំណង់សាធារណៈ និងបេតិកភណ្ឌ
- ចេញលិខិតអនុញ្ញាតជួសជុល និងរុះរើអគារលំនៅឋាន និងអគារសាធារណៈ។

### ក.២.៣.ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល

ដោយឡែកចំពោះសមត្ថកិច្ចលើវិស័យសំណង់នៅថ្នាក់ក្រុង ស្រុក ខណ្ឌវិញ ត្រូវបានគ្រប់គ្រងដោយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ដែលជាសេនាធិការឲ្យមន្ទីររៀបចំដែន នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត។ លើសពីនេះការិយាល័យរៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ មានតួនាទី និងភារកិច្ចដូចជា៖[121]

- ចុះពិនិត្យជាក់ស្តែងរាល់សំណើសុំសាងសង់ ជួសជុលសំណង់ដើម្បីធ្វើរបាយការណ៍បច្ចេកទេស
- តាមដានត្រួតពិនិត្យការអនុវត្តលិខិតអនុញ្ញាតសាងសង់ រុះរើ និងជួសជុល
- ពិនិត្យ និងធ្វើរបាយការណ៍បច្ចេកទេសលើបណ្តាវិវាទផ្ទះសម្បែង និងដីធ្លី
- ផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធនឹងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ
- ធ្វើការអង្កេតវាស់វែងដីធ្លី ប្រមូលផ្តុំចងក្រងឯកសារក្នុងក្របខណ្ឌសមត្ថកិច្ចដែលបានកំណត់
- ចុះបញ្ជីអចលនវត្ថុតាម ស្រុក ខណ្ឌ ឃុំ សង្កាត់
- អនុវត្តគម្រោងចំណូលដែលថ្នាក់លើសម្រេច ប្រថាប់ត្រា ផ្ទេរសិទ្ធិផ្សេងៗពាក់ព័ន្ធសំណង់ និងដីធ្លី

[121] ប្រការ៣ នៃប្រកាសលេខ៧៦ ប្រក/ដ.ន.ស ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង និងតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩

- គ្រប់គ្រងការងារលិខិតចេញចូល បញ្ជូនឯកសារ សរុបរបាយការណ៍តាមរបបកំណត់។

ជារួមមកបានបង្ហាញឲ្យឃើញថារចនាសម្ព័ន្ធនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះវិស័យសំណង់មានការបែងចែកទៅតាមផ្នែក និងបច្ចេកទេសរបស់ស្ថាប័ននីមួយៗ និងទៅតាមសមត្ថកិច្ចរៀងៗខ្លួនតាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធវិស័យសំណង់នេះផងដែរ។ ជាពិសេសផងដែរនោះដោយភាពកើនឡើងនូវវិស័យសំណង់ទាំងក្នុងក្រុង និងក្រៅក្រុងនៃព្រះរាជាណាចក្រកម្ពុជាទើបមានការបង្កើតឡើងនូវរចនាសម្ព័ន្ធទាំងអស់នេះដើម្បីងាយស្រួលក្នុងការគ្រប់គ្រង។

### ខ.ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់មួយត្រូវបានបង្កើតឡើង យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធាន ព្រមទាំងមានតំណាងក្រសួងស្ថាប័ន និងវិស័យឯកជនពាក់ព័ន្ធជាសមាជិក ហើយក្រុមប្រឹក្សានេះមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ។

#### ខ.១.សមាសភាពនៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់នេះ រួមមានសមាសភាពដូចខាងក្រោម៖[122]

- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន
- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល អនុប្រធាន
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប អនុប្រធានប្រចាំការ
- រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍១រូប សមាជិក
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប សមាជិក

[122] មាត្រា២ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២

- រដ្ឋលេខាធិការសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ១រូប សមាជិក
- អគ្គលេខាធិការនៃគណៈវិស្វករកម្ពុជា សមាជិក
- អគ្គលេខាធិការនៃគណៈស្ថាបត្យករកម្ពុជា សមាជិក
- អគ្គនាយកវិទ្យាស្ថានស្តង់ដារកម្ពុជា សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- អគ្គនាយកមន្ទីរពិសោធន៍ជាតិសំណង់ សមាជិក
- តំណាងគ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានស្រាវជ្រាវពាក់ព័ន្ធមួយចំនួន សមាជិក
- ប្រធានសមាគមអ្នកសាងសង់កម្ពុជា សមាជិក
- ប្រធានសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា សមាជិក
- ប្រធានសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា សមាជិក
- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ សមាជិកអចិន្ត្រៃយ៍។

### ខ.២.តួនាទី និងភារកិច្ចក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់មានតួនាទី និងភារកិច្ចដូចខាងក្រោម៖[123]

- រៀបចំ និងលើកសំណើជូនរាជរដ្ឋាភិបាលដើម្បីដាក់ឲ្យប្រើបទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់
- ផ្តល់យោបល់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីដាក់ឲ្យប្រើបទប្បញ្ញត្តិបច្ចេកទេសសំណង់ដទៃទៀត ស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច សង្គម បរិស្ថាន បច្ចេកវិទ្យា និងវិទ្យាសាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជា
- តាមដានការអនុវត្ត និងលើកសំណើឬផ្តល់យោបល់កែសម្រួលបទប្បញ្ញត្តិបច្ចេកទេសសំណង់ដើម្បីឲ្យស្របតាមការវិវឌ្ឍសេដ្ឋកិច្ច សង្គម បរិស្ថាន បច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃប្រទេសកម្ពុជា

[123] មាត្រា៣ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីការៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២

- កំណត់វិធាន និងផ្តល់គោលការណ៍ណែនាំក្នុងការសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍បទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- ធ្វើកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានស្រាវជ្រាវ អ្នកស្រាវជ្រាវ និងវិស័យឯកជន ដើម្បីសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍បទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- ធ្វើកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ដើម្បីកៀរគរធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ដើម្បីគាំទ្រសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍បទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកវិជ្ជាជីវៈ និងសាធារណៈជនអំពីបទប្បញ្ញត្តិបច្ចេកទេសសំណង់
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។

**ខ.៣.ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់**

ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ក្នុងកិច្ចការទូទៅត្រូវដឹកនាំដោយប្រធានមួយរូប តែក្នុងករណីអវត្តមាន ប្រធាន ក.ជ.ប.ស.[124] អាចប្រគល់សិទ្ធិជូនអនុប្រធាន ក.ជ.ប.ស. ណាម្នាក់ឲ្យទទួលដឹកនាំការងារប្រចាំថ្ងៃរបស់ ក.ជ.ប.ស. ក្នុងឋានៈជាប្រធានស្តីទីរហូតដល់មានវត្តមានប្រធានវិញ។[125]ចំណែកការប្រជុំវិញ ក.ជ.ប.ស. ត្រូវរៀបចំការប្រជុំរបស់ខ្លួនយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ តែក្នុងករណីចាំបាច់ក្រុមប្រឹក្សានេះអាចកោះប្រជុំវិសាមញ្ញតាមការកោះអញ្ជើញរបស់ប្រធាន ក.ជ.ប.ស.។[126] ដោយឡែករាល់ដំណើរការរៀបចំ និងប្រព្រឹត្តទៅ និងការគ្រប់គ្រងលើវិស័យសំណង់របស់ក្រុមប្រឹក្សានេះមានអគ្គលេខាធិការដ្ឋាន និងមាននាយកដ្ឋានពាក់ព័ន្ធនឹងវិស័យសំណង់ជាសេនាធិការទៅតាមអង្គភាពចំណុះរៀងខ្លួន និងជាសេនាធិការជូន ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយផ្ទាល់។

មួយវិញទៀតរីឯប្រភពធនធានវិញនោះសម្រាប់អនុវត្តសកម្មភាពការងារ គឺថវិកាជាតិ នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក.ជ.ប.ស. មានសិទ្ធិទទួល និងគ្រប់គ្រង

[124] ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

[125] មាត្រា៤ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីការៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២

[126] មាត្រា៥ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីការៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២

តាមនីតិវិធីហិរញ្ញវត្ថុជាធរមាននូវមូលនិធិដែលបានមកពីហិរញ្ញប្បទានឥតសំណង ជំនួយបច្ចេកទេស និងមកពីប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់បំពេញភារកិច្ចរបស់ខ្លួនឲ្យមានប្រសិទ្ធភាព។[127]

### ខ.៣.១.អគ្គលេខាធិការដ្ឋាន

លើសពីនេះទៀតនោះសម្រាប់ដំណើរការការងារប្រចាំថ្ងៃ ក.ជ.ប.ស. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូប និងមានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។ ហើយអគ្គលេខាធិការដ្ឋាននៃ ក.ជ.ប.ស. មានតួនាទី និងភារកិច្ចដូចខាងក្រោម៖[128]

- ផ្តួចផ្តើម សិក្សា ស្រាវជ្រាវ អភិវឌ្ឍ និងចងក្រងបទដ្ឋានបច្ចេកទេសសំណង់
- លើកសំណើជូន ក.ជ.ប.ស. ដើម្បីត្រួតពិនិត្យសម្រេច ឬកែសម្រួលបទប្បញ្ញត្តិបច្ចេកទេសសំណង់
- រៀបចំផែនការគម្រោងកម្មវិធីបណ្តុះបណ្តាលអំពីបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ដល់មន្ត្រីជំនាញ អ្នកវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានស្រាវជ្រាវ និងវិស័យឯកជនពាក់ព័ន្ធ
- រៀបចំកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា ដើម្បីពិគ្រោះយោបល់ អភិវឌ្ឍន៍ បញ្ជ្រាប ឬផ្សព្វផ្សាយបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- តាមដាន ត្រួតពិនិត្យ និងធ្វើរបាយការណ៍វាយតម្លៃអំពីផលប៉ះពាល់ និងប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាននៃការអនុវត្តបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិសម្រាប់ការអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ និងបច្ចេកទេស ដើម្បីធានាប្រសិទ្ធភាពនៃកិច្ចដំណើរការរដ្ឋបាលទូទៅរបស់ ក.ជ.ប.ស.
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងធនធាន និងហិរញ្ញវត្ថុរបស់ ក.ជ.ប.ស.

[127] មាត្រា៨ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីការៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២

[128] មាត្រា២ នៃអនុក្រឹត្យលេខ១០៤ អនក្រ.បក ស្តីពីការៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២

- ធ្វើកំណត់ហេតុ និងរៀបចំរបាយការណ៍នៃកិច្ចប្រជុំរបស់ ក.ជ.ប.ស.
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនប្រធាន ក.ជ.ប.ស.
- និងអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន ក.ជ.ប.ស. ។

### ខ.៣.២.នាយកដ្ឋានគ្រឿងផ្គុំសំណង់

មួយវិញទៀតដែលត្រូវលើកយកមកបកស្រាយបន្ទាប់ពីអគ្គលេខាធិការដ្ឋាននោះ គឺនាយកដ្ឋានគ្រឿងផ្គុំសំណង់។ ដែលនាយកដ្ឋាននេះមានភារកិច្ចដូចតទៅ៖[129]

- សិក្សា ស្រាវជ្រាវ តាក់តែង ប្រមូល និងចងក្រងបទដ្ឋានបច្ចេកទេសសំណង់ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកបន្ទុក និងផ្នែកសម្ភារៈសំណង់ និងផលិតផលសំណង់
- ផ្តួចផ្តើម និងលើកសំណើសុំការសម្រេចលើបទប្បញ្ញត្តិបច្ចេកទេសសំណង់ ផ្នែកគ្រឿងផ្គុំសំណង់
- តាមដាន និងវាយតម្លៃការអនុវត្តបទដ្ឋានបច្ចេកទេសសំណង់ បទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកបន្ទុក និងផ្នែកសម្ភារៈសំណង់ និងផលិតផលសំណង់ និងលើកសំណើសុំកែសម្រួលបទប្បញ្ញត្តិបច្ចេកទេសសំណង់
- សិក្សាស្រាវជ្រាវ និងរៀបចំតាក់តែងគោលការណ៍ណែនាំអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកបន្ទុក និងផ្នែកសម្ភារៈសំណង់ និងផលិតផលសំណង់
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានស្រាវជ្រាវ និងវិស័យឯកជន ដើម្បីសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍បទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកបន្ទុក ផ្នែកសម្ភារៈសំណង់ និងផលិតផលសំណង់
- រៀបចំផែនការ គម្រោង និងកម្មវិធីបណ្តុះបណ្តាលអំពីបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកបន្ទុក និងផ្នែកសម្ភារៈសំណង់ និងផលិតផលសំណង់ដល់មន្ត្រីជំនាញ អ្នកវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានស្រាវជ្រាវ និងវិស័យឯកជនពាក់ព័ន្ធ
- គ្រប់គ្រងការងាររដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់នាយកដ្ឋាន

[129] មាត្រា១០ នៃអនុក្រឹត្យលេខ១០៤ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២

- រៀបចំផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- និងអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ។

### ខ.៣.៣.នាយកដ្ឋានសេវាកម្មសំណង់

ចំណែកឯទី៣វិញនោះ ដែលត្រូវលើកយកមកធ្វើការបកស្រាយបន្ទាប់ពីនាយកដ្ឋានគ្រឿងផ្គុំសំណង់ គឺនាយកដ្ឋានសេវាកម្មសំណង់។ ដែលមានភារកិច្ចដូចតទៅ៖[130]

- សិក្សាស្រាវជ្រាវ តាក់តែង ប្រមូល និងចងក្រងបទដ្ឋានបច្ចេកទេសសំណង់ផ្នែកប្រព័ន្ធមេកានិក ផ្នែកប្រព័ន្ធអគ្គិសនី ផ្នែកប្រព័ន្ធទឹក ផ្នែកប្រព័ន្ធព័ត៌មានវិទ្យា និងទូរគមនាគមន៍ ផ្នែកប្រព័ន្ធអ៊ីសូឡង់ និងសំឡេង និងបទដ្ឋានបច្ចេកទេសសំណង់ពាក់ព័ន្ធនឹងសេវាកម្មសំណង់ដទៃទៀតដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច សង្គម បរិស្ថាន បច្ចេកវិទ្យា និងវិទ្យាសាស្ត្រ
- ផ្តួចផ្តើមនិងលើកសំណើសុំការសម្រេចលើបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកប្រព័ន្ធមេកានិក ផ្នែកប្រព័ន្ធអគ្គិសនី ផ្នែកប្រព័ន្ធទឹក ផ្នែកប្រព័ន្ធព័ត៌មានវិទ្យា និងទូរគមនាគមន៍ ផ្នែកប្រព័ន្ធអ៊ីសូឡង់ និងសំឡេង
- តាមដាន និងវាយតម្លៃការអនុវត្តបទដ្ឋានបច្ចេកទេសសំណង់ បទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកប្រព័ន្ធមេកានិក ផ្នែកប្រព័ន្ធអគ្គិសនី ផ្នែកប្រព័ន្ធទឹក ប្រព័ន្ធព័ត៌មានវិទ្យា និងទូរគមនាគមន៍ ផ្នែកប្រព័ន្ធអ៊ីសូឡង់ និងសំឡេង និងបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ពាក់ព័ន្ធនឹងសេវាកម្មសំណង់ដទៃទៀត និងលើកជាសំណើសុំកែសម្រួលបទប្បញ្ញត្តិបច្ចេកទេសសំណង់
- សិក្សាស្រាវជ្រាវ និងរៀបចំតាក់តែងគោលការណ៍ណែនាំអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកប្រព័ន្ធមេកានិក ផ្នែកប្រព័ន្ធអគ្គិសនី ផ្នែកប្រព័ន្ធទឹក ប្រព័ន្ធព័ត៌មានវិទ្យា និងទូរគមនាគមន៍ ផ្នែកប្រព័ន្ធអ៊ីសូឡង់ សំឡេង និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ពាក់ព័ន្ធនឹងសេវាកម្មសំណង់ដទៃទៀត
- រៀបចំផែនការ គម្រោង កម្មវិធីបណ្តុះបណ្តាលអំពីបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកប្រព័ន្ធមេកានិក ផ្នែកប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធព័ត៌មានវិទ្យា

[130] មាត្រា១២ នៃអនុក្រឹត្យលេខ១០៤ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២

និងទូរគមនាគមន៍ ផ្នែកប្រព័ន្ធអ៊ីសូឡង់ដល់មន្ត្រីជំនាញ អ្នកវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានស្រាវជ្រាវ និងវិស័យឯកជនពាក់ព័ន្ធ និងបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ពាក់ព័ន្ធនឹងសេវាកម្មសំណង់ដទៃទៀត។

**គ.ក្រសួងមហាផ្ទៃ**

ក្រៅពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងលើការងារទូទៅក្នុងវិស័យសំណង់នោះ ក្រសួងមហាផ្ទៃក៏មានសមត្ថកិច្ចក្នុងការធានាឲ្យបាននូវសុវត្ថិភាពនៃសំណង់អគារផងដែរក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើបញ្ហាប្រព័ន្ធសុវត្ថិភាពអគ្គិភ័យរបស់សំណង់។ អគ្គិភ័យក្នុងន័យនេះសំដៅលើករណីភ្លើងឆេះមិនអាចគ្រប់គ្រងបានដែលធ្វើឲ្យបង្កផលប៉ះពាល់ធ្ងន់ធ្ងរ បង្កគ្រោះមហន្តរាយដល់អាយុជីវិត និងទ្រព្យសម្បត្តិ។ មួយវិញទៀតដើម្បីសម្រួលការគ្រប់គ្រងកិច្ចការងារនេះឲ្យបានលឿន ក្រសួងមហាផ្ទៃធ្វើប្រតិភូកម្មអំណាចដល់អគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដើម្បីគ្រប់គ្រង និង ត្រួតពិនិត្យលើប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យរាល់សំណង់ និងគោលដៅដែលតម្រូវឲ្យមានប្លង់ប្រព័ន្ធបង្ការ។[131]

**គ.១.អគ្គស្នងការដ្ឋាននគរបាលជាតិ**

សំណង់តម្រូវឲ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យស្ថិតនៅក្រោមសមត្ថកិច្ចរបស់អគ្គស្នងការដ្ឋាននគរបាលជាតិរួមមានដូចជា៖[132]

- សំណង់ដែលមានផ្ទៃកម្រាលចាប់ពី៣០០០(បីពាន់)ម៉ែត្រក្រឡា និងមានកម្ពស់ចាប់ពី ៥(ប្រាំ)ជាន់ឡើង ដោយរាប់បញ្ចូលទាំងជាន់ក្រោមដី និងផ្ទុកចំនួនមនុស្សចាប់ពី ២០០(ពីររយ)នាក់ និងចំនួនបន្ទប់ចាប់ពី២៥(ម្ភៃប្រាំ)បន្ទប់ និងចំណតរថយន្តចាប់ពី ១០០(មួយរយ)គ្រឿង។
- ស្ថានីយប្រេងឥន្ធនៈ ដេប៉ូប្រេង ពោងស្តុកប្រេងឥន្ធនៈ ទីតាំងលក់ឧស្ម័នចំហេះ និងគោលដៅផលិតកែច្នៃសារធាតុងាយផ្ទុះ ងាយឆេះ និងងាយផ្ទុះឆេះគ្រប់ប្រភេទចំណុះចាប់ពី ១០០០០(មួយម៉ឺន)លីត្រ និង ៥០០០(ប្រាំពាន់)គីឡូក្រាមឡើង។
- និងសំណង់សំខាន់ៗដែលស្ថិតនៅក្នុងតំបន់ការពារបរិស្ថានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ រមណីយដ្ឋានទេសចរណ៍ និងសាសនា។

**គ.២.ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

[131] មាត្រា៧ នៃអនុក្រឹត្យលេខ៨៧ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឲ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨

[132]មាត្រា១៣ នៃអនុក្រឹត្យលេខ៨៧ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឲ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨

ដោយឡែកចំពោះសំណង់ដែលតម្រូវឲ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យស្ថិតនៅក្រោមសមត្ថកិច្ចរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្តរួមមានដូចជា៖[133]

- សំណង់ និងគោលដៅទាំងឡាយណាដែលមានផ្ទៃក្រឡាកម្រាល ៣០០០(បីពាន់)ម៉ែត្រក្រឡា និងមានកម្ពស់៤(បួន)ជាន់ចុះក្រោម ដោយរាប់បញ្ចូលទាំងជាន់ក្រោមដី និងផ្ទុកចំនួនមនុស្សក្រោម២០០(ពីររយ)នាក់ ចំនួនបន្ទប់ក្រោម២៥(ម្ភៃប្រាំ)បន្ទប់ និងចំណតរថយន្តក្រោម ១០០(មួយរយ)គ្រឿង។
- ស្ថានីយប្រេងឥន្ធនៈ ដេប៉ូប្រេង ពោងស្តុកប្រេងឥន្ធនៈ ទីតាំងលក់ឧស្ម័នចំហេះ និងគោលដៅផលិតកែច្នៃសារធាតុងាយផ្ទុះ ងាយឆេះ និងងាយផ្ទុះឆេះគ្រប់ប្រភេទ ចំណុះក្រោម១០០០០(មួយម៉ឺន)លីត្រ និង៥០០០(ប្រាំពាន់)គីឡូក្រាម។

## ២.២. នីតិវិធីនៃដំណាក់កាលពេលសាងសង់ និងក្រោយពេលសាងសង់

### ២.២.១. ការត្រួតពិនិត្យដំណើរការសាងសង់

នៅក្នុងដំណាក់កាល ការងារសាងសង់ត្រូវមានការរៀបចំការត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យដែលមានអាជ្ញាបណ្ណ ឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[134] លើសពីនេះនៅក្នុងករណីចាំបាច់ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីធ្វើការត្រួតពិនិត្យការងារសាងសង់នោះបាន។ ដោយឡែកចំពោះការងារគ្រប់គ្រង និងពិនិត្យការងារសាងសង់នេះនឹងត្រូវកំណត់នៅក្នុងអនុក្រឹត្យ។

#### ២.២.១.១. ប្រភេទ និងកម្រិតនៃអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់

ដូចដែលអនុក្រឹត្យលេខ២២៥ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យបញ្ជាក់សំណង់ បានចែងថា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានសមត្ថកិច្ចគ្រប់គ្រងលើការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់។ ជាក់ស្តែងចំពោះអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់មាន៤ប្រភេទដូចខាងក្រោម៖[135]

- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ទូទៅ
- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្ម
- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់

[133]មាត្រា១៤ នៃអនុក្រឹត្យលេខ៨៧ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឲ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨

[134] មាត្រា៤១ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[135] មាត្រា៥ នៃអនុក្រឹត្យលេខ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក។

បន្ថែមពីលើនេះទៀតចំពោះអាជ្ញាបណ្ណទាំងបួនប្រភេទនេះ ក្នុងមួយប្រភេទមានបែងចែកចេញជាកម្រិតផ្សេងៗគ្នាទៅតាមប្រភេទអាជ្ញាបណ្ណផងដែរ។

អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ទូទៅនេះ មាន២កម្រិតដូចខាងក្រោម៖[136]

- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត១៖ គឺសម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យការងារ និងបញ្ជាក់សំណង់សម្រាប់គ្រឿងផ្គុំសំណង់គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងសម្រាប់ការងារសាងសង់រុះរើផ្នែកគ្រឿងផ្គុំសំណង់សម្រាប់សំណង់គ្រប់ប្រភេទ។
- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត២៖ គឺសម្រាប់ផ្តល់ជូនក្រុមហ៊ុនអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្ម មាន៣កម្រិតដូចខាងក្រោម៖[137]

- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត១៖ គឺសម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ស្ថាបត្យកម្ម និងសម្រាប់ការងារសាងសង់ ឬរុះរើផ្នែកស្ថាបត្យកម្មសម្រាប់សំណង់គ្រប់ប្រភេទ។
- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត២៖ គឺសម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ស្ថាបត្យកម្ម និងសម្រាប់ការងារសាងសង់ ឬរុះរើផ្នែកស្ថាបត្យកម្មនៃសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត៣៖ គឺសម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ស្ថាបត្យកម្ម និងសម្រាប់ការងារសាងសង់ ឬរុះរើផ្នែកស្ថាបត្យកម្មនៃសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់ មាន៣កម្រិតដូចខាងក្រោម៖[138]

[136] មាត្រា៦ នៃអនុក្រឹត្យលេខ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០
[137] មាត្រា៧ នៃអនុក្រឹត្យលេខ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០
[138] មាត្រា៨ នៃអនុក្រឹត្យលេខ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត១៖ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គ្រឿងផ្គុំសំណង់ គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងការងារសាងសង់ឬរុះរើផ្នែកគ្រឿងផ្គុំសំណង់សម្រាប់សំណង់គ្រប់ប្រភេទ។
- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត២៖សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គ្រឿងផ្គុំសំណង់ គម្រោងប្លង់គ្រឿងផ្គុំសំណង់ដែលលិខិតអនុញ្ញាតសាងសង់ ឬរុះរើផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត៣៖ សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គ្រឿងផ្គុំសំណង់ គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងការងារសាងសង់ ឬរុះរើផ្នែកគ្រឿងផ្គុំសំណង់សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក មាន៣កម្រិតដូចខាងក្រោម៖[139]

- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹកកម្រិត១៖ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី និងទឹកសម្រាប់សំណង់គ្រប់ប្រភេទ។
- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹកកម្រិត២៖ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី និង ទឹក និងការងារសាងសង់ ឬរុះរើផ្នែកមេកានិក អគ្គិសនី និងទឹកសម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹកកម្រិត៣៖ សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈតាមមុខជំនាញផ្នែកមេកានិក អគ្គិសនី ឬទឹកដើម្បីអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី ឬទឹក និងការងារសាងសង់ ឬរុះរើផ្នែកមេកានិក អគ្គិសនី ឬទឹកសម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

[139] មាត្រា៨ នៃអនុក្រឹត្យលេខ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

### ២.២.១.២. នីតិវិធីនៃការផ្តល់អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់

ពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងទៅដាក់នៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហើយបន្តទៀតរដ្ឋមន្ត្រីក្រសួងរៀបចំ-ដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ក្នុងរយៈពេលយ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការដោយគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។[140]

**ក.សំណុំឯកសារសម្រាប់ស្នើសុំអាជ្ញាបណ្ណអ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់**

ចំពោះសំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈរួមមានដូចខាងក្រោម៖[141]

- ពាក្យស្នើសុំអាជ្ញាបណ្ណ ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន(ថតចម្លង) ចំនួន១ច្បាប់
- សញ្ញាបត្រ(ថតចម្លង) ចំនួន១ច្បាប់
- ឯកសារបញ្ជាក់បទពិសោធន៍ការងារ(ថតចម្លង) ចំនួន១ច្បាប់
- វិញ្ញាបនបត្រធានារ៉ាប់រង ឬឯកសារបញ្ជាក់ការតម្កល់ប្រាក់នៅធនាគារជាតិនៃកម្ពុជា ចំនួន១ច្បាប់
- លិខិតធានាអះអាងរបស់អ្នកស្នើសុំអាជ្ញាបណ្ណ ចំនួន១ច្បាប់

ចំពោះសំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុនរួមមានដូចខាងក្រោម៖[142]

- ឯកសារពាក់ព័ន្ធនឹងក្រុមហ៊ុន
- ពាក្យស្នើសុំអាជ្ញាបណ្ណ ចំនួន១ច្បាប់
- លក្ខន្តិកៈក្រុមហ៊ុន(ថតចម្លង) ចំនួន១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម(ថតចម្លង) ចំនួន១ច្បាប់
- បញ្ជីរាយនាមនាយកបច្ចេកទេស និងអ្នកបច្ចេកទេស ចំនួន១ច្បាប់
- វិញ្ញាបនបត្រធានារ៉ាប់រង ឬឯកសារបញ្ជាក់ការតម្កល់ប្រាក់នៅធនាគារជាតិនៃកម្ពុជា ចំនួន១ច្បាប់

[140] មាត្រា២៥ នៃអនុក្រឹត្យលេខ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[141] ប្រការ៣ នៃប្រកាសលេខ០៣៣ ដ.ន.ស./ប្រ.ក.នី.ក ស្តីពីបែបបទ និងបរិបទនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

[142] ប្រការ៤ នៃប្រកាសលេខ០៣៣ ដ.ន.ស./ប្រ.ក.នី.ក ស្តីពីបែបបទ និងបរិបទនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

- ឯកសារពាក់ព័ន្ធនឹងអភិបាលរបស់ក្រុមហ៊ុនអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន និងទិដ្ឋាការ(ថតតចម្លង) ចំនួន១ច្បាប់
- ឯកសារពាក់ព័ន្ធនឹងនាយកបច្ចេកទេស និងអ្នកបច្ចេកទេស
    - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន និងទិដ្ឋាការ(ថតចម្លង) ចំនួន១ច្បាប់
    - សញ្ញាបត្រ(ថតចម្លង) ចំនួន១ច្បាប់
    - ឯកសារបញ្ជាក់បទពិសោធន៍ការងារ(ថតចម្លង) ចំនួន១ច្បាប់
    - វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈ(ថតចម្លង) ចំនួន១ច្បាប់
    - លិខិតធានាអះអាងរបស់នាយកបច្ចេកទេស ចំនួន១ច្បាប់

**ខ.រយៈពេលសម្រេចរបស់អាជ្ញាធរលើពាក្យសុំអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់**

ការពិនិត្យ និងសម្រេចលើសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ មានរយៈពេលយ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ តាមបរិបថដូចខាងក្រោម៖[143]

- ច្រកចេញចូលតែមួយត្រូវបញ្ជូនសំណុំឯកសារស្នើសុំទៅអគ្គនាយកដ្ឋានសំណង់ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។
- អគ្គនាយកដ្ឋានសំណង់ដែលមាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ជាសេនាធិការត្រូវធ្វើកំណត់បង្ហាញស្តីពីសំណុំឯកសារស្នើសុំអាជ្ញាបណ្ណដោយមានភ្ជាប់សេចក្តីព្រាងអាជ្ញាបណ្ណក្នុងរយៈពេលយ៉ាងយូរ ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំពីច្រកចេញចូលតែមួយ។
- កំណត់បង្ហាញស្តីពីសំណុំឯកសារស្នើសុំអាជ្ញាបណ្ណនេះ ត្រូវឆ្លងថ្នាក់ដឹកនាំតាមឋានានុក្រមដើម្បីទទួលមតិយោបល់ និងការសម្រេចរបស់ក្រសួង ក្នុងរយៈពេលយ៉ាងយូរ៦(ប្រាំមួយ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំអគ្គនាយកដ្ឋានសំណង់។
- ច្រកចេញចូលតែមួយត្រូវចាត់ចែងចុះលេខ កាលបរិច្ឆេទ និងបោះត្រានៅលើសេចក្តីព្រាងអាជ្ញាបណ្ណ ដើម្បីប្រគល់ជូនម្ចាស់សំណើ ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានការសម្រេចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

[143] ប្រការ១១ នៃប្រកាសលេខ០៣៣ ដ.ន.ស./ប្រ.ក.នី.ក ស្តីពីបែបបទ និងបរិបទនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

ដោយឡែកអ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់វិញត្រូវបង់កម្រៃសេវា ហើយកម្រៃសេវានេះត្រូវបង់នៅពេលទទួលបង្កាន់ដៃទទួលពាក្យស្នើសុំ និងមិនអាចប្រគល់ជូនម្ចាស់សំណើវិញឡើយ ទោះក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចសម្រេចបដិសេធផ្តល់ការអនុញ្ញាតជូនម្ចាស់សំណើក៏ដោយ។[144]

**២.២.១.៣. លក្ខខណ្ឌនៃការអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់**

អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ ត្រូវធ្វើការត្រួតពិនិត្យ និងវិភាគទៅលើទម្រង់ ការគណនា ការអនុវត្តបទប្បញ្ញត្តិ និងការប្រតិបត្តិការងារ ដើម្បីធ្វើការបញ្ជាក់អំពីអនុលោមភាពនៃគម្រោងប្លង់ អនុលោមភាពនៃការងារសាងសង់ ឬរុះរើ ឬអនុលោមភាពនៃសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិដទៃទៀត។

ចំពោះសំណង់ និងការងារសំណង់ដែលតម្រូវឲ្យមានការត្រួតពិនិត្យ និងបញ្ជាក់សំណង់នោះរួមមានដូចខាងក្រោម៖[145]

- គម្រោងប្លង់ប្រើប្រាស់សម្រាប់ការងារសាងសង់ ឬរុះរើ មុនអាជ្ញាធរមានសមត្ថកិច្ច ឬមន្ត្រីមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតពាក់ព័ន្ធ
- ការងារសាងសង់ ឬរុះរើដែលតម្រូវឲ្យមានលិខិតអនុញ្ញាត
- សំណង់ដែលត្រូវបានសាងសង់ថ្មី ជួសជុល កែប្រែ ឬប្តូរមុខងារប្រើប្រាស់សំណង់មុនអាជ្ញាធរមានសមត្ថកិច្ចអនុញ្ញាតឲ្យចូលប្រើប្រាស់សំណង់
- សំណង់ និងបរិក្ខារសំណង់ដែលតម្រូវឲ្យមានការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពជាទៀតទាត់
- សំណង់ដែលមានហានិភ័យចំពោះជីវិតមនុស្ស ទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សន្តិសុខ ឬសណ្តាប់ធ្នាប់សាធារណៈតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច។

មិនតែប៉ុណ្ណោះក្នុងការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់ អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ ត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖[146]

- អនុវត្តការងារតាមប្រភេទ និងកម្រិតនៃអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់
- អនុវត្តការងារដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងរួមទាំងបទប្បញ្ញត្តិជាធរមានដទៃទៀត
- អនុវត្តការងារតាមបែបបទនៃការអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់

[144]មាត្រា២៦ នៃអនុក្រឹត្យលេខ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[145]មាត្រា២៩ នៃអនុក្រឹត្យលេខ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[146]មាត្រា៣០នៃអនុក្រឹត្យលេខ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

- អនុវត្តការងារតាមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ ឬប្រកបអាជីវកម្មត្រួតពិនិត្យ និងបញ្ជាក់សំណង់
- គោរពក្រមសីលធម៌វិជ្ជាជីវៈ ឬធានាថានាយកបច្ចេកទេស និងអ្នកបច្ចេកទេសគោរពក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់ និងក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់។

មួយវិញទៀតនៅក្នុងការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវធ្វើរបាយការណ៍ស្ដីពីការត្រួតពិនិត្យ និងបញ្ជាក់សំណង់ និងចេញលិខិតបញ្ជាក់អនុលោមភាព។ ហើយរាល់ឯកសារបច្ចេកទេសចេញដោយអ្នកវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវមានហត្ថលេខា ត្រា លេខអាជ្ញាបណ្ណរបស់អ្នកវិជ្ជាជីវៈនោះ។ ចំណែកឯកសារចេញដោយក្រុមហ៊ុនត្រួតពិនិត្យ និងបញ្ជាក់សំណង់ ត្រូវមានហត្ថលេខារបស់អ្នកបច្ចេកទេសពាក់ព័ន្ធ ហត្ថលេខាទទួលខុសត្រូវរបស់នាយកបច្ចេកទេស ត្រា និងលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុននោះ។[147]ចំណែកឯរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំនៃការប្រកបវិជ្ជាជីវៈ ឬការប្រកបអាជីវកម្មរបស់ខ្លួន អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ត្រូវចម្លងជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយត្រូវមានហត្ថលេខាទទួលខុសត្រូវ ត្រា និងលេខអាជ្ញាបណ្ណរបស់អ្នកវិជ្ជាជីវៈ ឬហត្ថលេខារបស់អ្នកបច្ចេកទេសពាក់ព័ន្ធ និងហត្ថលេខាទទួលខុសត្រូវរបស់នាយកបច្ចេកទេស និងត្រារបស់ក្រុមហ៊ុន។

### ២.២.២. ការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

វិញ្ញាបនបត្រប្រើប្រាស់សំណង់ សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។ ជាទូទៅមុនដាក់ដំណើរការសំណង់ ម្ចាស់សំណង់ត្រូវធ្វើការស្នើសុំវិញ្ញាបនបត្រនោះនៅស្ថាប័នមានសមត្ថកិច្ចមុនពេលប្រើប្រាស់សំណង់នោះ។ ដើម្បីស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវរៀបចំសំណុំឯកសារដូចខាងក្រោម៖[148]

- ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចំនួន៣ច្បាប់
- ច្បាប់ចម្លងឯកសារបញ្ជាក់អត្តសញ្ញាណរបស់ម្ចាស់សំណង់(ត្រូវធ្វើនីត្យានុកូលកម្មនៅអាជ្ញា-ធរមានសមត្ថកិច្ច ឬមន្ទីរសាការី) ចំនួន៣ច្បាប់
- ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់ ចំនួន៣ច្បាប់
- សលាកបត្រក្បាលដីផ្ដល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីខេត្ត ចំនួន៣ច្បាប់

[147]មាត្រា៣២នៃអនុក្រឹត្យលេខ២២៥ អនក្រ.បក ស្ដីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[148] ប្រការ១០ នៃប្រកាសលេខ១៧៧ ដនស/ប្រក. ស្ដីពីបែបបទ និងនីតិវិធីនៃការផ្ដល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្ដីពីសំណង់ចូលជាធរមាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

- សម្រង់ប្លង់តាមការកសាងជាក់ស្តែង(ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ និងប្លង់អគ្គិភ័យ) ចំនួន៣ច្បាប់
- របាយការណ៍ត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់(បើមាន) ចំនួន៣ច្បាប់
- ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន) ចំនួន៣ច្បាប់
- ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន) ចំនួន៣ច្បាប់
- ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដី និងសម្ភារៈសំណង់ ចំនួន៣ច្បាប់
- ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់(បើមាន) ចំនួន៣ច្បាប់
- ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន(បើមាន) ចំនួន៣ច្បាប់។

បន្ទាប់ពីរៀបចំសំណុំឯកសាររួចរាល់ហើយ គឺត្រូវដាក់ស្នើសុំទៅតាមសមត្ថកិច្ចគ្រប់គ្រងសំណង់។ ជាក់ស្តែងដែលក្នុងនោះរួមមានសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ចំណែកសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។ មួយវិញទៀតចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌវិញ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នេះទៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុងស្រុក ខណ្ឌដែលសំណង់នោះតាំងនៅ។[149]

### ២.២.៣. ការពិនិត្យសម្រេច និងបែបបទនៃការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់

#### ២.២.៣.១. ការពិនិត្យសម្រេចលើឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

ចំពោះនីតិវិធីនៃការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺមានរយៈពេលយ៉ាងយូរ ៣០ (សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។ ហើយច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំតែក្នុងករណីដែលសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវតែប៉ុណ្ណោះ។ បន្ទាប់ពីទទួលបានសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវ

[149] ប្រការ១២ នៃប្រកាសលេខ១៧៧ ដនស/ប្រក. ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

បញ្ជូនសំណុំឯកសារស្នើសុំនោះទៅអគ្គនាយកដ្ឋានសំណង់ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។[150] បន្ថែមពីលើនេះទៀតអគ្គនាយកដ្ឋានសំណង់ ដោយមាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ជាសេនាធិការ ត្រូវពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ និងអគ្គនាយកដ្ឋានសំណង់ត្រូវធ្វើកំណត់បង្ហាញសរុបលទ្ធផលនៃការពិនិត្យ និងផ្តល់យោបល់ ហើយបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីពិនិត្យ និងសម្រេច។[151]

ដោយឡែក ចំពោះនីតិវិធីក្នុងការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្តវិញ គឺមានរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ និងអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត អាចចេញបង្កាន់ដៃទទួលពាក្យស្នើសុំ តែក្នុងករណីដែលសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ។ បន្ទាប់ពីទទួលសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ២ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។[152] ហើយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដោយមានការិយាល័យសំណង់ជាសេនាធិការត្រួតពិនិត្យ និងផ្តល់យោបល់ និងបញ្ជូនសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់រយៈពេលយ៉ាងយូរ៧ថ្ងៃនៃថ្ងៃធ្វើការទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងសម្រេច ដោយសម្រេចលើសំណុំឯកសារស្នើសុំដោយផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់តាមសំណើនៅក្នុងករណីពិនិត្យឃើញថា សំណង់បានគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទដ្ឋានជាធរមាន ឬចេញលិខិតបង្គាប់ឲ្យកែតម្រូវឬរុះរើសំណង់នៅក្នុងករណីពិនិត្យឃើញថាសំណង់មិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទដ្ឋានគតិយុត្តជាធរមាន រួចត្រូវបញ្ជូនសំណុំឯកសារដែលបានសម្រេចរួចទៅឲ្យមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្តក្នុងរយៈពេលយ៉ាងយូរ៣(បី)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារស្នើសុំ។[153]

---

[150] ប្រការ១៤ នៃប្រកាសលេខ១៧៧ ដនស/ប្រក. ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

[151] ប្រការ១៥ នៃប្រកាសលេខ១៧៧ ដនស/ប្រក. ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

[152] ប្រការ១៩ នៃប្រកាសលេខ១៧៧ ដនស/ប្រក. ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

[153] ប្រការ២១ នៃប្រកាសលេខ១៧៧ ដនស/ប្រក. ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

ចំណែកឯនីតិវិធីនៃការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មានរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។ ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចចេញបង្កាន់ដៃទទួលពាក្យស្នើសុំបាន តែក្នុងករណីដែលសំណុំឯកសារនោះមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ។ បន្ទាប់ពីទទួលបានសំណុំឯកសារ ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ទៅកាន់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។[154] បន្ទាប់ទៀតនោះការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រួតពិនិត្យផ្តល់យោបល់ និងបញ្ជូនសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ និងសម្រេចលើសំណុំឯកសារស្នើសុំដោយផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ នៅក្នុងករណីពិនិត្យឃើញថាសំណង់បានគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទដ្ឋានគតិយុត្តជាធរមាន ឬចេញលិខិតបង្គាប់ឲ្យកែប្រែ ឬរុះរើសំណង់ក្នុងករណីពិនិត្យឃើញថាសំណង់មិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធដទៃទៀត ហើយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារដែលបានសម្រេចរួចទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌក្នុងរយៈពេលយ៉ាងយូរ៣(បី)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារស្នើសុំ។[155]

### ២.២.៣.២. ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់

អាជ្ញាធរដែលមានសមត្ថកិច្ចដែលបានផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចសម្រេចព្យួរ ឬដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់នោះបាន ក្នុងករណីដែលរកឃើញថាសំណង់នោះលែងមានគុណភាព និងសុវត្ថិភាពសម្រាប់ប្រើប្រាស់បន្តទៀត ក្នុងករណីនេះអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់អំពីការព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដោយតម្រូវឲ្យម្ចាស់សំណង់ធ្វើការជួសជុល កែប្រែ រុះរើសំណង់នោះ។[156]

[154] ប្រការ២៥ នៃប្រកាសលេខ១៧៧ ដនស/ប្រក. ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

[155] ប្រការ២៧ នៃប្រកាសលេខ១៧៧ ដនស/ប្រក. ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

[156] មាត្រា២២ នៃអនុក្រឹត្យលេខ២២៦ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

នៅក្នុងករណីដែលសំណង់បានបាត់បង់សុវត្ថិភាពផ្នែកគ្រឿងផ្គុំធ្ងន់ធ្ងរ និងមិនអាចជួសជុល កែប្រែ ឬរុះរើតាមលក្ខណៈបច្ចេកទេសដើម្បីឲ្យមានសុវត្ថិភាពឡើងវិញ ឬមួយសំណង់មានសភាពគ្រោះថ្នាក់កម្រិតតាមការសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច។[157] ដោយឡែកអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ក្នុងករណីដែលមុខងារប្រើប្រាស់សំណង់ត្រូវបានប្តូរ និងគ្រឿងផ្គុំសំណង់ត្រូវបានកែប្រែដោយគ្មានការអនុញ្ញាត មួយវិញទៀតចំពោះសំណង់ដែលមានសភាពគ្រោះថ្នាក់ដែលក្រោមការសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច។[158]

[157] មាត្រា២៣ នៃអនុក្រឹត្យលេខ២២៦ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[158] ប្រការ៣២ នៃប្រកាសលេខ១៧៧ ដនស/ប្រក. ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការបកស្រាយប្រធានបទខាងលើដែលនិយាយអំពី ការគ្រប់គ្រងវិស័យសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា រួចមកធ្វើការសន្និដ្ឋានបានថាប្រទេសដែលកំពុងអភិវឌ្ឍន៍ជាពិសេសប្រទេសកម្ពុជាជាក់ស្តែងវិស័យសំណង់ពិតជារីកស្គុះស្គាយដូចដែលបានឃើញស្រាប់ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងជានាយករដ្ឋមន្ត្រី៦នីតិកាលកន្លងមក**។ កាលណាមានការអភិវឌ្ឍ ផលប៉ះពាល់តែងតែកើតមាន ការល្មើសច្បាប់សំណង់ក៏កើតមាន ភាពអសកម្មក្នុងការអនុវត្តច្បាប់ក៏កាន់តែច្រើន ហេតុនេះទើបតម្រូវឲ្យមានបទដ្ឋាននានាដើម្បីគ្រប់គ្រងលើការដ្ឋានទាំងអស់នោះ។

ដោយឡែកការអនុវត្តច្បាប់ក្នុងវិស័យសំណង់នេះឃើញថា មុនពេលច្បាប់ស្តីពីសំណង់មិនទាន់លេចរូបរាងឡើង ការគ្រប់គ្រងស្ថានភាពការគ្រប់គ្រងស្ថានភាពសំណង់មិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយទេ បើសង្កេតឲ្យច្បាស់លាស់ទៅ គឺសំណង់អនាធិបតេយ្យបានសាងសង់ជាហូរហែកន្លងមក ជាពិសេសការតាមដានត្រួតពិនិត្យសំណង់របស់មន្ត្រីមានសមត្ថកិច្ចនៅមានភាពខ្វះខាត និងអ្នកបច្ចេកទេសក៏ពុំសូវមានច្រើន មួយវិញទៀតសំណង់ជាច្រើនបានសាងសង់មិនគោរពទៅតាមបទដ្ឋានច្បាប់ និងបទប្បញ្ញត្តិបច្ចេកទេសជាហេតុនាំឲ្យសំណង់ពុំមានគុណភាព និងភាពរឹងមាំហើយការទទួលខុសត្រូវរបស់ម្ចាស់សំណង់ និងអ្នកពាក់ព័ន្ធក៏នៅមានកម្រិតនៅឡើយ។ ប៉ុន្តែនៅពេលដែលច្បាប់ស្តីពីសំណង់បានអនុម័ត និងបានប្រកាសឲ្យប្រើមកបានឲ្យឃើញថាសំណង់ស្ទើរតែទាំងស្រុងត្រូវបានគ្រប់គ្រងយ៉ាងច្បាស់លាស់។ ការគ្រប់គ្រងនេះសំណង់នីមួយៗដែលបានសាងសង់សុទ្ធតែគោរពគោលការណ៍ដែលច្បាប់កំណត់ មិនថាទាំងការស្នើសុំលិខិតអនុញ្ញាតសាងសង់ ដំណើរការសាងសង់ក្នុងការសាងសង់រហូតដល់បញ្ចប់ការងារសាងសង់ ត្រូវស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់អាជ្ញាធរមានសមត្ថកិច្ចទៅលើគុណភាព និងសុវត្ថិភាពនៃសំណង់ដែលមានមន្ត្រីអធិការកិច្ចសំណង់ជាអ្នកដែលមានភារកិច្ចទៅលើវិស័យសំណង់។ រីឯបុគ្គលដែលពាក់ព័ន្ធនឹងវិស័យសំណង់ផ្សេងទៀតដែលរួមមានអ្នកសាងសង់ អ្នកវិជ្ជាជីវៈ ឬក្រុមហ៊ុនសាងសង់សំណង់សុទ្ធតែតម្រូវឲ្យមានវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណត្រឹមត្រូវស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន។ បន្ថែមពីលើនេះទៀតនោះច្បាប់ក៏បានចែងកំណត់អំពីការដាក់ទោសទណ្ឌទៅលើបុគ្គលទាំងឡាយណាដែលប្រព្រឹត្តអំពើល្មើសក្នុងវិស័យសំណង់ ដែលមានការដាក់ទោសទណ្ឌពិន័យជាប្រាក់ និងដាក់ពន្ធនាគារផងដែរ។ ជារួមត្រឡប់មកវិញវិស័យសំណង់នៅកម្ពុជានាពេលបច្ចុប្បន្ននេះដោយរាប់ចាប់ពីច្បាប់ស្តីពីសំណង់ឆ្នាំ២០១៩ចូលជាធរមានមក បានកំណត់យ៉ាងច្បាស់អំពីដំណាក់កាលនីមួយៗ នីតិវិធីនីមួយៗសម្រាប់ការងារសាងសង់សំណង់ជាពិសេសការទទួលខុសត្រូវរបស់អ្នកដែលពាក់ព័ន្ធទាំងឡាយក្នុងករណីដែលសំណង់មានបញ្ហាកើតឡើងដែលនេះជាកត្តាចម្បងក្នុងការអភិវឌ្ឍវិស័យសំណង់ឲ្យកាន់តែមានភាពរីកចម្រើន។

# ឧបសម្ព័ន្ធ

# អនុសាសន៍

ដើម្បីឆ្លើយតបនឹងបញ្ហាមួយចំនួនក្នុងវិស័យនេះសូមចូលរួមជាអនុសាសន៍មួយចំនួន ដើម្បីជាចំណែកជំរុញឲ្យការគ្រប់គ្រងវិស័យសំណង់កាន់តែមានប្រសិទ្ធភាព ខ្ញុំមានគំនិតស្ដួចស្ដើងក្នុងការបញ្ចេញយោបល់ និងសំណូមពរដល់សមត្ថកិច្ចពាក់ព័ន្ធដូចជា៖

- ពង្រឹងនូវការអនុវត្តច្បាប់ស្ដីពីសំណង់ និងបទដ្ឋានពាក់ព័ន្ធឲ្យកាន់តែតឹងរ៉ឹងដើម្បីធានាឲ្យបាននូវការគ្រប់គ្រងវិស័យសំណង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យកាន់តែមានប្រសិទ្ធភាព
- ធានាឲ្យបាននូវការត្រួតពិនិត្យដំណើរការសាងសង់រាល់សំណង់ទាំងអស់ប្រកបដោយប្រសិទ្ធភាពក្នុងគោលដៅធានាគុណភាព និងសុវត្ថិភាពនៃសំណង់
- ធានាឲ្យបាននូវដំណើរការគ្រប់គ្រងសំណង់ប្រកបដោយតម្លាភាព និងភាពត្រឹមត្រូវតាមច្បាប់ ដោយចាត់វិធានការតឹងរ៉ឹងរាល់អំពើកេងប្រវ័ញ្ច បក្សពួកនិយម ការបំពាន់អំណាច និងការផ្ដល់កម្រៃក្រៅផ្លូវការ ព្រមទាំងអំពើផ្សេងៗទៀតដែលប៉ះពាល់ដល់ការងាររបស់អាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងសំណង់ និងសិទ្ធិស្មើគ្នាក្នុងការទទួលបាននូវសេវាសាធារណៈរបស់ប្រជាពលរដ្ឋគ្រប់រូប
- បង្កើតនូវវគ្គបណ្ដុះបណ្ដាលដើម្បីឲ្យសាធារណៈជនចូលរួមស្វែងយល់ និងបានយល់ដឹងអំពីការងារនានានៃវិស័យមួយនេះ
- ធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីការងារក្នុងវិស័យសំណង់នេះ តាមគ្រប់មធ្យោបាយដើម្បីបង្កើននូវការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅព្រមទាំងអ្នកវិនិយោគ
- ចែករំលែកឲ្យបានទូលាយនូវរាល់ព័ត៌មាន និងការវិវដ្ដថ្មីៗជាប្រចាំអំពីវិស័យនេះដែលរួមមាន ការវិវដ្ដសំខាន់ៗ បញ្ញាគតិយុត្ត និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងសំណង់។

## ឯកសារយោង

### ក.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- **ច្បាប់**
    - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
    - ច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩
    - ច្បាប់ភូមិបាល ឆ្នាំ២០០១
    - ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៩
    - ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤
- **អនុក្រឹត្យ**
    - អនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់
    - អនុក្រឹត្យលេខ១០៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់
    - អនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
    - អនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌ និងវិធីនៃការត្រួតពិនិត្យ និងបញ្ចាក់សំណង់
    - អនុក្រឹត្យលេខ២២៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
    - អនុក្រឹត្យលេខ៨៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅតម្រូវឲ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ
    - អនុក្រឹត្យលេខ៦២ អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
    - អនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- **ប្រកាស**
    - ប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានគ្រោះថ្នាក់

- ប្រកាសលេខ០៣៣ ដ.ន.ស/ប្រ.ក.នី.ក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទ និងបរិបទនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ជាប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់
- ប្រកាសលេខ១០៩ ដនស/ប្រ.ក/នី.ក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីបែបបទនៃការងារត្រួតពិនិត្យ និងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម និងគម្រោងប្លង់គ្រឿងផ្គុំសំណង់
- ប្រកាសលេខ១៧៧ ដនស/ប្រក. ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់
- ប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដនស-កយ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចសំណង់
- ប្រកាសលេខ៩៣ ប្រក.ដនស/អសណ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលប្រការ២ និងប្រការ៣ នៃប្រកាសលេខ៣២ ប្រក/សណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- ប្រកាសលេខ១៦៦ ប្រក.ដនស/អសណ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់
- ប្រកាសលេខ១៩២ ប្រក.ដនស/អសណ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់
- ប្រកាសលេខ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- ប្រកាសលេខ០៣៥ ស្តីពីការកែសម្រួលប្រការ៦ នៃប្រកាសលេខ១៩២ ប្រក.ដនស/អសណ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់
- ប្រកាសលេខ០៧៥ ប្រក.ដ.ន.ស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់
- ប្រកាសលេខ០៧៦ ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង និងតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ

## ខ. សៀវភៅ និងឯកសារពាក់ព័ន្ធ

- ច្បាប់ស្តីពីសំណង់ ឧទ្ទេសនាមដោយ លោក ប៉ិល ភិរ័ក្ស ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ឆ្នាំ២០២៣

- ការគ្រប់គ្រងវិស័យសំណង់ ឧទ្ទេសនាមដោយ ឯកឧត្តម បណ្ឌិត ឆាន់ សូរ្យផល អគ្គនាយក នៃអគ្គនាយកដ្ឋានសំណង់ ឆ្នាំ២០២៣
- លិខិតអនុញ្ញាតសាងសង់ ឧទ្ទេសនាមដោយ លោក ឈៀក វីរៈ ប្រធាននាយកដ្ឋានសិក្សាគម្រោងប្លង់

## គ. គេហទំព័រនានា

- គេហទំព័រផ្លូវការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
    - រចនាសម្ព័ន្ធ https://mlmupc.gov.kh/structure/
    - អគ្គនាយកដ្ឋានសំណង់
    - ការងាររៀបចំដែនដី https://mlmupc.gov.kh/land-management-process/
    - សេវាសំណង់ https://mlmupc.gov.kh/construction-services/

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១ រូបភាព

ឧបសម្ព័ន្ធ១.១. រចនាសម្ព័ន្ធរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ឧបសម្ព័ន្ធ១.២. រចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្តនិងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ

ឧបសម្ព័ន្ធ១.៣. និមិត្តសញ្ញាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

ឧបសម្ព័ន្ធ១.៤. រូបភាពអគារដួលរលំនៅខេត្តកែប កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០២០

ឧបសម្ព័ន្ធ១.៥. រូបភាពអគារដួលរលំនៅខេត្តព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩

## ឧបសម្ព័ន្ធ២ សំណុំគំរូឯកសារ

ឧបសម្ព័ន្ធ២.១. ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់

ឧបសម្ព័ន្ធ២.២. ពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន

ឧបសម្ព័ន្ធ២.៣. ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

ឧបសម្ព័ន្ធ២.៤. តារាងត្រួតពិនិត្យឯកសារ និងគម្រោងប្លង់ ស្នើសុំលិខិតអនុញ្ញាតសាងសង់

ឧបសម្ព័ន្ធ២.៥. តារាងត្រួតពិនិត្យឯកសារសុំលិខិតអនុញ្ញាតបើកការដ្ឋាន

ឧបសម្ព័ន្ធ២.៦. វិញ្ញាបនបត្រប្រើប្រាស់សំណង់

## ឧបសម្ព័ន្ធ៣ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ឧបសម្ព័ន្ធ៣.១. ច្បាប់ស្តីពីសំណង់ឆ្នាំ២០១៩

ឧបសម្ព័ន្ធ៣.២. អនុក្រឹត្យលេខ២២៤ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

ឧបសម្ព័ន្ធ៣.៣. អនុក្រឹត្យលេខ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

ឧបសម្ព័ន្ធ៣.៤. អនុក្រឹត្យលេខ២២៦ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

ឧបសម្ព័ន្ធ៣.៥. ប្រកាសលេខ១៧៧ ដនស/ប្រក. ស្តីពីបែបបទនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

# ឧបសម្ព័ន្ធទី១

# រូបភាព

ឧបសម្ព័ន្ធ១.១. រចនាសម្ព័ន្ធក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



ឧបសម្ព័ន្ធ១.២. រចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និង ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ



ឧបសម្ព័ន្ធ១.៣. និមិត្តសញ្ញាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រុមប្រឹក្សាជាតិប្បញ្ញត្តិបច្ចេកទេសសំណង់

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

ឧបសម្ព័ន្ធ១.៤.  រូបភាពអគាររដួលរលំនៅខេត្តកែប កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០២០





ឧបសម្ព័ន្ធ១.៦.  រូបភាពអគារដួលរលំនៅខេត្តព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩






# ឧបសម្ព័ន្ធទី២
# សំណុំគំរូឯកសារ

## ឧបសម្ព័ន្ធ២.៦. វិញ្ញាបនបត្រប្រើប្រាស់សំណង់



ឧបសម្ព័ន្ធទី ២ នៃប្រកាសលេខ ១៣៧៧ ដនស/ប្រក ចុះថ្ងៃទី...០៦.........ខែ...ធ្នូ...........ឆ្នាំ២០១៥.....
ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
MINISTRY OF LAND MANAGEMENT, URBAN PLANNING AND CONSTRUCTION
លេខ/N°: ....................................

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

**វិញ្ញាបនបត្រប្រើប្រាស់សំណង់**
**CERTIFICATE OF OCCUPANCY**

- សំណង់អំពី.................................. កម្ពស់...................... ម៉ែត្រ ស្មើនឹង...................... ជាន់ ផ្ទៃក្រឡាកម្រាលសំណង់សរុប.......................................... ម²
CONSTRUCTION BUILT OF...........; HEIGHT.................M, ....................STORIES, TOTAL AREA ..................................................... M²
- ទីតាំងសំណង់÷ ក្បាលដីលេខ.................. ផ្លូវ............ ភូមិ.................... ឃុំ/សង្កាត់................ ក្រុង/ស្រុក/ខណ្ឌ................ រាជធានី/ខេត្ត..................
LOCATION: LAND TITLE N°:........, ST.::........VILLAGE:........., COMMUNE/SANGKAT:............., KRONG/SROK/KHAN:.............., CAPITAL/PROVINCE:.............
- ម្ចាស់សំណង់÷..................................................................... -មុខងារប្រើប្រាស់សំណង់ ....................................................
OWNER: .................................................................. USE OF THE CONSTRUCTION: ..............................................
- ថ្ងៃចាប់ផ្តើមសាងសង់.................... ថ្ងៃបញ្ចប់ការសាងសង់.......................... -សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែងលេខ.................. ចុះថ្ងៃទី..... ខែ........ ឆ្នាំ..........
CONSTRUCTION DATE STARTED:.......................; COMPLETED:.....................AS BUILT DRAWING N°......................DATED:..................................
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ចុះថ្ងៃទី............ ខែ................ ឆ្នាំ.......... អនុវត្តដោយ ...............................................
CONSTRUCTION QUALITY AND SAFETY INSPECTION REPORT DATED:........................ DONE BY:............................................

សម្គាល់÷ នៅពេលមានការផ្លាស់ប្តូរមុខងារប្រើប្រាស់សំណង់ និង/ឬការកែប្រែគ្រឿងផ្គុំសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។
REMARK: WHEN THERE IS A CHANGE OF THE USE OF THE CONSTRUCTION AND/OR A CHANGE OF THE CONSTRUCTION STRUCTURE, THE OWNER SHALL SUBMIT REQUEST FOR A NEW CERTIFICATE OF OCCUPANCY.

ថ្ងៃ.................................. ខែ............... ឆ្នាំ.................. ព.ស. ..........

រាជធានីភ្នំពេញ ថ្ងៃទី ............. ខែ ............. ឆ្នាំ ..............
PHNOM PENH, DATE ..................................................

ជ.រដ្ឋមន្ត្រី
FOR THE MINISTER

# ឧបសម្ព័ន្ធទី៣

# ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ឧបសម្ព័ន្ធ៣.៣. អនុក្រឹត្យលេខ២២៥ អនក្រ.បក ស្ដីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២២៥ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## លក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤ ន.ស.៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១១/១១២៤ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ស្ដីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៦/១៨៤ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៤ និងមាត្រា២២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៥២២ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៧ មាត្រា៩ និងមាត្រា៣២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ខែ ធ្នូ ឆ្នាំ២០២០ស្តីពីលិខិតអនុញ្ញាតសាងសង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការបញ្ចប់សុពលភាព ការបន្តសុពលភាព ការព្យួរ និងការដកហូតអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងលក្ខខណ្ឌនៃការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ ក្នុងគោលបំណងដើម្បីៈ
- ធានាគុណភាព សន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិនិងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- ធានាការងារសិក្សាគម្រោងប្លង់ ការងារសាងសង់ និងការងារជុះជុលអនុលោមតាមបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសសំណង់
- ធានាគណនេយ្យភាពនិងប្រសិទ្ធភាពក្នុងការប្រកបវិជ្ជាជីវៈ និងការប្រកបអាជីវកម្មក្នុងវិស័យសំណង់
- បង្កើនជំនឿទុកចិត្តរបស់សាធារណជនលើសំណង់

៩_ **ឯកសារបច្ចេកទេស** សំដៅដល់របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់សំណង់ របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ របាយការណ៍ស្តីពីការធ្វើកោសល្យវិច័យសំណង់ ប្លង់សម្រេងសំណង់ ឬលិខិតបញ្ជាក់អនុលោមភាព។

## ជំពូកទី២

## សមត្ថកិច្ច

**មាត្រា៤ ._**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងលើការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់។

## ជំពូកទី៣

## ប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

**មាត្រា៥ ._**

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ មាន៤(បួន)ប្រភេទដូចខាងក្រោម៖

១_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅ។

២_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្ម។

៣_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់។

៤_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក។

**មាត្រា៦ ._**

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅ មាន២ (ពីរ)កម្រិតដូចខាងក្រោម៖

១_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត១ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់សំណង់គ្រប់ប្រភេទ។

២_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត២ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា៧ ._**

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្ម មាន៣(បី)កម្រិតដូចខាងក្រោម៖

១_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត១ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ស្ថាបត្យកម្មនិងសម្រាប់ការងារសាងសង់ឬរុះរើផ្នែកស្ថាបត្យកម្មសម្រាប់សំណង់គ្រប់ប្រភេទ។

២_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត២ សម្រាប់ផ្ដល់ជូនក្រុមហ៊ុន ដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ស្ថាបត្យកម្មនិងសម្រាប់ ការងារសាងសង់ឬរុះរើផ្នែកស្ថាបត្យកម្មនៃសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្ដល់ដោយ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត៣ សម្រាប់ផ្ដល់ជូនអ្នកវិជ្ជាជីវៈ ដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ស្ថាបត្យកម្មនិងសម្រាប់ ការងារសាងសង់ឬរុះរើផ្នែកស្ថាបត្យកម្មនៃសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្ដល់ដោយ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា៨ ._**

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់ មាន៣(បី)កម្រិតដូចខាងក្រោម៖

១_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត១ សម្រាប់ផ្ដល់ជូន ក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គ្រឿងផ្គុំសំណង់ គម្រោង ប្លង់គ្រឿងផ្គុំសំណង់ និងការងារសាងសង់ឬរុះរើផ្នែកគ្រឿងផ្គុំសំណង់សម្រាប់សំណង់គ្រប់ ប្រភេទ។

២_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត២ សម្រាប់ផ្ដល់ជូន ក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គ្រឿងផ្គុំសំណង់ គម្រោងប្លង់ គ្រឿងផ្គុំសំណង់ និងការងារសាងសង់ឬរុះរើផ្នែកគ្រឿងផ្គុំសំណង់សម្រាប់សំណង់ដែលលិខិត អនុញ្ញាតសាងសង់ផ្ដល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត៣ សម្រាប់ផ្ដល់ជូនអ្នក វិជ្ជាជីវៈដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គ្រឿងផ្គុំសំណង់ គម្រោង ប្លង់គ្រឿងផ្គុំសំណង់ និងការងារសាងសង់ឬរុះរើផ្នែកគ្រឿងផ្គុំសំណង់សម្រាប់សំណង់ដែល លិខិតអនុញ្ញាតសាងសង់ផ្ដល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា៩ ._**

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក មាន៣(បី)កម្រិត ដូច ខាងក្រោម៖

១_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត១ សម្រាប់ផ្ដល់ ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ប្រព័ន្ធ មេកានិក អគ្គិសនី និងទឹក និងការងារសាងសង់ឬរុះរើផ្នែកមេកានិក អគ្គិសនី និងទឹកសម្រាប់ សំណង់គ្រប់ប្រភេទ។

២_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត២ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី និងទឹក និងការងារសាងសង់ឬរុះរើផ្នែកមេកានិក អគ្គិសនី និងទឹកសម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត៣ សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈតាមមុខជំនាញផ្នែកមេកានិក អគ្គិសនី ឬទឹក ដើម្បីអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី ឬទឹក និងការងារសាងសង់ឬរុះរើផ្នែកមេកានិក អគ្គិសនី ឬទឹក សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៤
## លក្ខខណ្ឌនៃការផ្តល់ ការបញ្ចប់សុពលភាព និងការបន្តសុពលភាព
## អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

**មាត្រា១០ ._**

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត១ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ១ ០០០ ០០០ ០០០(មួយពាន់លាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិលនិងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច២០(ម្ភៃ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៣(បី)រូបជាស្ថាបត្យករដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៥(ប្រាំ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិល មេកានិក អគ្គិសនី ទឹក ឬភូគព្ភសាស្ត្រ និងដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច ១៥(ដប់ប្រាំ)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

**មាត្រា១១ ._**

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត២ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិលនិងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ២(ពីរ)រូបជាស្ថាបត្យករដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៤(បួន)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិល មេកានិក អគ្គិសនី ទឹក ឬភូគព្ភសាស្ត្រ និងដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច ១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

**មាត្រា១២ .-**

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត១ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច២០(ម្ភៃ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៣(បី)រូបជាស្ថាបត្យករដែលម្នាក់ៗមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

**មាត្រា១៣ .-**

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត២ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ៣០០ ០០០ ០០០(បីរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ២(ពីរ)រូបជាស្ថាបត្យករដែលម្នាក់ៗមានបទពិសោធន៍យ៉ាងតិច៧(ប្រាំពីរ)ឆ្នាំ

- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

**មាត្រា១៤ .-**

អ្នកវិជ្ជាជីវៈដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត៣ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈជាស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន។

**មាត្រា១៥ .-**

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត១ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិលនិងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច២០(ម្ភៃ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៥(ប្រាំ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិល ៤(បួន)រូបនិងផ្នែកភូគព្ភសាស្ត្រ១(មួយ)រូបនិងដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

**មាត្រា១៦ .-**

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត២ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ៣០០ ០០០ ០០០(បីរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិលនិងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៤(បួន)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិល ៣(បី)រូបនិងផ្នែកភូគព្ភសាស្ត្រ១(មួយ)រូបនិងដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច៧(ប្រាំពីរ)ឆ្នាំ

- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

**មាត្រា១៧ .-**

អ្នកវិជ្ជាជីវៈដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត៣ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិលនិងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន។

**មាត្រា១៨ .-**

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត១ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ៣០០ ០០០ ០០០(បីរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកមេកានិក អគ្គិសនី ឬទឹក និងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៤(បួន)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិល មេកានិក អគ្គិសនី និងទឹក និងដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

**មាត្រា១៩ .-**

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត២ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ១០០ ០០០ ០០០(មួយរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកមេកានិក អគ្គិសនី ឬទឹក និងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៣(បី)រូបជាវិស្វករដែលមានមុខជំនាញផ្នែកមេកានិក អគ្គិសនី និងទឹក និងដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច៧(ប្រាំពីរ)ឆ្នាំ

- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

**មាត្រា២០ .-**

អ្នកវិជ្ជាជីវៈដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត៣ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈជាវិស្វករដែលមានមុខជំនាញផ្នែកមេកានិក អគ្គិសនី ឬទឹក ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន។

**មាត្រា២១ .-**

ក្នុងករណីនាយកបច្ចេកទេសរបស់ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ បានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិរញ្ញបត្ថម្ភដោយតុលាការ ឬត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ ឬត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលនាយកបច្ចេកទេសនោះធ្លាប់ស្នាក់នៅ ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវតែងតាំងនាយកបច្ចេកទេសថ្មីនិងស្នើសុំការយល់ព្រមជាលាយលក្ខណ៍អក្សរមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃប្រកាសរបស់តុលាការឬថ្ងៃប្រកាសសាលក្រមឬសាលដីកាស្ថាពរ។

ក្នុងករណីក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ សម្រេចប្តូរនាយកបច្ចេកទេសឬអ្នកបច្ចេកទេសក្រុមហ៊ុនត្រូវស្នើសុំការយល់ព្រមជាលាយលក្ខណ៍អក្សរមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃសម្រេចប្តូរ។

ក្នុងកំលុងពេលរង់ចាំការសម្រេចយល់ព្រមលើការតែងតាំងនាយកបច្ចេកទេសថ្មី ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមហ៊ុនត្រូវតែងតាំងនាយកបច្ចេកទេសស្តីទី១(មួយ)រូប ដោយជ្រើសរើស ក្នុងចំណោមអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនដែលមានមុខជំនាញសមមូលនឹងមុខជំនាញរបស់នាយកបច្ចេកទេសដែលត្រូវបានប្តូរ។

**មាត្រា២២ .-**

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចចេញបានតែមួយដងគត់ លើកលែងករណីដែលអាជ្ញាបណ្ណបានបាត់បង់ រហែក ឬខូច ឬមានការប្តូរប្រធានក្រុមហ៊ុនឬនាយកបច្ចេកទេស។ ក្នុងករណីនេះអ្នកកាន់អាជ្ញាបណ្ណ ត្រូវដាក់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មីមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៣ .-**

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ មានសុពលភាព៣(បី)ឆ្នាំគិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ និងអាចបន្តជាថ្មីបាន។

ការដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើនៅក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃមុនកាលបរិច្ឆេទផុតសុពលភាព។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ដោយប្រកាស។ ក្នុងករណីនេះ អាជ្ញាបណ្ណថ្មីត្រូវមានការបញ្ជាក់អំពីកាលបរិច្ឆេទនៃការផ្ដល់អាជ្ញាបណ្ណលើកដំបូង។

ក្នុងរយៈពេលនៃការពិនិត្យសម្រេចលើពាក្យស្នើសុំបន្តសុពលភាព អាជ្ញាបណ្ណចាស់នៅបន្តសុពលភាពរហូតដល់ថ្ងៃដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចលើពាក្យស្នើសុំនោះ។

អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលផុតសុពលភាព អាចបន្តអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាផ្ដល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដែលត្រូវបានបង្កើតឡើងនៅក្នុងកំលុងពេលដែលអាជ្ញាបណ្ណនោះមានសុពលភាព ប៉ុន្តែមិនអាចបង្កើតកិច្ចសន្យាផ្ដល់សេវាកម្មថ្មីឡើយ។

**មាត្រា២៤ .-**

អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចឈប់ប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មដោយស្ម័គ្រចិត្តមុនកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ។ ក្នុងករណីនេះ អ្នកកាន់អាជ្ញាបណ្ណត្រូវបញ្ជាក់អះអាងជាលាយលក្ខណ៍អក្សរថាបានអនុវត្តចប់សព្វគ្រប់នូវកាតព្វកិច្ចទាំងឡាយដែលបានបង្កើតឡើងដោយកិច្ចសន្យាផ្ដល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបញ្ចប់សុពលភាពអាជ្ញាបណ្ណដោយប្រកាស។

ការបញ្ចប់សុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ មិនធ្វើឱ្យអ្នកស្នើសុំរួចផុតពីការទទួលខុសត្រូវក្នុងការសងការខូចខាតដែលបង្កឡើងដល់អតិថិជនឬអ្នកដទៃដោយសារវិការៈនៃការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់របស់ខ្លួនឡើយ។

## ជំពូកទី៥

## នីតិវិធីនៃការផ្ដល់ ការបញ្ចប់សុពលភាព និងការបន្តសុពលភាព អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

**មាត្រា២៥ .-**

ពាក្យស្នើសុំអាជ្ញាបណ្ណ ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី ពាក្យស្នើសុំបញ្ចប់សុពលភាព និងពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងដាក់នៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណ ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី ពាក្យស្នើសុំបញ្ចប់សុពលភាព និងពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ក្នុងរយៈពេលយ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

រាល់ចម្លើយបដិសេធចំពោះពាក្យស្នើសុំអាជ្ញាបណ្ណ ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី ពាក្យស្នើសុំបញ្ចប់សុពលភាព និងពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីមូលហេតុ។

**មាត្រា២៦ ._**

អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ អ្នកដាក់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី អ្នកដាក់ពាក្យស្នើសុំបញ្ចប់សុពលភាព និងអ្នកដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវបង់កម្រៃសេវា។

កម្រៃសេវាពិនិត្យនិងផ្តល់អាជ្ញាបណ្ណ ការចេញសន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវបង់នៅពេលទទួលបង្កាន់ដៃទទួលពាក្យស្នើសុំនិងមិនអាចប្រគល់ជូនម្ចាស់សំណើវិញឡើយ ទោះក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចសម្រេចបដិសេធផ្តល់ការអនុញ្ញាតជូនម្ចាស់សំណើក៏ដោយ។

កម្រៃសេវាផ្តល់អាជ្ញាបណ្ណ ការចេញសន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្ត សុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៧ ._**

បែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៦

## លក្ខខណ្ឌនៃការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់

**មាត្រា២៨ ._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើការត្រួតពិនិត្យនិងវិភាគលើទម្រង់ ការគណនា ការអនុវត្តបទប្បញ្ញត្តិ និងការប្រតិបត្តិការងារ ដើម្បីធ្វើការបញ្ជាក់អំពីអនុលោមភាពនៃគម្រោងប្លង់ អនុលោមភាពនៃការងារសាងសង់ឬរះបើ ឬអនុលោមភាពនៃសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត។

**មាត្រា២៩ .-**

សំណង់និងការងារសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់សំណង់ មានដូចខាងក្រោម៖

១- គម្រោងប្លង់ប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើ មុនអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតពាក់ព័ន្ធ។

២- ការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាត។

៣- សំណង់ដែលត្រូវបានសាងសង់ថ្មី ជួសជុល កែប្រែ ឬប្តូរមុខងារប្រើប្រាស់សំណង់ មុនអាជ្ញាធរមានសមត្ថកិច្ចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់។

៤- សំណង់និងបរិក្ខារសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពជាទៀងទាត់។

៥- សំណង់ដែលមានហានិភ័យចំពោះជីវិតមនុស្ស ទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សន្តិសុខឬសណ្តាប់ធ្នាប់សាធារណៈតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីចាំបាច់ អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់លើឯកសារបច្ចេកទេស ការងារសាងសង់ឬរុះរើ ឬសំណង់ដទៃទៀត។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំនៃសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពអគ្គិភ័យលើសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៣០ .-**

ក្នុងការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖

- អនុវត្តការងារតាមប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់
- អនុវត្តការងារដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- អនុវត្តការងារតាមបែបបទនៃការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់
- អនុវត្តតាមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់
- គោរពក្រមសីលធម៌វិជ្ជាជីវៈឬធានាថានាយកបច្ចេកទេសនិងអ្នកបច្ចេកទេសគោរពក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់និងក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។

ក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣១ .-**

ក្នុងការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវធ្វើរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់សំណង់និងចេញលិខិតបញ្ជាក់អនុលោមភាព។

**មាត្រា៣២ .-**

រាល់ឯកសារបច្ចេកទេសចេញដោយអ្នកវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវមានហត្ថលេខា ត្រា និងលេខអាជ្ញាបណ្ណរបស់អ្នកវិជ្ជាជីវៈនោះ។

រាល់ឯកសារបច្ចេកទេសចេញដោយក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវមានហត្ថលេខារបស់អ្នកបច្ចេកទេសពាក់ព័ន្ធ ហត្ថលេខាទទួលខុសត្រូវរបស់នាយកបច្ចេកទេស ត្រា និងលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុននោះ។

នាយកបច្ចេកទេសស្តីទី គ្មានសិទ្ធិចុះហត្ថលេខាលើឯកសារបច្ចេកទេសចេញដោយក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ឡើយ។

**មាត្រា៣៣ .-**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំនៃការប្រកបវិជ្ជាជីវៈឬការប្រកបអាជីវកម្មរបស់ខ្លួន និងចម្លងជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំនៃការប្រកបវិជ្ជាជីវៈរបស់អ្នកវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវមានហត្ថលេខាទទួលខុសត្រូវ ត្រា និងលេខអាជ្ញាបណ្ណរបស់អ្នកវិជ្ជាជីវៈនោះ។

របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំនៃការប្រកបអាជីវកម្មរបស់ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវមានហត្ថលេខារបស់អ្នកបច្ចេកទេសពាក់ព័ន្ធនិងហត្ថលេខាទទួលខុសត្រូវរបស់នាយកបច្ចេកទេសនិងត្រារបស់ក្រុមហ៊ុន។

**មាត្រា៣៤ .-**

នាយកបច្ចេកទេសនិងអ្នកបច្ចេកទេសនៃក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងអ្នកវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវមកទទួលការបណ្តុះបណ្តាលអំពីការអនុវត្តការងាររបស់ខ្លួនតាមការរៀបចំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៥ .-**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចអនុវត្តការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់និងការងារកោសល្យវិច័យសំណង់តាមសំណើរបស់តុលាការ ក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬម្ចាស់សំណង់។

**មាត្រា៣៦ .-**

បែបបទនៃការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៧
## ការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់
## អនុវត្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**មាត្រា៣៧ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ សម្រាប់សំណង់ គម្រោងប្លង់ និងការងារសាងសង់ឬរុះរើសំណង់របស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀតតាមសំណើរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច។

ក្នុងករណីចាំបាច់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចទទួលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់របស់បុគ្គលឯកជន។

ក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចអនុវត្តការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ឬការងារកោសល្យវិច័យសំណង់ តាមសំណើរបស់តុលាការ ក្រសួងស្ថាប័នពាក់ព័ន្ធ ឬបុគ្គលឯកជន។

**មាត្រា៣៨ .-**

សមាសភាពនៃក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវជ្រើសរើសក្នុងចំណោមថ្នាក់ដឹកនាំនិងមន្ត្រីរាជការដែលជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ និងដែលមានបទពិសោធន៍ការងារផ្នែកស្ថាបត្យកម្ម ផ្នែកសំណង់ស៊ីវិល ផ្នែកភូគព្ភសាស្ត្រ ផ្នែកមេកានិក ផ្នែកអគ្គិសនី ផ្នែកទឹក ឬផ្នែកវិស្វកម្មដទៃទៀត។

សមាសភាពនៃក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៩ .-**

ក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់សំណង់ របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ប្លង់សម្រេចសំណង់ ឬរបាយការណ៍នៃការធ្វើកោសល្យវិច័យសំណង់។

ក្រោយពីបានទទួលការឯកភាពពីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវចេញលិខិតបញ្ជាក់អនុលោមភាពដោយមានហត្ថលេខារបស់ប្រធានក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៤០ .-**

សេវាត្រួតពិនិត្យនិងបញ្ជាក់លើសំណង់របស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀតដែលអនុវត្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនតម្រូវឱ្យមានការបង់កម្រៃសេវាឡើយ។

ម្ចាស់សំណង់ជាបុគ្គលឯកជនដែលទទួលសេវាត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្ដល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបង់កម្រៃសេវា។

កម្រៃសេវាត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៨

## ស្ថាបត្យករឬវិស្វករនិងក្រុមហ៊ុនសញ្ជាតិបរទេស

**មាត្រា៤១ .-**

ស្ថាបត្យករឬវិស្វករនិងក្រុមហ៊ុនសញ្ជាតិបរទេស មានសិទ្ធិប្រកបវិជ្ជាជីវៈឬអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់តាមលក្ខខណ្ឌដូចមានចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា៤២ .-**

ស្ថាបត្យករឬវិស្វករសញ្ជាតិបរទេសដែលស្នើសុំប្រកបវិជ្ជាជីវៈនៅព្រះរាជាណាចក្រកម្ពុជាជានាយកបច្ចេកទេសឬជាអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឬជាអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានចុះបញ្ជិកានៅគណៈវិជ្ជាជីវៈពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា
- បានបំពេញលក្ខខណ្ឌតម្រូវដើម្បីប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់
- មានសិទ្ធិស្នាក់នៅរយៈពេលវែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- មានសិទ្ធិប្រកបការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤៣ .-**

ក្រុមហ៊ុនសញ្ជាតិបរទេសដែលបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលស្នើសុំប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញលក្ខខណ្ឌដូចគ្នានឹងក្រុមហ៊ុនសញ្ជាតិខ្មែរដែរ។

ក្រុមហ៊ុនសញ្ជាតិបរទេសដែលបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ដែលស្នើសុំប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានបំពេញលក្ខខណ្ឌតម្រូវដើម្បីប្រកបអាជីវកម្ម
- ត្រូវមានភ្នាក់ងារតំណាងដោយមានលិខិតប្រគល់សិទ្ធិដែលបញ្ជាក់ពីភាពស្របច្បាប់និងចុះហត្ថលេខាដោយប្រធានក្រុមហ៊ុន និង
- ត្រូវមានការិយាល័យតំណាងពាណិជ្ជកម្មឬការិយាល័យទំនាក់ទំនងឬបុត្រសម្ព័ន្ធក្រុមហ៊ុនដែលមានអាសយដ្ឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៩
## ការប្ដឹងតវ៉ា

**មាត្រា៤៤ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចមានចែងក្នុងអនុក្រឹត្យនេះ មានសិទ្ធិប្ដឹងតវ៉ាតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្ដីពីសំណង់និងបទប្បញ្ញត្តិដទៃទៀតជាធរមាន។

## ជំពូកទី១០
## ទណ្ឌកម្ម

**មាត្រា៤៥ .-**

ទណ្ឌកម្មក្នុងអនុក្រឹត្យនេះ រួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរអាជ្ញាបណ្ណ
- ការដកហូតអាជ្ញាបណ្ណ។

**មាត្រា៤៦ .-**

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរអាជ្ញាបណ្ណ និងការដកហូតអាជ្ញាបណ្ណ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចផ្សាយការព្រមាន ការព្យួរ ឬការដកហូតអាជ្ញាបណ្ណជាសាធារណៈនៅក្នុងសារព័ត៌មានឬតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

**មាត្រា៤៧ .-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន ចំពោះអ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដែលមិនគោរពតាមលក្ខខណ្ឌនៃការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ដូចមានចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា៤៨ .-**

ត្រូវព្យួរអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ក្នុងរយៈពេលមិនលើសពី៦(ប្រាំមួយ)ខែដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន ចំពោះអ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ជាអ្នកវិជ្ជាជីវៈដែលបានប្រព្រឹត្តនូវអំពើណាមួយដូចខាងក្រោម៖

- មិនអនុវត្តតាមការណែនាំដូចមានចែងនៅក្នុងលិខិតព្រមានរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ
- លែងបំពេញលក្ខខណ្ឌតម្រូវដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈ

- បានប្រព្រឹត្តខុសក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់ឬក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់
- មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ក៏ប៉ុន្តែមានការបញ្ជាក់ពីគ្រូពេទ្យជំនាញថាអាចជាសះស្បើយឡើងវិញក្នុងរយៈពេលនៃការព្យួរ។

ត្រូវព្យួរអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ក្នុងរយៈពេលមិនលើសពី១(មួយ)ឆ្នាំ ដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន ចំពោះអ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ជាក្រុមហ៊ុនដែលបានប្រព្រឹត្តនូវអំពើណាមួយដូចខាងក្រោម៖

- មិនអនុវត្តតាមការណែនាំដូចមានកំណត់ក្នុងលិខិតព្រមានរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបអាជីវកម្ម
- លែងបំពេញលក្ខខណ្ឌតម្រូវដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្ម
- មិនបានប្តូរអភិបាលរបស់ក្រុមហ៊ុនដែលបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិរញ្ញបត្តម្ភដោយតុលាការ ឬត្រូវបានតុលាការប្រកាសក្ស័យធន ឬការជម្រះបញ្ជីតាមផ្លូវតុលាការ ឬត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងប្រទេសណាមួយដែលអភិបាលនោះធ្លាប់ស្នាក់នៅក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសរបស់តុលាការឬថ្ងៃប្រកាសសាលក្រមឬសាលដីកាស្ថាពរ
- មិនបានប្តូរនាយកបច្ចេកទេសឬអ្នកបច្ចេកទេសដែលបានបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈក្នុងរយៈពេល៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃបាត់បង់នីតិសម្បទា។

ក្នុងរយៈពេលដែលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវបានព្យួរ អ្នកកាន់អាជ្ញាបណ្ណមិនអាចបង្កើតកិច្ចសន្យាផ្តល់សេវាកម្មថ្មីនិងមិនអាចចុះហត្ថលេខាលើឯកសារបច្ចេកទេសពាក់ព័ន្ធការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ឡើយ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្យួរអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ដោយសេចក្តីសម្រេច។

**មាត្រា៤៩.-**

ត្រូវដកហូតអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន ចំពោះអ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ជាអ្នកវិជ្ជាជីវៈដែលបានប្រព្រឹត្តនូវអំពើណាមួយដូចខាងក្រោម៖

- មិនបានអនុវត្តតាមការណែនាំដូចមានចែងនៅក្នុងសេចក្តីសម្រេចស្តីពីការព្យួរអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់
- បានប្រព្រឹត្តខុសធ្ងន់ធ្ងរចំពោះក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់ឬក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់

- បាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈដូចមានចែងនៅក្នុងច្បាប់ស្ដីពីសំណង់
- មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ដោយមានការបញ្ជាក់ពីគ្រូពេទ្យជំនាញថាមិនអាចជាសះស្បើយឡើងវិញក្នុងរយៈពេលនៃការព្យួរ
- បានទទួលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភដោយតុលាការ
- បានទទួលការប្រកាសក្ស័យធនដោយតុលាការ
- ត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងប្រទេសណាមួយដែលអភិបាលនោះធ្លាប់ស្នាក់នៅ។

ត្រូវដកហូតអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន ចំពោះអ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ជាក្រុមហ៊ុនដែលបានប្រព្រឹត្តនូវអំពើណាមួយដូចខាងក្រោម៖

- មិនបានអនុវត្តតាមការតម្រូវដូចមានចែងនៅក្នុងសេចក្ដីសម្រេចស្ដីពីការព្យួរអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់
- ត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម
- ត្រូវបានតុលាការប្រកាសរំលាយឬប្រកាសមោឃភាព
- ត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ។

អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលត្រូវបានដកហូត អាចស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់សាជាថ្មីក្រោយរយៈពេល៥ (ប្រាំ)ឆ្នាំគិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដកហូតអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ដោយប្រកាស។

បែបបទនិងបរិបទនៃការព្យួរនិងការដកហូតអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៥០.-**

បុគ្គលដែលក្លែងបន្លំឯកសារឬផ្ដល់ព័ត៌មានមិនពិតដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីទទួលបានអាជ្ញាបណ្ណ សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដូចមានចែងក្នុងអនុក្រឹត្យនេះ ឬក្លែងបន្លំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឬប្រកាសស្ដីពីការបញ្ចប់សុពលភាព ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា៥១ .-**

អ្នករាជការសាធារណៈមានសមត្ថកិច្ចដែលមិនទទួលពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ការចេញសន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

ដោយគ្មានមូលហេតុត្រឹមត្រូវ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌ តាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១១

## អន្តរប្បញ្ញត្តិ

**មាត្រា៥២ .-**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចអនុវត្តការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមានតាមសំណើរបស់ម្ចាស់សំណង់។ ក្នុងករណីនេះ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើប្លង់សម្រង់សំណង់ និងរបាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជូនម្ចាស់សំណង់ដើម្បីប្រើប្រាស់សម្រាប់បំពេញបែបបទស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់។

**មាត្រា៥៣ .-**

អ្នកស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដែលគ្មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន ត្រូវតម្កល់ប្រាក់នៅធនាគារជាតិនៃកម្ពុជាទៅតាមប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណ។

**មាត្រា៥៤ .-**

ចំនួនទឹកប្រាក់អប្បបរមាដែលអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន ត្រូវបានកំណត់ដូចខាងក្រោម៖

១- ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត១។

២- ៣០០ ០០០ ០០០(បីរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត២។

៣- ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត១។

៤- ៣០០ ០០០ ០០០(បីរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត២។

៥- ៥០ ០០០ ០០០(ហាសិបលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត៣។

៦- ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត១។

៧- ៣០០ ០០០ ០០០(បីរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត២។

៨- ៥០ ០០០ ០០០(ហាសិបលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត៣។

៩- ៣០០ ០០០ ០០០(បីរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត១។

១០- ១០០ ០០០ ០០០(មួយរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត២។

១១- ៥០ ០០០ ០០០(ហាសិបលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត៣។

**មាត្រា៥៥ .-**

ប្រាក់ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវដាក់តម្កល់ជាសាច់ប្រាក់នៅក្នុងគណនីទោលរតនាគារជាតិ ដែលបើកនៅធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់នេះ អាចដកវិញបានក្នុងករណីដូចខាងក្រោម៖

១- អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ បានទទួលប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការបញ្ចប់សុពលភាពនៃអាជ្ញាបណ្ណ។

២- អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ បានទទួលប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការដកហូតអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៣- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ផុតសុពលភាព។

៤- អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ បានទទួលវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥៦ .-**

អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវដាក់ពាក្យស្នើសុំដកប្រាក់តម្កល់មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើពាក្យស្នើសុំដកប្រាក់តម្កល់ក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

ធនាគារជាតិនៃកម្ពុជា ត្រូវបង្វិលសាច់ប្រាក់ជូនម្ចាស់វិញ តាមសំណើរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចស្នើសុំបង្កកប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា ក្នុងករណីដែលក្រសួងពិនិត្យឃើញថា អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ កំពុងមានវិវាទជាមួយអតិថិជនរបស់ខ្លួន ក្នុងការអនុវត្តកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងបានធ្វើឱ្យខូចប្រយោជន៍ធ្ងន់ធ្ងរដល់អតិថិជននោះឬបានបង្កការខូចខាតដល់អ្នកដទៃ។

**មាត្រា៥៧ .-**

បែបបទនិងបរិបថនៃការអនុញ្ញាតឱ្យដកប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១២

## អវសានប្បញ្ញត្តិ

**មាត្រា៥៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១ រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ៣.៤. អនុក្រឹត្យលេខ២២៦ អនក្រ.បក ស្ដីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្ដល់ ការព្យួរ និងការដកហូត វិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២២៦ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## លក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤ ន.ស. ៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលបានប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- អនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ
- អនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា១៦ និងមាត្រា១៧នៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២២៤អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ២២៥អនក្រ.បក ចុះថ្ងៃទី ៣០ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ការប្រើប្រាស់សំណង់ ការប្តូរមុខងារប្រើប្រាស់សំណង់ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ និងការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ក្នុងគោលបំណងដើម្បីធានាសន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិនិងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទ លើកលែងតែប្រភេទសំណង់ដែលមានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់** សំដៅដល់ការងារពិនិត្យ ពិសោធន៍ វិភាគ គណនា និងវាយតម្លៃអំពីគុណភាពនិងសុវត្ថិភាពនៃសំណង់មានស្រាប់ក្នុងដំណាក់កាលនៃការប្រើប្រាស់សំណង់។

២- **ចំណាត់ថ្នាក់សំណង់** សំដៅដល់ការរៀបចំជាប្រភេទ ជាថ្នាក់ឬក្រុមនៃសំណង់ទៅតាមលក្ខណៈវិនិច្ឆ័យផ្សេងៗ។

៣- **ការប្រើប្រាស់សំណង់** សំដៅដល់ការប្រើប្រាស់ ការអាស្រ័យផល និងការថាត់ថែងសំណង់។

៤- **ប្លង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ** សំដៅដល់ផែនទីប្រើប្រាស់ដីសាធារណៈរបស់រដ្ឋសម្រាប់គ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលម្ហសាធារណៈ ដែលសិក្សានិងរៀបចំដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត តាមបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម និងអនុម័តដោយរដ្ឋបាលរាជធានី ខេត្ត។

៥- **មុខងារប្រើប្រាស់សំណង់** សំដៅដល់គោលបំណងចម្បងនៃការប្រើប្រាស់សំណង់។

៦- **មុខងារសមាសភាគសំណង់** សំដៅដល់មុខងារទាំងឡាយនៃផ្នែកនីមួយៗរបស់សំណង់ ដែលផ្សំគ្នាសម្រាប់បង្កើតមុខងារប្រើប្រាស់សំណង់។

៧- **យន្តការច្រកចេញចូលតែមួយ** សំដៅដល់ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ។

៨- **វិញ្ញាបនបត្រប្រើប្រាស់សំណង់** សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

៩- **សំណង់** សំដៅដល់ដំណើរការនៃការងារសំណង់ ដល់អគារ គ្រឿងផ្គុំ ស្ថាបត្យការទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ឬបណ្តោះអាសន្ន ធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់។

១០- **សំណង់ដែលមានសភាពគ្រោះថ្នាក់** សំដៅដល់សំណង់ឬផ្នែកណាមួយនៃសំណង់ ឬសម្ភារៈសំណង់ បរិក្ខារដែលបំពាក់លើសំណង់ ដែលអាចបង្កគ្រោះថ្នាក់ដល់សំណង់ជិតខាង ដល់អាយុជីវិត រាងកាយ សុខភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ អ្នកជិតខាង និងសាធារណជន។

១១- **អគារពហុមុខងារ** សំដៅដល់អគារដែលមានលម្ហតែមួយឬច្រើនដែលអាចបំពេញមុខងារប្រើប្រាស់ច្រើនយ៉ាងនៅពេលខុសៗគ្នា។

១២- **អគារប្រើប្រាស់ចម្រុះ** សំដៅដល់អគារដែលមានផ្នែកផ្សេងៗពីគ្នាហើយផ្នែកទាំងនោះមានមុខងារប្រើប្រាស់ផ្សេងៗគ្នា។

១៣- **អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី២
## សមត្ថកិច្ច

**មាត្រា៤ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងការប្រើប្រាស់សំណង់គ្រប់ប្រភេទ។

**មាត្រា៥ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាអាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ និងការប្តូរមុខងារប្រើប្រាស់សំណង់ទៅតាមបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់។

## ជំពូកទី៣
## លក្ខខណ្ឌនៃការប្រើប្រាស់សំណង់

**មាត្រា៦ .-**

រាល់ការប្រើប្រាស់សំណង់ ត្រូវមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ឬវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្នជាមុន លើកលែងតែសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ ត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖

- ប្រើប្រាស់សំណង់ទៅតាមមុខងារប្រើប្រាស់សំណង់
- ប្រើប្រាស់សំណង់ដោយអនុលោមតាមបទដ្ឋានគតិយុត្តនិងបទដ្ឋានបច្ចេកទេសនៃការប្រើប្រាស់សំណង់
- ប្រគល់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់របស់ខ្លួនជូនអាជ្ញាធរមានសមត្ថកិច្ចជាទៀងទាត់តាមការកំណត់របស់ច្បាប់ស្តីពីសំណង់
- យកចិត្តទុកដាក់ថែទាំសំណង់និងចាត់ចែងជួសជុលផ្នែកនៃសំណង់ដែលខូចខាត
- រាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចអំពីសភាពគ្រោះថ្នាក់នៃសំណង់។

ម្ចាស់សំណង់មានកាតព្វកិច្ចធានាឱ្យការប្រើប្រាស់ ការអាស្រ័យផល និងការចាត់ចែងសំណង់របស់ខ្លួនគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា៧ .-**

មុខងារប្រើប្រាស់សំណង់ ត្រូវកំណត់នៅក្នុងវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ចំណាត់ថ្នាក់សំណង់តាមមុខងារប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៨ .-**

រាល់ការប្តូរមុខងារប្រើប្រាស់សំណង់ទាំងមូលឬដោយផ្នែក ត្រូវមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មីជាមុន លើកលែងតែសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ការប្តូរមុខងារសមាសភាគសំណង់ដែលមិនបង្កើនបន្ទុកលើគ្រឿងផ្ទុំសំណង់និងក្នុងគោលដៅមិនមែនអាជីវកម្ម មិនតម្រូវឱ្យមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មីឡើយ។

**មាត្រា៩ .-**

ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្រោយការងារសាងសង់សំណង់ទាំងមូលត្រូវបានបញ្ចប់ជាស្ថាពរ។

វិញ្ញាបនបត្រប្រើប្រាស់សំណង់សម្រាប់អគារពហុមុខងារ ត្រូវមានកត់ត្រាមុខងារប្រើប្រាស់ទាំងអស់នៃអគារនោះ។

វិញ្ញាបនបត្រប្រើប្រាស់សំណង់សម្រាប់អគារប្រើប្រាស់ចម្រុះ ត្រូវមានកត់ត្រាមុខងារប្រើប្រាស់ទាំងអស់តាមផ្នែកនីមួយៗនៃអគារនោះ។

វិញ្ញាបនបត្រប្រើប្រាស់សំណង់មានសុពលភាពជាអចិន្ត្រៃយ៍ ទោះបីកម្មសិទ្ធិករនៃសំណង់ត្រូវបានផ្លាស់ប្តូរក៏ដោយ។

នៅពេលមានការផ្ទេរកម្មសិទ្ធិនៃដីឬសិទ្ធិកាន់កាប់ដីដែលសំណង់នោះតាំងនៅ និង/ឬការផ្ទេរកម្មសិទ្ធិនៃសំណង់ឬគម្រោងសាងសង់នោះត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន សិទ្ធិនិងកាតព្វកិច្ចដែលទទួលបានពីវិញ្ញាបនបត្រប្រើប្រាស់សំណង់ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវផ្ទេរទៅឱ្យកម្មសិទ្ធិករថ្មីឬអ្នកកាន់កាប់ថ្មីនៃសំណង់។ ក្នុងករណីនេះ កម្មសិទ្ធិករថ្មីឬអ្នកកាន់កាប់ថ្មីនៃសំណង់ អាចស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។

ក្នុងករណីវិញ្ញាបនបត្រប្រើប្រាស់សំណង់ត្រូវបានព្យួរឬដកហូតដោយអាជ្ញាធរមានសមត្ថកិច្ច ការប្រើប្រាស់សំណង់នោះ ត្រូវបានហាមឃាត់។

**មាត្រា១០ .-**

ម្ចាស់សំណង់អាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន ដើម្បីអាចប្រើប្រាស់ផ្នែកនៃសំណង់ដែលបានសាងសង់រួច។

បុគ្គលដែលបានទទួលវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន មានកាតព្វកិច្ចរៀបចំជំឡើងរបាំងឬមធ្យោបាយផ្សេងទៀត សម្រាប់ខណ្ឌផ្នែកនៃសំណង់ដែលត្រូវបានអនុញ្ញាតឱ្យចូលប្រើប្រាស់ពីផ្នែកនៃសំណង់ដែលមិនទាន់សាងសង់រួចដើម្បីធានាសុវត្ថិភាពក្នុងការប្រើប្រាស់សំណង់។

វិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន មានសុពលភាពត្រឹមថ្ងៃដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ត្រូវបានផ្តល់ជូនសម្រាប់សំណង់ទាំងមូល។

**មាត្រា១១ .-**

ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់ដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ក្នុងគោលដៅក្រៅពីលំនៅឋាន ត្រូវដាក់តាំងបង្ហាញវិញ្ញាបនបត្រប្រើប្រាស់សំណង់ដល់អ្នកប្រើប្រាស់។

## ជំពូកទី៤

## លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់

**មាត្រា១២ .-**

លក្ខខណ្ឌនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ មានដូចខាងក្រោម៖

- សំណង់ត្រូវបានសាងសង់ ជួសជុល ឬកែប្រែនៅលើដីដែលបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី ឬដីដែលកាន់កាប់ដោយស្របច្បាប់ ស្របតាមប្លង់សុរិយោដី ប្លង់លម្អិតនគរូបនីយកម្ម ផែនការប្រើប្រាស់ដី ប្លង់គោលប្រើប្រាស់ដី ឬប្លង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
- ការងារសាងសង់ ការងារជួសជុល ការងារកែប្រែ ឬការងាររុះរើបានចប់រួចរាល់ដោយអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- សំណង់មានគ្រឿងផ្គុំអាចទ្រទ្រង់បន្ទុកបានប្រកបដោយសុវត្ថិភាពទៅតាមមុខងារប្រើប្រាស់សំណង់
- សំណង់មានសុវត្ថិភាពអគ្គិភ័យ អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ
- សំណង់មានប្រព័ន្ធមេកានិក អគ្គិសនី និងទឹកអាចប្រើប្រាស់បានប្រកបដោយសុវត្ថិភាព អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- សំណង់ត្រូវបានសាងសង់ ជួសជុល ឬកែប្រែដោយប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលអាចធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬស្តង់ដាកម្ពុជា។

**មាត្រា១៣ .-**

លក្ខខណ្ឌនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន មានដូចខាងក្រោម៖

- សំណង់ត្រូវបានសាងសង់ ជួសជុល ឬកែប្រែនៅលើដីដែលបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី ឬដីដែលកាន់កាប់ដោយស្របច្បាប់ ស្របតាមប្លង់សុរិយោដី ប្លង់លម្អិតនគរូបនីយកម្ម ផែនការប្រើប្រាស់ដី ប្លង់គោលប្រើប្រាស់ដី ឬប្លង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
- គ្រឿងផ្គុំសំណង់សំខាន់ៗមានជាអាទិ៍គ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ ជញ្ជាំងទ្របន្ទុកនៃសំណង់ទាំងមូលត្រូវបានសាងសង់ ជួសជុល ឬកែប្រែរួចនិងមានសុវត្ថិភាព

- ការងារសាងសង់ ការងារជួសជុល ឬការងារកែប្រែផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្ដោះអាសន្ន បានចប់រួចរាល់ដោយអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- ផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្ដោះអាសន្ន មានសុវត្ថិភាពអគ្គិភ័យអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ
- ផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្ដោះអាសន្ន មានប្រព័ន្ធមេកានិក អគ្គិសនី និងទឹកអាចប្រើប្រាស់បានប្រកបដោយសុវត្ថិភាពអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- ផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្ដោះអាសន្ន ត្រូវបានសាងសង់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ដែលអាចធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ឬស្តង់ដាកម្ពុជា
- ការប្រើប្រាស់ផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្ដោះអាសន្ន អាចអនុញ្ញាតឱ្យការងារសាងសង់ផ្នែកផ្សេងទៀតនៃសំណង់បន្តដំណើរការបានដោយសុវត្ថិភាព។

**មាត្រា១៤ .-**

សំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវធ្វើជាភាសាខ្មែរនិងដាក់នៅយន្តការច្រកចេញចូលតែមួយ។

បង្កាន់ដៃទទួលពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចផ្ដល់ជូនម្ចាស់សំណើតែក្នុងករណីសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់។

ក្នុងករណីសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់មានលក្ខណៈមិនត្រឹមត្រូវ យន្តការច្រកចេញចូលតែមួយត្រូវស្នើជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើឱ្យធ្វើការកែតម្រូវ។

កំលុងពេលនៃការកែតម្រូវសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់មិនត្រូវបានរាប់បញ្ចូលក្នុងបរិបថនៃការសម្រេចលើពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ ។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងរយៈពេលយ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចលើពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចលើពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

រាល់ចម្លើយបដិសេធរបស់អាជ្ញាធរមានសមត្ថកិច្ច ចំពោះការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងមានបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់។

ការមិនសម្រេចលើពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ក្នុងរយៈពេលដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវចាត់ទុកថាអាជ្ញាធរមានសមត្ថកិច្ចបានផ្តល់ការអនុញ្ញាតដល់ម្ចាស់សំណើដោយតុណ្ហីភាព។ ក្នុងករណីនេះ ការប្រើប្រាស់សំណង់ត្រូវស្របតាមមុខងារប្រើប្រាស់សំណង់ដែលបានកំណត់ក្នុងកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់។

**មាត្រា១៦ .-**

សំណុំឯកសារស្តីពីការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវតម្កល់ទុករហូតដល់ពេលសំណង់នោះត្រូវបានរុះរើទាំងស្រុងនៅ៖

- អគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំពោះវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំពោះវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

សំណុំឯកសារស្តីពីវិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលគម្រោងប្លង់ស្ថាបត្យកម្មមានតម្លៃពិសេសផ្នែកស្ថាបត្យកម្ម ត្រូវតម្កល់ទុកជាអចិន្ត្រៃយ៍។

**មាត្រា១៧ .-**

អ្នកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវបង់កម្រៃសេវា។

កម្រៃសេវាពិនិត្យនិងផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវបង់នៅពេលទទួលបង្កាន់ដៃទទួលពាក្យស្នើសុំ និងមិនអាចប្រគល់ជូនម្ចាស់សំណើវិញឡើយ ទោះក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចសម្រេចបដិសេធផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ជូនម្ចាស់សំណើក៏ដោយ។

កម្រៃសេវាពិនិត្យនិងផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាពិនិត្យនិងផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

បែបបទនិងបរិបថនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបថនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៥
## លក្ខខណ្ឌនិងនីតិវិធីនៃការប្តូរមុខងារប្រើប្រាស់សំណង់

**មាត្រា១៨ .-**

ការស្នើសុំប្តូរមុខងារប្រើប្រាស់សំណង់ ត្រូវធ្វើឡើងដោយម្ចាស់សំណង់។

អាជ្ញាធរមានសមត្ថកិច្ច អនុញ្ញាតឱ្យប្តូរមុខងារប្រើប្រាស់សំណង់ដោយផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។

ក្នុងករណីការប្តូរមុខងារប្រើប្រាស់សំណង់តម្រូវឱ្យមានការជួសជុល ការកែប្រែ ការដំឡើងបរិក្ខារសំណង់ឬផលិតផលសំណង់ ឬការរុះរើផ្នែកនៃសំណង់ដែលប៉ះពាល់សោភណភាពខាងក្រៅ រចនាសម្ព័ន្ធទ្រទ្រង់ ឬដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ម្ចាស់សំណង់ត្រូវស្នើសុំលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើជាមុន និងត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី ក្រោយការងារជួសជុល ការងារកែប្រែ ការងារដំឡើង ឬការងាររុះរើនោះត្រូវបានបញ្ចប់។

**មាត្រា១៩ .-**

លក្ខខណ្ឌនៃការប្តូរមុខងារប្រើប្រាស់សំណង់ មានដូចខាងក្រោម៖

- សំណង់មានគ្រឿងផ្គុំអាចទ្រទ្រង់បន្ទុកបានប្រកបដោយសុវត្ថិភាពទៅតាមមុខងារប្រើប្រាស់ថ្មីរបស់សំណង់
- ការងារជួសជុល ការងារកែប្រែ ការងារដំឡើង ឬការងាររុះរើសម្រាប់បម្រើមុខងារប្រើប្រាស់ថ្មីបានចប់រួចរាល់ដោយអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- សំណង់មានសុវត្ថិភាពអគ្គិភ័យចំពោះមុខងារប្រើប្រាស់ថ្មី អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ
- សំណង់មានប្រព័ន្ធមេកានិក អគ្គិសនី និងទឹកអាចប្រើប្រាស់បានប្រកបដោយសុវត្ថិភាព អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- ការងារជួសជុល ការងារកែប្រែ ឬការងារដំឡើងសម្រាប់បម្រើមុខងារប្រើប្រាស់ថ្មីដោយប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលអាចធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬស្តង់ដាកម្ពុជា។

**មាត្រា២០ .-**

បញ្ញត្តិស្តីពីកន្លែងទទួលពាក្យស្នើសុំ ការផ្តល់បង្កាន់ដៃទទួលពាក្យស្នើសុំ ការសម្រេចលើពាក្យស្នើសុំ និងកម្រៃសេវានៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះកន្លែងទទួលពាក្យស្នើសុំ ការផ្តល់បង្កាន់ដៃទទួលពាក្យស្នើសុំ ការសម្រេចលើពាក្យស្នើសុំ និងកម្រៃសេវានៃការប្តូរមុខងារប្រើប្រាស់សំណង់។

បែបបទនិងបរិបថនៃការប្តូរមុខងារប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៦
## លក្ខខណ្ឌនិងនីតិវិធីនៃការព្យួរនិងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់

**មាត្រា២១ .-**

អាជ្ញាធរមានសមត្ថកិច្ចដែលផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចព្យួរឬដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់នោះបាន ក្នុងករណីសំណង់នោះលែងមានគុណភាពនិងសុវត្ថិភាពសម្រាប់ការប្រើប្រាស់។

អាជ្ញាធរមានសមត្ថកិច្ច អាចហាមឃាត់ការប្រើប្រាស់សំណង់មួយផ្នែក ដោយមិនព្យួរឬដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងករណីផ្នែកនៃសំណង់នោះ គ្មានសុវត្ថិភាពក្នុងការប្រើប្រាស់ ហើយផ្នែកដទៃទៀត អាចប្រើប្រាស់បានដោយសុវត្ថិភាព។

**មាត្រា២២ .-**

អាជ្ញាធរមានសមត្ថកិច្ច ត្រូវព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងករណីរបាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់បង្ហាញថាសំណង់នោះ ពុំមានសុវត្ថិភាពក្នុងការប្រើប្រាស់។ ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អំពីការព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដោយតម្រូវឱ្យម្ចាស់សំណង់ធ្វើការជួសជុល កែប្រែ ឬរុះរើសំណង់នោះ។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អំពីការអនុញ្ញាតឱ្យប្រើប្រាស់សំណង់ឡើងវិញ ក្នុងករណីម្ចាស់សំណង់បានធ្វើការជួសជុល កែប្រែ ឬរុះរើតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៣ .-**

អាជ្ញាធរមានសមត្ថកិច្ច អាចដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងករណីណាមួយដូចខាងក្រោម៖

១- សំណង់បានបាត់បង់សុវត្ថិភាពផ្នែកគ្រឿងផ្គុំកម្រិតធ្ងន់ធ្ងរនិងមិនអាចជួសជុល កែប្រែ ឬរុះរើតាមលក្ខណៈបច្ចេកទេសដើម្បីធ្វើឱ្យមានសុវត្ថិភាពឡើងវិញ។

២- សំណង់មានសភាពគ្រោះថ្នាក់កម្រិតធ្ងន់ធ្ងរតាមការសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់អំពីការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដោយតម្រូវឱ្យម្ចាស់សំណង់អនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់ដូចមានកំណត់ក្នុងអនុក្រឹត្យនេះតាមស្ថានភាពជាក់ស្តែងនីមួយៗ។

បែបបទនិងបរិបទនៃការព្យួរនិងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៧
## ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់

**មាត្រា២៤.-**

ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវបានកំណត់ដូចខាងក្រោម៖

១- សម្រាប់សំណង់ដែលប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋាន ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវធ្វើរៀងរាល់៥(ប្រាំ)ឆ្នាំម្តងយ៉ាងយូរ។

២- សម្រាប់សំណង់ដែលប្រើប្រាស់ក្នុងគោលដៅលំនៅឋាន ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវធ្វើរៀងរាល់១០(ដប់)ឆ្នាំម្តងយ៉ាងយូរ។

៣- សម្រាប់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យនៃសំណង់ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវធ្វើរៀងរាល់២(ពីរ)ឆ្នាំម្តងយ៉ាងយូរ។

៤- សម្រាប់បរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវធ្វើរៀងរាល់១(មួយ)ឆ្នាំម្តងយ៉ាងយូរ។

សម្រាប់សំណង់ដែលមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់លើកទីមួយ ត្រូវអនុវត្តក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌទី១ខាងលើនេះ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់នោះ។

ចំពោះការអនុញ្ញាតឱ្យប្រើប្រាស់សំណង់ដោយតុណ្ហីភាព ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់លើកទីមួយ ត្រូវអនុវត្តក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌទី១ខាងលើនេះ គិតចាប់ពីថ្ងៃអនុញ្ញាតដោយតុណ្ហីភាពនោះ។

ប្រភេទបរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៥.-**

ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវអនុវត្តដោយ៖

១- ក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងមន្ត្រីត្រួតពិនិត្យសំណង់នៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២. មន្ត្រីត្រួតពិនិត្យសំណង់នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣. មន្ត្រីត្រួតពិនិត្យសំណង់នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

៤. អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់ ឬអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក។

**មាត្រា២៦ .-**

មន្ត្រីត្រួតពិនិត្យសំណង់ ត្រូវជ្រើសរើសក្នុងចំណោមថ្នាក់ដឹកនាំនិងមន្ត្រីរាជការដែលជាអ្នកវិជ្ជាជីវៈ និងដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិល ផ្នែកភូគព្ភសាស្ត្រ ផ្នែកមេកានិក ផ្នែកអគ្គិសនី ផ្នែកទឹក ឬផ្នែកវិស្វកម្មដទៃទៀត។

មន្ត្រីត្រួតពិនិត្យសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មន្ត្រីត្រួតពិនិត្យសំណង់នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវតែងតាំងដោយដីការបស់រដ្ឋបាលរាជធានី ខេត្តសាមី។

មន្ត្រីត្រួតពិនិត្យសំណង់នៃរដ្ឋបាលក្រុង ស្រុក ត្រូវតែងតាំងដោយដីការបស់រដ្ឋបាលក្រុង ស្រុក សាមី។

មន្ត្រីត្រួតពិនិត្យសំណង់នៃរដ្ឋបាលខណ្ឌ ត្រូវតែងតាំងដោយដីការបស់រដ្ឋបាលរាជធានីភ្នំពេញ។

គោលការណ៍ បែបបទ និងនីតិវិធីនៃការតែងតាំងមន្ត្រីត្រួតពិនិត្យសំណង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តឱ្យបានស្របតាមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក សម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

លក្ខណសម្បត្តិ និងលក្ខណវិនិច្ឆ័យសម្រាប់ជ្រើសរើសមន្ត្រីត្រួតពិនិត្យសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៧ .-**

រាល់ចំណាយសម្រាប់ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជាបន្ទុករបស់ម្ចាស់សំណង់។

**មាត្រា២៨ .-**

ម្ចាស់សំណង់ឬអ្នកគ្រប់គ្រងសំណង់ មានកាតព្វកិច្ចប្រគល់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ ជូនអាជ្ញាធរមានសមត្ថកិច្ចយ៉ាងយូរ៣០(សាមសិប)ថ្ងៃក្រោយថ្ងៃផុតកំណត់ ដែលតម្រូវឱ្យអនុវត្តការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

**មាត្រា២៩ .-**

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៨
## ការប្រើប្រាស់សំណង់ដែលមានសភាពគ្រោះថ្នាក់

**មាត្រា៣០ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចត្រួតពិនិត្យនិងតាមដានរាល់សំណង់ដែលមានសភាពគ្រោះថ្នាក់ ដើម្បីចាត់វិធានការចាំបាច់នានាក្នុងការធានាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់ចំពោះសំណង់ដែលស្ថិតក្រោមសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់របស់ខ្លួន និងធ្វើបច្ចុប្បន្នកម្មបញ្ជីនោះជាប្រចាំ។

**មាត្រា៣១ .-**

សំណង់ដែលមានសភាពគ្រោះថ្នាក់ មានដូចខាងក្រោមៈ

- សំណង់ដែលមានគ្រឿងផ្គុំសំណង់ មិនអាចទ្រទ្រង់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់សំណង់
- សំណង់ដែលគ្មានសុវត្ថិភាពអគ្គិភ័យ អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ
- សំណង់ដែលត្រូវបានសាងសង់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ដែលមិនអាចធានាគុណភាពសំណង់និងសុវត្ថិភាពឬសុខភាពរបស់អ្នកប្រើប្រាស់ឬសាធារណជនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬស្តង់ដាកម្ពុជា
- សំណង់ដែលងាយរងគ្រោះថ្នាក់ដោយកត្តាខាងក្រៅដែលបង្កឡើងដោយមនុស្សឬធម្មជាតិមានជាអាទិ៍ ការបាក់ដី ការធ្លាក់ថ្ម ទឹកជំនន់ អគ្គិភ័យ
- សំណង់ដែលមានកត្តាប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពរបស់អ្នកប្រើប្រាស់ ឬសាធារណជនមានជាអាទិ៍ កង្វះអនាម័យ កង្វះខ្យល់ កង្វះពន្លឺ សំណើម ការជ្រាបទឹក ការពុកផុយ។

**មាត្រា៣២ .-**

កម្មសិទ្ធិករនៃសំណង់ដែលស្ថិតក្នុងបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់ ត្រូវផ្តល់កិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងអនុវត្តតាមការណែនាំនិងវិធានការបញ្ចៀសគ្រោះថ្នាក់របស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់និងសាធារណជន។

ម្ចាស់សំណង់និងអ្នកគ្រប់គ្រងសំណង់ដែលស្ថិតក្នុងបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់ មានកាតព្វកិច្ចរាយការណ៍អំពីស្ថានភាពនិងការប្រែប្រួលនៃសំណង់ជូនអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីចាំបាច់ដើម្បីបញ្ចៀសគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបន្ទាន់មានជាអាទិ៍ការជូនដំណឹងជាសាធារណៈ ការតម្រូវឱ្យជួសជុលឬកែប្រែសំណង់ ការកម្រិតការប្រើប្រាស់ ការហាមប្រើប្រាស់ ការហ៊ុមព័ទ្ធសំណង់ ការហាមចូល ការកំណត់បរិវេណសុវត្ថិភាព ការជម្លៀស និងការតម្រូវឱ្យរុះរើសំណង់ទាំងមូលឬមួយផ្នែកទៅតាមកម្រិតហានិភ័យនៃគ្រោះថ្នាក់ដោយរាល់ចំណាយជាបន្ទុករបស់ម្ចាស់សំណង់។

ក្នុងករណីម្ចាស់សំណង់មិនធ្វើការរុះរើសំណង់តាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការរុះរើសំណង់នោះដោយផ្ទាល់ ដោយរាល់ចំណាយជាបន្ទុករបស់ម្ចាស់សំណង់។

**មាត្រា៣៣ .-**

កម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៩
## ការប្រើប្រាស់អគារសហកម្មសិទ្ធិនិងសំណង់ក្នុងបុរី

**មាត្រា៣៤ .-**

វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចផ្ដល់សម្រាប់អគារសហកម្មសិទ្ធិឬសំណង់នៅក្នុងបុរី លុះត្រាតែចំណែករួមនិងចំណែកឯកជននៃអគារសហកម្មសិទ្ធិឬបុរីនោះ ត្រូវបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដីជាមុន។

បញ្ញត្តិស្ដីពីយន្តការនិងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះយន្តការនិងនីតិវិធីនៃការចុះបញ្ជីចំណែករួមនៃអគារសហកម្មសិទ្ធិ។

**មាត្រា៣៥ .-**

សម្រាប់គម្រោងអភិវឌ្ឍអគារសហកម្មសិទ្ធិឬបុរី លក្ខខណ្ឌនៃការផ្ដល់វិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្ដោះអាសន្ន ត្រូវបន្ថែមលក្ខខណ្ឌនៃការបញ្ចប់ការងារសាងសង់បរិក្ខារសាធារណៈជាមូលដ្ឋានមានជាអាទិ៍ ជណ្ដើរ ជណ្ដើរយន្ត ប្រព័ន្ធអគ្គិសនី ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធទឹកកខ្វក់ ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ប្រព័ន្ធលូ ផ្លូវ ប្រព័ន្ធបំភ្លឺសាធារណៈ។

**មាត្រា៣៦ .-**

ចំពោះអគារសហកម្មសិទ្ធិ វិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវផ្ដល់សម្រាប់ចំណែកឯកជននីមួយៗ។ វិញ្ញាបនបត្រប្រើប្រាស់សំណង់សម្រាប់ចំណែករួម ត្រូវរក្សាទុកដោយគណៈកម្មការគ្រប់គ្រងអគារសហកម្មសិទ្ធិនិងចម្លងជូនសហកម្មសិទ្ធិករទាំងអស់។

ចំពោះបុរី វិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវផ្ដល់សម្រាប់សំណង់ដែលមានកម្មសិទ្ធិករដោយឡែកៗ។

វិញ្ញាបនបត្រប្រើប្រាស់សំណង់សម្រាប់ចំណែករួមឬកម្មសិទ្ធិអវិភាគ ត្រូវរក្សាទុកដោយគណៈកម្មការគ្រប់គ្រងបុរី ព្រមទាំងចម្លងជូនកម្មសិទ្ធិករទាំងអស់នៅក្នុងបុរី។

**មាត្រា៣៧ .-**

ការប្រើប្រាស់អគារសហកម្មសិទ្ធិនិងសំណង់នៅក្នុងបុរី ត្រូវអនុលោមតាមបទបញ្ជាផ្ទៃក្នុងនៃអគារសហកម្មសិទ្ធិឬបុរី និងតាមបទដ្ឋានគតិយុត្តជាធរមាន។

ការប្រើប្រាស់ចំណែករួមនិងចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិនិងការគ្រប់គ្រងបុរី។

បែបបទនិងនីតិវិធីនៃការគ្រប់គ្រងការប្រើប្រាស់អគារសហកម្មសិទ្ធិនិងសំណង់នៅក្នុងបុរី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៨ .-**

ម្ចាស់នៃចំណែកឯកជនទាំងអស់នៃអគារសហកម្មសិទ្ធិនិងកម្មសិទ្ធិករទាំងអស់នៃបុរី ត្រូវទទួលបន្ទុករួមគ្នាទៅតាមសមាមាត្រនៃផ្ទៃក្រឡាកម្រាលសំណង់របស់ចំណែកឯកជននីមួយៗ ឬផ្ទៃក្រឡាដីឡូត៍ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀត ចំពោះរាល់ចំណាយលើការងារសម្រាប់ចំណែករួមដូចខាងក្រោម៖

- ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់
- ការងារជួសជុល ការងារកែប្រែសំណង់ តាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច
- ការងាររុះរើសំណង់មួយផ្នែកឬសំណង់ទាំងមូលដើម្បីអនុវត្តវិធានការរបស់អាជ្ញាធរមានសមត្ថកិច្ចដើម្បីបញ្ចៀសគ្រោះថ្នាក់។

សមាមាត្រគិតជាភាគរយនៃចំណាយសម្រាប់ចំណែករួម ដែលម្ចាស់ចំណែកឯកជននីមួយៗនៃអគារសហកម្មសិទ្ធិនិងកម្មសិទ្ធិករទាំងអស់នៃបុរីត្រូវទទួលខុសត្រូវ ត្រូវកំណត់ជាមុនដោយបទបញ្ជាផ្ទៃក្នុងនៃអគារសហកម្មសិទ្ធិឬបុរីនោះ។

## ជំពូកទី១០
## ការប្ដឹងតវ៉ា

**មាត្រា៣៩ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចដូចមានចែងក្នុងអនុក្រឹត្យនេះ មានសិទ្ធិតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចដែលបានចេញសេចក្តីសម្រេចនោះ ឬទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬទៅតុលាការតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីសំណង់និងបទប្បញ្ញត្តិដទៃទៀតជាធរមាន។

## ជំពូកទី១១
## ទណ្ឌកម្ម

**មាត្រា៤០ .-**

ទណ្ឌកម្មក្នុងអនុក្រឹត្យនេះរួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ

- ការព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់
- ការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
- ការហាមឃាត់ការចាត់ចែងនិងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់
- ការហាមឃាត់ការប្រើប្រាស់សំណង់ក្នុងគោលដៅក្រៅពីលំនៅឋាន
- ការហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្ម
- ការពិន័យអន្តរការណ៍។

**មាត្រា៤១ .-**

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់ ការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ និងការហាមឃាត់ការប្រើប្រាស់ ការចាត់ចែង ឬការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់ ជាសមត្ថកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចទៅតាមបញ្ញត្តិស្ដីពីសមត្ថកិច្ចផ្ដល់វិញ្ញាបនបត្រប្រើប្រាស់សំណង់។

អាជ្ញាធរមានសមត្ថកិច្ច អាចផ្សាយការព្រមាន ការព្យួរ ឬការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ជាសាធារណៈនៅក្នុងសារព័ត៌មានឬតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

ការហាមឃាត់ការប្រកបអាជីវកម្ម និងការហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្ម ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធតាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ច។

ការពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចសំណង់។

**មាត្រា៤២ .-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន ចំពោះបុគ្គលដែលបានប្រព្រឹត្តនូវអំពើណាមួយដូចខាងក្រោម៖

- ប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ក្នុងគោលដៅលំនៅឋានមិនត្រឹមត្រូវតាមមុខងារប្រើប្រាស់សំណង់ដូចមានកំណត់ក្នុងវិញ្ញាបនបត្រប្រើប្រាស់សំណង់
- ប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់មិនអនុលោមតាមបទដ្ឋានគតិយុត្តឬបទដ្ឋានបច្ចេកទេសនៃការប្រើប្រាស់សំណង់
- ប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ដោយមិនបានប្រគល់របាយការណ៍ស្ដីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពលើសំណង់របស់ខ្លួនជូនអាជ្ញាធរមានសមត្ថកិច្ចតាមការកំណត់របស់ច្បាប់ស្ដីពីសំណង់
- ប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ក្នុងគោលដៅអាជីវកម្មដោយមិនបានយកចិត្តទុកដាក់ក្នុងការចាត់ចែងថែទាំឬជួសជុលផ្នែកនៃសំណង់ដែលខូចខាត។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវចេញលិខិតព្រមានជូនទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់ដោយតម្រូវឱ្យគោរពតាមបទដ្ឋានគតិយុត្តជាធរមានឬតម្រូវឱ្យធ្វើការជួសជុល កែប្រែ និង/ឬរុះរើសំណង់ឬផ្នែកនៃសំណង់ដើម្បីធានាសុវត្ថិភាពក្នុងការប្រើប្រាស់។

**មាត្រា៤៣ .-**

ត្រូវព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់រយៈពេលមិនលើសពី៣(បី)ខែ ចំពោះអំពើល្មើសណាមួយដូចខាងក្រោម៖

- ប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ក្នុងគោលដៅក្រៅពីលំនៅឋានខុសពីមុខងារប្រើប្រាស់សំណង់ ដូចមានកំណត់ក្នុងវិញ្ញាបនបត្រប្រើប្រាស់សំណង់
- ប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ខុសពីការណែនាំដូចមានកំណត់ក្នុងលិខិតព្រមានរបស់អាជ្ញាធរមានសមត្ថកិច្ច។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់អំពីការព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយតម្រូវឱ្យធ្វើការជួសជុល កែប្រែ និង/ឬ រុះរើសំណង់ឬផ្នែកនៃសំណង់ដែលពុំមានសុវត្ថិភាពក្នុងការប្រើប្រាស់។

ក្នុងកំលុងពេលដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ត្រូវបានព្យួរ ការប្រើប្រាស់សំណង់ឬការធ្វើអាជីវកម្មនៅក្នុងសំណង់នោះ ត្រូវបានហាមឃាត់។

បុគ្គលដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ក្នុងកំលុងពេលដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់នោះត្រូវបានព្យួរ ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីសំណង់។ ក្នុងករណីនេះ មន្ត្រីអធិការកិច្ចសំណង់ត្រូវរៀបចំកំណត់ហេតុបញ្ជូនទៅអយ្យការអមសាលាដំបូង ដើម្បីចាត់វិធានការតាមច្បាប់ជាធរមាន។

**មាត្រា៤៤ .-**

ត្រូវដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចំពោះការមិនអនុវត្តតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចដូចមានកំណត់ក្នុងលិខិតជូនដំណឹងស្តីពីការព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់អំពីការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយបញ្ជាក់អំពីមូលហេតុ វិធានការ និងការតម្រូវនានា ដើម្បីធានាសុវត្ថិភាពម្ចាស់សំណង់ អ្នកប្រើប្រាស់ និងសាធារណជន។

**មាត្រា៤៥ .-**

ត្រូវហាមឃាត់ការចាត់ចែង ការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់ ការប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋាន ឬការផ្សព្វផ្សាយពាណិជ្ជកម្ម ចំពោះសំណង់ដូចខាងក្រោម៖

- សំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់
- សំណង់ដែលម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់ មិនបានអនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់របស់អាជ្ញាធរមានសមត្ថកិច្ច
- សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ត្រូវបានព្យួរឬដកហូត។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់អំពីការហាមឃាត់ដោយបញ្ជាក់អំពីមូលហេតុនិងការតម្រូវនានា ដើម្បីធានាសុវត្ថិភាពម្ចាស់សំណង់ អ្នកប្រើប្រាស់ និងសាធារណជន។

**មាត្រា៤៦ .-**

ត្រូវពិន័យអន្តរការណ៍ ចំពោះបុគ្គលដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋានននូវសំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ជាប្រាក់ចំនួនដូចខាងក្រោម៖

- ៨០ ០០០ ០០០(ប៉ែតសិបលាន)រៀល សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ២០ ០០០ ០០០(ម្ភៃលាន)រៀល សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ២ ០០០ ០០០(ពីរលាន)រៀល សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

ក្នុងករណីដែលបុគ្គលល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ ប៉ុន្តែនៅបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងរយៈពេល៣(បី)ខែ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា៤៧ .-**

ត្រូវពិន័យអន្តរការណ៍ ចំពោះបុគ្គលដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ក្នុងគោលដៅក្រៅពីលំនៅឋានដោយខុសពីមុខងារប្រើប្រាស់សំណង់ដូចមានកំណត់នៅក្នុងវិញ្ញាបនបត្រប្រើប្រាស់សំណង់នោះ ជាប្រាក់ចំនួនដូចខាងក្រោម៖

- ៤០ ០០០ ០០០(សែសិបលាន)រៀល សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ១០ ០០០ ០០០(ដប់លាន)រៀល សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ១ ០០០ ០០០(មួយលាន)រៀល សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

ក្នុងករណីដែលបុគ្គលល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ ប៉ុន្តែនៅបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងរយៈពេល៣(បី)ខែ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា៤៨ .-**

ក្នុងករណីបុគ្គលល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍ត្រូវដំឡើងជាពីរដង។ ករណីការខកខានបង់ប្រាក់ពិន័យអន្តរការណ៍លើសពី៦០(ហុកសិប)ថ្ងៃ ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវដំឡើងជាបីដង។ ករណីការខកខានបង់ប្រាក់ពិន័យអន្តរការណ៍ផុតរយៈពេល៩០(កៅសិប)ថ្ងៃ មន្ត្រីអធិការកិច្ចសំណង់ ត្រូវចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

**មាត្រា៤៩ .-**

បុគ្គលដែលក្លែងបន្លំឯកសារឬផ្ដល់ព័ត៌មានមិនពិតដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីទទួលបានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្លែងបន្លំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬរបាយការណ៍ស្ដីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា៥០ .-**

អ្នករាជការសាធារណៈមានសមត្ថកិច្ចដែលមិនទទួលពិនិត្យសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬបដិសេធផ្ដល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយគ្មានមូលហេតុត្រឹមត្រូវ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១២

## អន្តរប្បញ្ញត្តិ

**មាត្រា៥១ .-**

លិខិតបិទការដ្ឋានសំណង់ដែលបានផ្ដល់មុនអនុក្រឹត្យនេះចូលជាធរមាន មានតម្លៃស្មើនឹងវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ចំពោះសំណង់ដែលមានលិខិតបិទការដ្ឋានសំណង់រួចហើយ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់លើកទីមួយ ត្រូវអនុវត្តក្នុងរយៈពេលដូចមានកំណត់ក្នុងអនុក្រឹត្យនេះ គិតចាប់ពីថ្ងៃអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា៥២ .-**

ចំពោះសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់និងដែលបានសាងសង់រួចមុនច្បាប់ស្ដីពីសំណង់ចូលជាធរមាន ប៉ុន្តែមិនទាន់មានលិខិតបិទការដ្ឋានសំណង់ឬវិញ្ញាបនបត្រប្រើប្រាស់សំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមគោលការណ៍ដូចមានចែងក្នុងមាត្រា១០៦នៃច្បាប់ស្ដីពីសំណង់ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។ ក្នុងករណីនេះ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់លើកទីមួយត្រូវអនុវត្តក្នុងរយៈពេលដូចមានកំណត់ក្នុងអនុក្រឹត្យនេះ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។

**មាត្រា៥៣ .-**

ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ដែលបានសាងសង់រួចមុនច្បាប់ស្ដីពីសំណង់ចូលជាធរមាន អាចអនុវត្តផងដែរដោយ៖

១- អ្នកវិជ្ជាជីវៈដែលមានវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ផ្នែកគ្រឿងផ្គុំសំណង់។

២- អ្នកវិជ្ជាជីវៈដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្លង់សំណង់ផ្នែកគ្រឿងផ្គុំសំណង់។

៣- ក្រុមហ៊ុនដែលមានវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់។

៤- ក្រុមហ៊ុនដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្លង់សំណង់ទូទៅឬផ្នែកគ្រឿងផ្គុំសំណង់។

## ជំពូកទី១៣

## អវសានប្បញ្ញត្តិ

**មាត្រា៥៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១ រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ១៧៧ ដនស/ប្រក.

**ប្រកាស**
**ស្តីពី**
**បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់**
**ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី
- បានឃើញអនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងអាងទន្លេ
- បានឃើញសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណង៖

- ធានាគុណភាព សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សោភណភាពសំណង់ បរិស្ថានល្អ និងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- បង្ការនិងទប់ស្កាត់ហានិភ័យដែលបង្កឡើងដោយការប្រើប្រាស់សំណង់ដែលគ្មានគុណភាពនិងសុវត្ថិភាពសម្រាប់ការប្រើប្រាស់
- ការពារទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈដទៃទៀត
- លើកតម្លៃសេដ្ឋកិច្ចរបស់សំណង់
- គ្រប់គ្រងទិន្នន័យសំណង់ប្រកបដោយប្រសិទ្ធភាព។

**ប្រការ២ .-**

ប្រកាសនេះមានគោលដៅ៖

- កំណត់សមត្ថកិច្ចក្នុងការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
- កំណត់បែបបទនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន
- កំណត់បទប្បញ្ញត្តិបច្ចេកទេសជាមូលដ្ឋានក្នុងការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់។

**ប្រការ៣ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទ ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់និងដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ដូចខាងក្រោម៖

- សំណង់ដែលគ្មានលិខិតអនុញ្ញាតសាងសង់
- សំណង់ដែលសាងសង់ខុសពីលិខិតអនុញ្ញាតសាងសង់
- សំណង់ដែលមានលិខិតអនុញ្ញាតសាងសង់ ប៉ុន្តែគ្មានវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ ឬលិខិតបិទការដ្ឋាន។

**ប្រការ៤ .-**

ក្នុងរយៈពេល២(ពីរ)ឆ្នាំ ក្រោយច្បាប់ស្តីពីសំណង់ចូលជាធរមាន ម្ចាស់សំណង់ត្រូវមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់របស់ខ្លួនពីអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីសំណង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ម្ចាស់នៃសំណង់ដែលបានសាងសង់រួចមុនថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៧ អាចមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់របស់ខ្លួនពីអាជ្ញាធរមានសមត្ថកិច្ចបាន។

**ប្រការ៥ .-**

អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ក្នុងករណីសំណង់នោះមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់និងសាធារណជន និងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

ចំពោះសំណង់ដែលបានសាងសង់ក្រោយថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ វិញ្ញាបនបត្រប្រើប្រាស់សំណង់អាចផ្តល់ជូនបាន លុះត្រាតែម្ចាស់សំណង់បានបង់ប្រាក់ពិន័យអន្តរការណ៍តាមគោលការណ៍

ដែលបានកំណត់ដោយអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

**ប្រការ៦ ._**

វិញ្ញាបនបត្រប្រើប្រាស់សំណង់នៅតែមានសុពលភាព ទោះបីម្ចាស់សំណង់ត្រូវបានផ្លាស់ប្ដូរក៏ដោយ។

ក្នុងករណីវិញ្ញាបនបត្រប្រើប្រាស់សំណង់ត្រូវបានព្យួរ ឬដកហូតដោយអាជ្ញាធរមានសមត្ថកិច្ច សំណង់នោះមិនត្រូវបានអនុញ្ញាតឱ្យបន្តការប្រើប្រាស់ឡើយ។

រាល់ការប្ដូរមុខងារប្រើប្រាស់ និង/ឬកែប្រែគ្រឿងផ្គុំនៃសំណង់ ដែលមានវិញ្ញាបនបត្រប្រើប្រាស់រួចហើយ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតប្ដូរមុខងារប្រើប្រាស់ និង/ឬកែប្រែគ្រឿងផ្គុំសំណង់ពីអាជ្ញាធរមានសមត្ថកិច្ចជាមុន។

ជនណាដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅអាជីវកម្ម នូវសំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ហើយបណ្ដាលឱ្យមានរបួសឬបណ្ដាលឱ្យខូចសុខភាពដល់អ្នកដទៃ ត្រូវផ្ដន្ទាទោសតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីសំណង់។

**ប្រការ៧ ._**

ការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវបង់កម្រៃសេវាសាធារណៈជូនរដ្ឋ។

កម្រៃសេវាក្នុងការផ្ដល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៨ ._**

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងប្រកាសនេះមានដូចខាងក្រោម៖

- **វិញ្ញាបនបត្រប្រើប្រាស់សំណង់** សំដៅដល់លិខិតអនុញ្ញាតផ្ដល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។
- **ម្ចាស់សំណង់** សំដៅដល់ម្ចាស់នៃសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាត ឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់ស្ដីពីសំណង់ចូលជាធរមាន។

- **អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់** សំដៅដល់មន្ត្រីជំនាញដែលបានទទួលការអនុញ្ញាតឬក្រុមហ៊ុនដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់។
- **ឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់** សំដៅដល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ បណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ វិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ ឬគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល។ ក្នុងករណីសាមីសំណើមិនមែនជាកម្មសិទ្ធិករត្រូវមានការព្រមព្រៀងពីម្ចាស់ដី។

## ជំពូកទី២
## សមត្ថកិច្ច

**ប្រការ៩ .-**

អាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ រួមមាន៖

- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់សំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សម្រាប់សំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ សម្រាប់សំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៣
## បែបបទនិងនីតិវិធីនៃការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

### ផ្នែកទី ១
### សំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

**ប្រការ១០ .-**

សំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ មានដូចខាងក្រោម៖

- ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងឯកសារបញ្ជាក់អត្តសញ្ញាណរបស់ម្ចាស់សំណង់ (ត្រូវធ្វើនីត្យានុកូលកម្មនៅអាជ្ញាធរមានសមត្ថកិច្ចឬមន្ទីរសារការី) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់ ចំនួន ០៣ ច្បាប់

- សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំនួន ០៣ ច្បាប់
- សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង (ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ និងប្លង់អគ្គិភ័យ) ចំនួន ០៣ ច្បាប់
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់(បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់(បើមាន)ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន) ចំនួន ០៣ ច្បាប់

គំរូទម្រង់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ជាឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

**ប្រការ១១ ._**

បុគ្គលដែលអាចចុះហត្ថលេខាទទួលខុសត្រូវលើសម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង មានដូចខាងក្រោម៖

១. នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលមានវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ឬសាងសង់។

២. នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្លង់ ឬអាជ្ញាបណ្ណសាងសង់។

៣. នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង ត្រូវមានបោះត្រានិងចុះលេខវិញ្ញាបនបត្រឬលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុនដែលបានអនុវត្តការធ្វើសម្រង់ប្លង់នោះ។

សម្រាប់សំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ បុគ្គលដែលអាចចុះហត្ថលេខាទទួលខុសត្រូវលើសម្រង់ប្លង់តាមការសាងសង់ជាក់ស្តែងផងដែរ មានដូចខាងក្រោម៖

១. អ្នកវិជ្ជាជីវៈដែលមានវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ឬសាងសង់។

២. អ្នកវិជ្ជាជីវៈដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្លង់ឬអាជ្ញាបណ្ណសាងសង់។

ក្នុងករណីនេះ អ្នកវិជ្ជាជីវៈត្រូវបោះត្រានិងចុះលេខវិញ្ញាបនបត្រឬលេខអាជ្ញាបណ្ណនៅលើសម្រង់ប្លង់នោះ។

**ប្រការ១២ .-**

ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។

ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅការិយាល័យច្រកចេញចូលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ផ្នែកទី ២

## នីតិវិធីនៃការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ប្រការ១៣ .-**

ការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំ តែក្នុងករណីដែលសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវ។

**ប្រការ១៤ .-**

បន្ទាប់ពីបានទទួលសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបញ្ជូនសំណុំឯកសារស្នើសុំទៅអគ្គនាយកដ្ឋានសំណង់ ក្នុងរយៈពេលយ៉ាងយូរ ០២ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

**ប្រការ១៥ .-**

អគ្គនាយកដ្ឋានសំណង់ ដោយមាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ជាសេនាធិការ ត្រូវពិនិត្យនិងផ្តល់យោបល់លើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់។ អគ្គនាយកដ្ឋានសំណង់ត្រូវធ្វើកំណត់បង្ហាញសរុបលទ្ធផលនៃការពិនិត្យនិងផ្តល់យោបល់ និងបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យសម្រេច។

**ប្រការ១៦ .-**

ក្នុងករណីសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ពុំមានរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ផ្តល់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។ រយៈពេលនៃការចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

**ប្រការ១៧ .-**

អគ្គនាយកដ្ឋានសំណង់ ត្រូវបញ្ជូនវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀតទៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីប្រគល់ជូនម្ចាស់សំណើ។

គំរូទម្រង់នៃវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

## ផ្នែកទី៣

## នីតិវិធីក្នុងការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

**ប្រការ១៨ .-**

ការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មានរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត អាចចេញបង្កាន់ដៃទទួលពាក្យស្នើសុំ តែក្នុងករណីដែលសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវ។

**ប្រការ១៩ .-**

បន្ទាប់ពីបានទទួលសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារស្នើសុំនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ២(ពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

**ប្រការ២០.-**

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដោយមានការិយាល័យសំណង់ជាសេនាធិការ ត្រូវពិនិត្យនិងផ្តល់យោបល់ និងបញ្ជូនសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់រយៈពេលយ៉ាងយូរ៧(ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យសម្រេច។

ក្នុងករណីសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ពុំមានរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។ រយៈពេលនៃការចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

**ប្រការ២១.-**

បន្ទាប់ពីបានពិនិត្យលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចលើសំណុំឯកសារស្នើសុំ ដូចខាងក្រោម៖

១. ផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់តាមសំណើ ក្នុងករណីពិនិត្យឃើញថា សំណង់បានគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តជាធរមាន ឬ

២. ចេញលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើសំណង់ ក្នុងករណីពិនិត្យឃើញថា សំណង់មិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តជាធរមាន។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារដែលបានសម្រេចរួច ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ០៣(បី) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារស្នើសុំ។

**ប្រការ២២.-**

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវបញ្ជូនវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀតទៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ០៣(បី) ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីប្រគល់ជូនម្ចាស់សំណើ។

គំរូទម្រង់នៃវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

**ប្រការ២៣ .-**

ក្នុងករណីសំណង់មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានចែងក្នុងប្រកាសនេះ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបង្គាប់ឱ្យម្ចាស់សំណង់ធ្វើការកែតម្រូវ និង/ឬបំពេញបន្ថែម ឱ្យស្របតាមបទប្បញ្ញត្តិបច្ចេកទេសមុននឹងចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ក្នុងករណីមិនអាចសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់បាន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីសុំយោបល់។

រយៈពេលនៃការកែតម្រូវនិង/ឬបំពេញបន្ថែម និងរយៈពេលស្នើសុំយោបល់ទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

## ផ្នែកទី ៤

## នីតិវិធីក្នុងការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

**ប្រការ២៤ .-**

ការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មានរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចចេញបង្កាន់ដៃទទួលពាក្យស្នើសុំតែក្នុងករណីដែលសំណុំឯកសារនោះមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវ។

**ប្រការ២៥.-**

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ០២(ពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

**ប្រការ២៦ .-**

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យផ្តល់យោបល់ និងបញ្ជូនសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ។

ក្នុងករណីសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ពុំមានរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។ រយៈពេលនៃការចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

**ប្រការ២៧ .-**

បន្ទាប់ពីបានពិនិត្យលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចលើសំណុំឯកសារស្នើសុំ ដូចខាងក្រោម÷

១. ផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់តាមសំណើ ក្នុងករណីពិនិត្យឃើញថា សំណង់បានគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តជាធរមាន ឬ

២. ចេញលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើសំណង់ ក្នុងករណីពិនិត្យឃើញថា សំណង់មិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តជាធរមាន។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារដែលបានសម្រេចរួច ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ ០៣(បី) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារស្នើសុំ។

**ប្រការ២៨ .-**

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀតទៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ០៣(បី) ថ្ងៃនៃថ្ងៃធ្វើការដើម្បីប្រគល់ជូនម្ចាស់សំណើ។

គំរូទម្រង់នៃវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាឧបសម្ព័ន្ធទី៤នៃប្រកាសនេះ។

**ប្រការ២៩ .-**

ក្នុងករណីសំណង់មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានចែងក្នុងប្រកាសនេះ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្គាប់ឱ្យម្ចាស់សំណង់ធ្វើការកែតម្រូវនិង/ឬបំពេញបន្ថែមឱ្យស្របតាមបទប្បញ្ញត្តិបច្ចេកទេសមុននឹងចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ក្នុងករណីមិនអាចសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់បាន អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីសុំយោបល់។

ក្នុងករណីមិនអាចបានអាចផ្តល់យោបល់បាន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីសុំយោបល់។

រយៈពេលនៃការកែតម្រូវនិង/ឬបំពេញបន្ថែម និងរយៈពេលស្នើសុំយោបល់តាមមាត្រានុក្រមនេះ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

## ជំពូកទី៤

## បែបបទនិងនីតិវិធីនៃការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់

**ប្រការ៣០ .-**

អាជ្ញាធរមានសមត្ថកិច្ចដែលផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចសម្រេចព្យួរឬដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់នោះបាន ក្នុងករណីសំណង់នោះលែងមានគុណភាពនិងសុវត្ថិភាពសម្រាប់ការប្រើប្រាស់។

**ប្រការ៣១ .-**

វិញ្ញាបនបត្រប្រើប្រាស់សំណង់នឹងត្រូវព្យួរដោយអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់បង្ហាញថាសំណង់នោះ ពុំមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់។

ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវបង្គាប់ជាលាយលក្ខណ៍អក្សរឱ្យម្ចាស់សំណង់ធ្វើការកែតម្រូវតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវលុបការព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងករណីម្ចាស់សំណង់បានធ្វើការកែតម្រូវតាមការបង្គាប់របស់អាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៣២ .-**

វិញ្ញាបនបត្រប្រើប្រាស់សំណង់នឹងត្រូវដកហូតដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីណាមួយដូចខាងក្រោម៖

១. មុខងារប្រើប្រាស់សំណង់ត្រូវបានប្តូរ។

២. គ្រឿងផ្គុំសំណង់ត្រូវបានកែប្រែដោយគ្មានការអនុញ្ញាត។

៣. សំណង់មានសភាពគ្រោះថ្នាក់ តាមការសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច។

## ជំពូកទី៥
## របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់

**ប្រការ៣៣ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវសម្រេចផ្តល់ ព្យួរ ឬដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដោយផ្អែកលើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវធ្វើដោយមន្ត្រីត្រួតពិនិត្យសំណង់ ឬក្រុមហ៊ុនដែលមានវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ឬក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវមានហត្ថលេខាទទួលខុសត្រូវរបស់៖

១. មន្ត្រីត្រួតពិនិត្យសំណង់ ឬ

២. នាយកបច្ចេកទេសក្រុមហ៊ុនដែលមានវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ឬ

៣. នាយកបច្ចេកទេសក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវមានបោះត្រា និងចុះលេខវិញ្ញាបនបត្រ ឬលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុននោះ។

គំរូទម្រង់របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជាឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។

**ប្រការ៣៤ .-**

មន្ត្រីត្រួតពិនិត្យសំណង់ ដែលមានសមត្ថកិច្ចចុះអនុវត្តការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ដែលជាកម្មវត្ថុនៃការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ រួមមាន៖

- មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានសំណង់ ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មន្ត្រីជំនាញនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំពោះសំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- មន្ត្រីជំនាញនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ចំពោះសំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៦

## បទប្បញ្ញត្តិបច្ចេកទេស

**ប្រការ៣៥ .-**

វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចផ្តល់ជូនបានសម្រាប់សំណង់ដែលសាងសង់នៅលើដីដែលបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី ស្របតាមប្លង់សុរិយោដី និងប្លង់ហេដ្ឋារចនាសម្ព័ន្ធ។

**ប្រការ៣៦ .-**

វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចផ្តល់ជូនបានសម្រាប់សំណង់ដែលអនុលោមតាមបទប្បញ្ញត្តិរៀបចំដែនដី និងនគរូបនីយកម្មដូចមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តដូចខាងក្រោម៖

ក. ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ ចំពោះសំណង់ដែលបានចាប់ផ្តើមសាងសង់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៧ ដល់ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥។

ខ. ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន បទប្បញ្ញត្តិ គោលការណ៍ និងសេចក្តីណែនាំជាធរមាន ចំពោះសំណង់ដែលបានចាប់ផ្តើមសាងសង់នៅក្រោយថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ និងបញ្ចប់ការសាងសង់មុនច្បាប់ស្តីពីសំណង់ចូលជាធរមាននៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩។

**ប្រការ៣៧ .-**

វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចផ្តល់ជូនបានសម្រាប់សំណង់ដែលអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ដូចខាងក្រោម÷

- គ្រឿងផ្គុំសំណង់អាចទ្រទ្រង់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់របស់សំណង់
- សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ដែលអាចធានាគុណភាពសំណង់ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ ស្របតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ឬស្តង់ដាកម្ពុជាដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដាជាតិ
- មានសុវត្ថិភាពអគ្គិភ័យ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ។

## ជំពូកទី៧

## ការប្តឹងតវ៉ា

**ប្រការ៣៨ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយការសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់ ការព្យួរ ឬការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ មានសិទ្ធិប្តឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ច ឬទៅតុលាការតាមនីតិវិធីជាធរមាន។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ៣៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤០ .-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ជា សុផារ៉ា

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  **"ដើម្បីជូនជ្រាប"**
- ដូចប្រការ៤០ **"ដើម្បីអនុវត្ត"**
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ